# អាគារិយវិន័យ

# និង

# អនាគារិយវិន័យ

សំរាប់អនុបត្តន៍របស់គ្រហស្ថនិងបព្វជិត


រៀបរៀងដោយ

ព្រះគ្រូវីរិយមុនីវិសុទ្ធិញាណ អ៊ុច-រស់

អាចារ្យបង្រៀនបាលីនៅសាលាបាលីជាន់ខ្ពស់

ក្រុងភ្នំពេញ





ព.ស.២៤៧៨ ជលម្ពុត្តភ្នូរ គ.ស.១៩៣៥

## ផ្សាយចេញពី

# www.haotrai.com

## ចែកជាឈម្ភឈានដោយ

MEKONGNET
CONNECTING YOU ALL

AnAnA
Computer
Trusted Service & Quality

# អារម្ភកថា

សៀវភៅនេះខ្ញុំរៀបរៀងជូនឧបាសក ( អ៊ុច ) ឧបាសិកា ( អ៊ុន ) នៅភូមិទូលស្វាយព្រៃ ឃុំលេខ៥ ក្រុងភ្នំពេញ ជាបិតាមាតារបស់ខ្ញុំ ។

ឈ្មោះទាំងពីរនេះ បានចាត់ចែង សង់សាលាបង្រៀនបឋមវិជ្ជាខ្មែរ ១ខ្នង នៅវត្តរលាំងកំពូល ឃុំត្រគៀត ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ ហើយមានប្រាថ្នាចង់បានសៀវភៅធម៌យកទៅចែកផ្សាយ ជាធម្មបណ្ណាការ ក្នុងឱកាសធ្វើបុណ្យឆ្លងសាលានោះទើបប្រឹក្សានឹងខ្ញុំឱ្យចាត់ចែងរៀបរៀងសៀវភៅនេះឡើង ដើម្បីនឹងចំណាយធនធាន បោះពុម្ពនាំយកទៅចែកផ្សាយតាមកម្លាំងសទ្ធា ។ មិនត្រឹមតែប៉ុណ្ណោះ ក្នុងវេលាដែលខ្ញុំកំពុងចាត់ការរៀបរៀង មានលោកជាសប្បុរស បព្វជិតខ្លះគ្រហស្ថខ្លះ បានឮដំណឹងនេះហើយ មានសេចក្តីត្រូវការទៅសុំចូលយកចំណែក ទៅចែកផ្សាយជាធម្មបណ្ណាការ តាមតំបន់របស់ខ្លួនផងក៏មានច្រើន ទើបការនេះក៏កាន់តែមានកម្លាំងកើនឡើងទៀត ។

លំអានធម៌ដែលខ្ញុំរៀបរៀងនេះ ដោយឱកាសមមាញឹកពេក ខ្ញុំមិនបានស្រង់យកអំពីគម្ពីរច្រើនទេ គឺស្រង់យកតែអំពីគម្ពីរមង្គលត្ថទីបនី ១ ត្រង់វិនយកថាប៉ុណ្ណោះមករៀបរៀង តែថ្វីបើដូច្នោះ ក៏គង់មានប្រយោជន៍ច្រើនដល់ពួកជនអ្នកស្វែងរកនូវសមាបដិបត្តិ ។

ដើម្បីនឹងការពារសេចក្ដីភ្លាំងភ្លាត់ វេលាដែលខ្ញុំរៀបរៀងចប់ ខ្ញុំបានយកទៅប្រគេនព្រះតេជព្រះគុណព្រះសិរីសម្មតិវង្សព្រះនាម ( អែម ) ចាងហ្វាងសាលាបាលីជាន់ខ្ពស់ អធិបតីក្រុមជុំនុំប្រែព្រះត្រៃបិដក ឱ្យលោកមេត្តាពិនិត្យផ្ទៀងផ្ទាត់ឱ្យ ។

លុះហើយកិច្ចនេះ ខ្ញុំក៏នាំយកទៅពឹងព្រះរាជបណ្ណាល័យកម្ពុជា ឱ្យជួយទំនុកបំរុងសុំអនុញ្ញាត្តិអំពីរាជការមុខក្រសួង ។

ទីបំផុតនេះ ខ្ញុំសូមជូនកុសលផ្ទាល់ខ្លួនដល់ឧបាសក ( អ៊ុច ) និងឧបាសិកា ( អ៊ុន ) ជាបិតាមាតារបស់ខ្ញុំ និងដល់អស់លោកជាសប្បុរស អ្នកត្រូវការដោយចំណែកបុណ្យ ព្រមទាំងភូតនិករក្នុងអនន្តលោកធាតុ ។

វត្តលង្កា នៅថ្ងៃអាទិត្យ ៧ កើត ខែអាសាឍ ឆ្នាំកុរ សប្តស័ក ព.ស. ២៤៧៨ គ.ស. ១៩៣៥ ។

ព្រះគ្រូវីរិយមុនីវិសុទ្ធិញាណ អ៊ុច រស់

# បញ្ជីមាតិកា

## អាគារិយវិន័យ


| មាតិកា | ទំព័រ |
|---|---|
| អកុសលកម្មបថកថា | ១ |
| កាយកម្មកថា | ៥ |
| ចីវរកម្មកថា | ២០ |
| មនោកម្មកថា | ៣១ |
| អកិរិយវាទាទិកថា | ៣៧ |
| បាណាតិបាតាទិអារម្មណកថា | ៤៥ |
| កុសលកម្មបថកថា | ៤៨ |
| អាទីនវានិសំសកថា | ៥៤ |


## អនាគារិយវិន័យ


| | |
|---|---|
| ពាក្យផ្ដើម | ៥៧ |
| បាតិមោក្ខសំវរសីល | ៧៥ |
| ឥន្ទ្រីយសំវរសីល | ៧៩ |
| អាជីវបារិសុទ្ធិសីល | ៩៤ |
| បច្ចយសន្និស្សិតសីល | ១០៤ |

## នមត្ថុ រតនត្តយស្ស

# អាគារិយវិន័យ

វិន័យដែលព្រះសម្មាសម្ពុទ្ធ ទ្រង់អនុញ្ញាតិទុកសម្រាប់ឱ្យពួកជនជាគ្រហស្ថ អ្នកនៅគ្រប់គ្រងគេហស្ថាន កាន់កាប់ប្រតិបត្តិតាម ហៅថា អាគារិយវិន័យ បានដល់កិរិយាវៀរចាកអកុសលកម្មបថ១០ ប្រព្រឹត្តតាមកុសលកម្មបថ ១០ នោះឯង។

អំពើដែលសត្វប្រព្រឹត្តធ្វើដោយកាយ, វាចារ, ចិត្ត ហៅថាកម្ម មាន២ប្រភេទ គឺ : អំពើល្អ ហៅថាកុសលកម្ម ១, អំពើអាក្រក់ ហៅថា អកុសលកម្ម ១ ។ កុសលកម្ម បានឈ្មោះថាកុសលកម្មបថ ព្រោះជាគន្លងរបស់សុគតិ (១) ឬថា ជាគន្លងរបស់សេចក្តីសុខដែលកើតក្នុងសុគតិភព ។ អកុសលកម្មបានឈ្មោះថា អកុសលកម្មបថ ព្រោះជាគន្លងរបស់ទុគ្គតិ (២) ឬថាជាគន្លងរបស់សេចក្តីទុក្ខដែលកើតក្នុងទុគ្គតិភព ។

---

១ ដំណើរទៅកើតល្អ គឺទៅកើតក្នុងទីសុខ ។ ២ ដំណើរទៅកើតអាក្រក់ គឺទៅកើតក្នុងទីទុក្ខ ។

# អកុសលកម្មបថកថា

❖❖❖❖❖❖

តាមទំនងនេះ គួរពណ៌នាអំពីកុសលកម្មបថជាមុន ព្រោះលោករៀងទុកជាខាងដើម តែថា កុសលកម្មបថ មានសេចក្ដីរាក់ឯកុសលកម្មបថ មានសេចក្ដីជ្រាលជ្រៅ ជាត់ម្ចីរភាពជាង កាលបើបានពណ៌នាតែអំពីអកុសលកម្មបថរួចហើយ ក៏ហាក់ដូចជាបានពណ៌នាអំពីកុសលកម្មបថរួចដែរ ព្រោះកុសលកម្មបថ មានសេចក្ដីសៀតស្ទបតែជាមួយនឹងអកុសលកម្មបថ ព្រោះហេតុនោះនឹងពណ៌នាអំពីអកុសលកម្មបថជាមុន រួចសឹមពណ៌នាអំពីកុសល-កម្មបថតទៅ ។

កុសលកម្មបថ ចែកចេញជា ១០ ប្រភេទគឺៈ

**១_បាណាតិបាតោ** កិរិយាញុំាងសត្វមានជីវិតឱ្យធ្លាក់ចុះកន្លង ឬ ឱ្យធ្លាក់ចុះឆាប់ បានដល់ចេតនាជាហេតុសម្លាប់នូវសត្វ មានជីវិត ដោយកាយរបស់ខ្លួន ឬ ប្រើគេឱ្យសម្លាប់ដោយវាចា ។

**២_អទិន្នាទានំ** កិរិយាកាន់យកនូវទ្រព្យដែលម្ចាស់គេមិនបានឱ្យដោយកាយ ឬ ដោយវាចា បានដល់ចេតនាជាហេតុ

លួចយកនូវទ្រព្យរបស់អ្នកដទៃ ដោយកាយរបស់ខ្លួន ឬ ប្រើគេឱ្យលួច ដោយវាចា ។

**៣.កាមេសុ មិច្ឆាចារោ** កិរិយាប្រព្រឹត្តខុសក្នុងកាមទាំងឡាយ បានដល់ចេតនាជាហេតុប្រព្រឹត្តល្មើសក្នុងមេថុនសមាចារ ។

**៤.មុសាវាទោ** កិរិយាពោលនូវពាក្យមិនពិត បានដល់ចេតនាជាហេតុពោលនូវពាក្យឃ្លៀងឃ្លាត (និយាយកុហក) ។

**៥.បិសុណាវាចា** ចេតនាជាហេតុពោលនូវពាក្យស៊កសៀត បានដល់សំដីញុះញង់នាំឱ្យគេបែកចាកគ្នា ។

**៦.ផរុសវាចា** ចេតនាជាហេតុពោលនូវពាក្យអាក្រក់ បានដល់សំដីចាក់ដោតនាំឱ្យអ្នកដទៃក្តៅចិត្ត (ពាក្យត្រគោះ) ។

**៧.សម្ផប្បលាបោ** កិរិយាពោលនូវពាក្យរោយរាយ បានដល់អកុសលចេតនាជាហេតុពោលនូវពាក្យ ឡេះឡោះឥតមូលដ្ឋាន ។

**៨.អភិជ្ឈា** ធម្មជាតិសំឡឹងយកនូវទ្រព្យរបស់អ្នកដទៃ បានដល់សេចក្តីលោភបែរឈមទៅរកទ្រព្យអ្នកដទៃ ។

**៩.ព្យាបាទោ** សភាពញ៉ាំងប្រយោជន៍និងសេចក្តីសុខ

នៃបុគ្គលដទៃឱ្យធ្លាក់ចុះ បានដល់សេចក្តីគំនុំ ចង់ធ្វើប្រយោជន៍ និងសេចក្តីសុខ ដែលបុគ្គលដទៃបានឱ្យវិនាស ។

១០. **មិច្ឆាទិដ្ឋិ** ធម្មជាតិឃើញខុស បានដល់សេចក្តីយល់ឃើញ ឃ្លាងចាកសភាពដែលពិត ហើយប្រកាន់ខ្ជាប់តាមទំនងនោះ ។

អកុសលកម្មបថទាំង ១០ នេះ លោកចាត់ទុកជា ៣ពួកគឺ : អំពើដែលធ្វើបានដោយកាយ ហៅថាកាយកម្ម ជាពួក១, អំពើដែលធ្វើបានដោយវាចា ហៅថាវចីកម្ម ជាពួក១, អំពើដែលធ្វើបានដោយចិត្ត ហៅថាមនោកម្ម ជាពួក១ ។ ក្នុងអកុសលកម្មបថ ទាំង ១០ នោះ បាណាតិបាត ១, អទិន្នាទាន ១, កាមេសុមិច្ឆាចារ ១, ទាំង ៣ នេះ ចាត់ជា កាយកម្ម ព្រោះជាអំពើធ្វើបានដោយកាយ, មុសាវាទ ១, បិសុណាវាចា ១, ផរុសវាចា ១, សម្ផប្បលាបៈ ១, ទាំង ៤ នេះ ចាត់ជាវិចីកម្ម ព្រោះជាអំពើធ្វើបានដោយវាចា, អភិជ្ឈា ១, ព្យាបាទ ១, មិច្ឆាទិដ្ឋិ ១, ទាំង ៣ នេះ ចាត់ជាមនោកម្ម ព្រោះជាអំពើធ្វើបានដោយចិត្ត, កាយកម្ម ៣, វចីកម្ម ៤, មនោកម្ម ៣ ត្រូវជាអកុសលកម្មបថ ១០ ។

## កាយកម្មកថា

## បាណាតិបាត

**វធកចេតនា** គឺចេតនាជាគ្រឿងសម្លាប់ របស់បុគ្គល ដែលសំគាល់ដឹងថា សត្វមានជីវិត ក្នុងសត្វដែលមានជីវិតមែន, ប្រព្រឹត្តទៅក្នុងកាយទ្វារ ឬវចីទ្វារ ទ្វារណា ១ អាចញ៉ាំង សេចក្តីព្យាយាមឱ្យកើតឡើង ដើម្បីផ្តាច់បង់នូវជីវិតិន្ទ្រិយ របស់ សត្វនោះហៅថា បាណាតិបាត។

បាណាតិបាត នុ៎ះ បើបុគ្គលឱ្យប្រព្រឹត្តទៅក្នុងសត្វតិរច្ឆាន ជាដើម ដែលប្រាសចាកគុណសម្បត្តិ គឺថាសម្លាប់សត្វដែល មិនមានសីលគុណជាដើម, បើសត្វដែលមានសរីរៈតូច មាន ទោសតិច, ដែលមានសរីរៈធំ មានទោសច្រើន ព្រោះ ប្រយោគព្យាយាមធំ, បើប្រយោគព្យាយាមស្មើគ្នា ក៏គង់វត្ថុ ដែលត្រូវសម្លាប់នោះធំ, បើបុគ្គលឱ្យប្រព្រឹត្តិទៅក្នុងមនុស្ស ជា ដើម ដែលមានគុណសម្បត្តិ មនុស្សដែលមានគុណសម្បត្តិតិច មានទោសតិច ដែលមានគុណសម្បត្តិ ច្រើនមានទោសច្រើន, ពុំនោះ បើទំហំសរីរៈនិងគុណសម្បត្តិស្មើគ្នា លោកសំរេចដោយ កិលេសនិងសេចក្តីព្យាយាម របស់អ្នកសម្លាប់, បើអ្នកសម្លាប់

មានកិលេសទន់ ឬ សេចក្តីព្យាយាមទន់ មានទោសតិច, បើមានកិលេសក្លា ឬសេចក្តីព្យាយាមក្លា មានទោសច្រើន។

អង្គរបស់បាណាតិបាតនោះមាន ៥ គឺ :

**១. បាណោ** សត្វមានជីវិត ,

**២. បាណសញ្ញិតា** សេចក្តីដឹងថាសត្វមានជីវិត ,

**៣. វធកចិត្តំ** ចិត្តប្រុងនឹងសម្លាប់ ,

**៤. ឧបក្កមោ** សេចក្តីព្យាយាមនឹងសម្លាប់ដោយអាការឯណានិមួយ ,

**៥. តេន មរណំ** សេចក្តីស្លាប់ដោយព្យាយាមនោះ អ្នកប្រព្រឹត្តិកន្លង ធ្វើបានគ្រប់ព្រមដោយអង្គទាំង៥នេះ ទើបកម្មបថបែកធ្លាយ បើមិនបានគ្រប់ព្រមដោយអង្គទាំង៥ នេះទេ កម្មបថមិនបានបែកធ្លាយឡើយ ។

# អទិន្នាទាន

**ថេយ្យចេតនា** គឺចេតនាជាគ្រឿងលួច របស់បុគ្គល ដែលសំគាល់ដឹងថា ទ្រព្យមានម្ចាស់គេកាន់កាប់រក្សា ក្នុងទ្រព្យដែលមានម្ចាស់គេកាន់កាប់មែន, ប្រព្រឹត្តទៅក្នុងកាយទ្វារ ឬវចីទ្វារ ទ្វារណា១ អាចញ៉ាំងសេចក្តីព្យាយាម ឱ្យកើតឡើង ដើម្បីលួចយកនូវទ្រព្យដែលមានម្ចាស់គេកាន់កាប់រក្សា ហើយដែលគេមិនបានឱ្យដល់ខ្លួន ដោយកាយ ឬដោយវាចានោះ ហៅថា អទិន្នាទាន ។

**អទិន្នាទាន** នុ៎ះ បើបុគ្គលឱ្យប្រព្រឹត្តទៅ ក្នុងទ្រព្យដ៏ថយថោក គឺថាលួចយកនូវទ្រព្យដ៏ថយថោករបស់បុគ្គលដ៏ទៃ មានទោសតិច, លួចយកនូវទ្រព្យដ៏ថ្លៃថ្លា មានទោសច្រើន, បើវត្ថុស្មើគ្នា លួចយកនូវទ្រព្យរបស់បុគ្គលដែលមានគុណសម្បត្តិតិច មានទោសតិច, ដែលមានគុណសម្បត្តិច្រើន មានទោសច្រើន, ពុំនោះ បើលួចទ្រព្យតូចមានទោសតិច, លួចទ្រព្យធំមានទោសច្រើន ព្រោះប្រយោគព្យាយាមធំ, បើវត្ថុដែលលួច និងគុណសម្បត្តិរបស់ម្ចាស់ទ្រព្យស្មើគ្នាលោកសម្រេចដោយកិលេសនិងសេចក្តីព្យាយាមរបស់អ្នកលួច បើអ្នកលួចមានកិលេសទន់ ឬ

សេចក្ដីព្យាយាមទន់ មានទោសតិច, បើមានកិលេសក្លា មាន ទោសច្រើន ។

អង្គរបស់អទិន្នាទាននោះមាន ៥ គឺ :

១- **បរបរិគ្គហិតំ** ទ្រព្យដែលមានបុគ្គលដទៃ កាន់កាប់រក្សា,

២- **បរបរិគ្គហិតសញ្ញិតា** សេចក្ដីដឹងថា ទ្រព្យដែលមានបុគ្គលដទៃ កាន់កាប់រក្សា,

៣- **ថេយ្យចិត្តំ** ចិត្តប្រុងនឹងលួច,

៤- **ឧបក្កមោ** សេចក្ដីព្យាយាមនឹងលួច ដោយអាការឯណានិមួយ,

៥- **តេន ហរណំ** ការលួចយកបាន ដោយសេចក្ដីព្យាយាមនោះ ។

អ្នកប្រព្រឹត្តកន្លង ធ្វើឱ្យគ្រប់ព្រមដោយអង្គ៥ នេះ ទើបកម្មបថបែកធ្លាយ បើមិនបានគ្រប់ព្រមទេ កម្មបថមិនបានបែកធ្លាយឡើយ ។

## កាមេសុ មិច្ឆាចារ

មេថុនសមាចារ ២ ប្រភេទគឺ :

**សទារសន្តោស** : សេចក្តីសន្តោស, ក្នុងភរិយារបស់ខ្លួនដែលច្បាប់អនុញ្ញាតឱ្យ ១, **បរទារគមន** : កិរិយាគប់រក នូវភរិយារបស់បុគ្គលដទៃ ដែលច្បាប់ហាមឃាត់១, ទាំងពីរនេះហៅថា កាម ព្រោះសត្វតែងប្រាថ្នា។

កិរិយាប្រព្រឹត្តិខុស ក្នុងកាមនោះ ចំពោះសត្វដែលជាវត្ថុនៃមេថុន ជាមារយាទដ៏លាមក ដែលអ្នកប្រាជ្ញទាំងឡាយមានព្រះពុទ្ធជាដើម តែងតេះដៀលហៅថា កាមេ សុមិច្ឆាចារ ([1]) បានដល់កិរិយាគប់រកស្ត្រី ជាភរិយារបស់បុគ្គលដ៏ទៃ ដូចពោលមកហើយ, តែបើតាមលក្ខណៈ លោកសំដៅយក អគមនីយដ្ឋានវីតិក្កមចេតនា គឺចេតនាជាហេតុប្រព្រឹត្តកន្លង ក្នុងស្ថានដែលមិនគួរគប់រកគឺ ស្ត្រីដែលគេគ្រប់គ្រងរក្សា ឬ បុរស ដែល

---

១ ក្នុងអភិធម្មវិភាវិនិថា កាម មាន ២ គឺមេថុនកាម ១, រសកាម ១, មេថុនកាមសំដៅយកមេថុនសមាចារ ១ប្រភេទដូចពោលមកហើយ ឯរសកាម សំដៅយករសរបស់អាហារ : សទារសន្តោស និងរសរបស់អាហារឯទៀត ព្រះសម្ពុទ្ធទ្រង់អនុញ្ញាតក្នុងទីនេះ, ដែលហៅថា កិរិយាប្រព្រឹត្តិខុសក្នុងកាមនោះសំដៅយក បរទារគមនៈ និងសុរាបានៈ ហើយលោកចាត់ សុរាបានៈ ចូលជាកម្មបថ ក្នុងទីនេះផង ។

មិនមែនជាស្វាមីរបស់ខ្លួន ឬដែលបុគ្គលអ្នកគ្រប់គ្រងខ្លួន មិនបានអនុញ្ញាតឱ្យប្រព្រឹត្តទៅក្នុងកាយទ្វារ ដោយប្រាថ្នាដើម្បីនឹងសេពនូវអសទ្ធម្ម ហៅថា កាមេសុ មិច្ឆាចារ ។

ស្ត្រីដែលជាអគមនីយដ្ឋានរបស់បុរស គឺស្ត្រីដែលបុរស មិនគួរគប់រក ដោយអសទ្ធម្មមាន ២០ ពួកគឺ :

**១- មាតុរក្ខិតា** ស្ត្រីដែលមាតាគ្រប់គ្រងរក្សា.

**២- បិតុរក្ខិតា** ស្ត្រីដែលបិតាគ្រប់គ្រងរក្សា.

**៣- មាតាបិតុរក្ខិតា** ស្ត្រីដែលមាតានិងបិតាគ្រប់គ្រងរក្សា.

**៤- ភាតុរក្ខិតា** ស្ត្រីដែលបងប្អូនប្រុសគ្រប់គ្រងរក្សា.

**៥- ភគិនីរក្ខិតា** ស្ត្រីដែលបងប្អូនស្ត្រីគ្រប់គ្រងរក្សា.

**៦- ញាតិរក្ខិតា** ស្ត្រីដែលញាតិគ្រប់គ្រងរក្សា.

**៧- គោត្តរក្ខិតា** ស្ត្រីដែលបុគ្គលមានគោត្រជាមួយគ្នា ឬ មានជាតិវង្សជាមួយគ្នាគ្រប់គ្រងរក្សា.

**៨- ធម្មរក្ខិតា** ស្ត្រីដែលបព្វជិតអ្នកប្រព្រឹត្តធម៌ត្រូវគ្នាពួកណា ១ គ្រប់គ្រងរក្សា .

**៩- សារក្ខា** ស្ត្រីដែលប្រកបដោយ ការរក្សា គឺស្ត្រីដែលមានស្វាមីហើយ ឬ មានគេប្រកាន់ទុកហើយ .

១០. **សបរិទណ្ឌា** ស្រីដែលប្រកបដោយអាជ្ញា គឺស្ត្រីដែលព្រះរាជាដាក់រាជអាជ្ញាមិនឱ្យប្រព្រឹត្តតាមអំពើចិត្ត ឬមិនឱ្យបុរសណា ១ ទៅប្រព្រឹត្តកន្លង.

១១. **ធនក្កីតា** ស្ត្រីដែលគេទិញ ឬលោះដោយទ្រព្យ ទោះបីតិចក្តី, ច្រើនក្តី យកមកធ្វើជាភរិយា ឬត្រឹមតែលោះមកប៉ុណ្ណោះ មិនបានដល់ធ្វើជាភរិយាក៏ដោយ.

១២. **ឆន្ទវាសិនី** ស្ត្រីដែលរត់តាមទៅនៅ ធ្វើជាភរិយារបស់បុរសដទៃ ដោយសេចក្តីពេញចិត្តរបស់ខ្លួន ហើយបុរសក៏ទទួលព្រមផង.

១៣. **ភោគវាសិនី** ស្ត្រីដែលទៅនៅ ធ្វើជាភរិយារបស់បុរសដទៃព្រោះតែភោគៈ គឺស្ត្រីដែលបានភោគៈ យ៉ាងហោចត្រឹមតែអង្រែនិងត្បាល់ជាដើម អំពីបុរសណាមួយ ក៏ទៅនៅធ្វើជាភរិយាបុរសនោះ.

១៤. **បដវាសិនី** ស្ត្រីដែលទៅនៅ ធ្វើជាភរិយារបស់ បុរសដទៃព្រោះតែសំពត់ គឺស្ត្រីអ្នកកំសត់ ដែលគ្រាន់តែបុរសណា១ឱ្យសំពត់ស្លៀក ឬដណ្តប់ប៉ុណ្ណោះ ក៏សុខចិត្តចូលទៅនៅធ្វើជាភរិយារបស់គេ .

**១៥-** **ឱទបត្តកិនី** ស្ត្រីដែលគេផ្ដោបដៃ ជាមួយនឹងបុរស ជ្រលក់ទៅក្នុងពាងទឹក ឬផ្តិលទឹក១ ហើយគេពោលថា "អ្នកនាងទាំងឡាយចូរប្រឡូកគ្នា, ចូរកុំបែកចាកគ្នាដូចជាទឹកនេះ(១)" គឺស្ត្រីដែលគេផ្សំផ្គុំឱ្យជាភរិយា របស់បុរសដោយវិធីបែបនេះ.

**១៦-** **ឱភតចុម្ពដា** ស្ត្រីដែលគេដាក់ទ្រនូល ចុះអំពីក្បាល គឺស្ត្រីអ្នករកឧសជាដើម ដែលបុរសណា១ ជួយដាក់ទ្រនូល អំពីក្បាល ហើយនាំយកទៅធ្វើជាភរិយា .

**១៧-** **ទាសី ច ភរិយា ច** ស្ត្រីដែលជាទាសីគេផង, ជាភរិយាគេផងគឺ ស្ត្រីដែលជាទាសីរបស់បុរសណា១ ហើយបុរសនោះយកធ្វើជាភរិយា.

**១៨-** **កម្មការី ច ភរិយា ច** ស្ត្រីដែលជា កូនឈ្នួលគេផង ជាភរិយាគេផង គឺស្ត្រីដែលចូលទៅនៅធ្វើការស៊ីឈ្នួលឱ្យបុរសណាមួយ ហើយបុរសនោះទៅសំរេចឃរាវាសធម៌ ជាមួយ លែងត្រូវការដោយភរិយារបស់ខ្លួន.

**១៩-** **ធជាហដា** ស្ត្រីដែលសេនានាំមក ដោយទង់ជ័យ គឺស្ត្រីដែលសេនាជំឡើងទង់ជ័យ លើកទ័ពទៅច្បាំងផ្ដើម

១ មុខជានឹងមានវិធីផ្សំផ្គុំរបស់ជាតិណា ឬប្រទេសណាបែបនេះមិនខាន ។

យកដែនរបស់ស្តេចដទៃ កៀរយកបានមក ហើយមានបុរស ណា១ យកធ្វើជាភរិយា.

**២០. មុហុត្តិកា** ស្ត្រីដែលមានបុរស ទៅភពប្រសព្វតែមួយស្របក់ៗ គឺស្ត្រីដែលជាសហាយស្មន្តរបស់បុរសណា១ ។

ស្ត្រីទាំង២០ ចំពូក ដូចពោលមកនេះ សុទ្ធតែជាអគមនីយដ្ឋានរបស់បុរស គឺថាសុទ្ធតែជាស្ត្រីដែលបុរសមិនគប្បី ទៅគប់រកដោយអសទ្ធម្មទាំងអស់. បើទៅគប់រកចាត់ជាមិច្ឆាចារ បែកធ្លាយកម្មបថ ។

បុរសដទៃមិនមែនជាស្វាមី ឬមិនមែនជាកំណាន់របស់ខ្លួនជាអគមនីយដ្ឋាន របស់ស្ត្រី១២ចំពូកខាងចុង មានស្ត្រីឈ្មោះសារក្ខាជាដើម គឺមិនត្រូវឱ្យស្ត្រី ទាំង១២ចំពូកនោះ គប់រកដោយអសទ្ធម្ម បើគប់រក ចាត់ជាមច្ឆាចារបែកធ្លាយកម្មបថ។

មែនពិតបុរសទាំងឡាយ មិនត្រូវទៅគប់រកស្ត្រី ដែលមានបុគ្គលណាមួយ គ្រប់គ្រងរក្សានោះឡើយ. បើទៅគប់រកស្ត្រី ៨ ជំពូកខាងដើម មានស្ត្រីឈ្មោះ មាតុរក្ខិតា ជាដើម ចាត់ជាមិច្ឆាចារ ព្រោះស្ត្រីទាំងនោះ មានមាតាជាដើម គ្រប់គ្រងរក្សាមិនឱ្យទៅរួមសង្វាស ជាមួយនឹងបុរសតាមទំនើងចិត្ត. បើទៅ

គប់រកស្ត្រី ១២ ចំពូកខាងចុង មានស្ត្រីឈ្មោះ សារក្ខាជាដើម ចាត់ជាមច្ឆាចារ ព្រោះជាអាការរំលោភចូលទៅ ក្នុងស្ថានដែលបុរសដទៃគេខាខាំង។ ប៉ែកខាងស្ត្រីវិញ បើមានស្វាមីហើយ ឬ មានបុរសណា១ប្រកាន់ទុកជាភរិយាហើយ មិនត្រូវទៅគប់រក បុរសដទៃដោយអសទ្ធម្មឡើយ ហេតុនោះស្ត្រី ១២ ចំពូកខាងចុង មានស្ត្រីឈ្មោះសារក្ខាជាដើម បើទៅគប់រកបុរសដទៃ ចាត់ជាមិច្ឆាចារបែកធ្លាយកម្មបថ ព្រោះស្ត្រីទាំងនោះបានឈ្មោះថា មានស្វាមីហើយ. ឯស្ត្រី ៨ចំពូកខាងដើម មានស្ត្រីឈ្មោះ មាតុរក្ខិតា ជាដើម បើទៅគប់រកបុរសណា១ មិនបានឈ្មោះថា មិច្ឆាចារទេ ព្រោះស្ត្រីទាំងនោះ មិនទាន់មានស្វាមីជាអ្នកហួងហែង សម្ផស្សនៅឡើយ. បើទុកជាមាតានិងបិតាជាដើម បីបាច់រក្សា ក៏មិនមែនប្រាថ្នានូវសម្ផស្សដោយខ្លួនឯងដែរ គឺគ្រាន់តែឃាត់នូវអំពើអនាចារ មិនឱ្យទៅគប់រកបុរសដទៃប៉ុណ្ណោះ ព្រោះហេតុនោះមាតានិងបិតាជាដើម មិនមែនជាឥស្សរៈ លើសម្ផស្ស របស់ស្ត្រីទាំងនោះឡើយ ។

**កាមេសុ មិច្ឆាចារ** នុ៎ះ បើបុគ្គលឱ្យប្រព្រឹត្តទៅក្នុងអគមនីយដ្ឋាន ដែលប្រាសចាក សីលគុណជាដើម មានទោស

តិច, ដែលបរិបូណ៌ដោយសីលគុណជាដើម មានទោសច្រើន, ពុំនោះ បើទុកជាប្រាសចាកសីលគុណជាដើម តែបុគ្គលឱ្យប្រព្រឹត្តទៅទាំងបំពាន ក៏មានទោសច្រើនដែរ, បើសេចក្តីប្រាថ្នារបស់អ្នកទាំងពីរស្មើគ្នា លោកសំរេចដោយកិលេស និងសេចក្តីព្យាយាមរបស់អ្នកប្រព្រឹត្ត, បើអ្នកប្រព្រឹត្តមានកិលេសទន់ ឬសេចក្តីព្យាយាមទន់ មានទោសតិច, បើមានកិលេសក្លា ឬសេចក្តីព្យាយាមក្លា មានទោសច្រើន ។

អង្គរបស់ កាមេសុ មិច្ឆាចារ នោះមាន ៤ គឺ :

**១- អគមនីយវត្ថុ** វត្ថុមិនគួរគាប់រក គឺស្ត្រីដែលគេគ្រប់គ្រងរក្សា ឬបុរសដែលមិនមែនជាស្វាមីរបស់ខ្លួន,

**២- តស្មិំ សេវនចិត្តំ** ចិត្តចង់សេពក្នុងវត្ថុដែល មិនគួរគប់រកនោះ,

**៣- សេវនប្បយោគោ** សេចក្តីព្យាយាមនឹងសេព [១]

**៤- មគ្គេន មគ្គប្បដិបត្តិ អធិវាសនំ** ការប្រជល់ ឬការទទួលនូវមគ្គដោយមគ្គ ។

---

១ ត្រង់អង្គទី៣នេះ លោកពោលទុកសម្រាប់តែខាងបុរស ព្រោះបុរសច្រើនមានព្យាយាមនឹងសេព, ឯស្ត្រីមិនសូវមានព្យាយាមនឹងសេពឡើយ. តែបើបែរជាមានព្យាយាមវិញក៏លោកចាត់ទុកថា មានអង្គគ្រប់ទាំង៤ដូចគ្នា ព្រោះហេតុនោះត្រូវជ្រាបថា អង្គដែលទៀងនោះមានតែ៣, គឺខាងបុរសក៏៣, ខាងស្ត្រីក៏៣, ឯអង្គទី៣នេះ សម្រាប់ថែមទៅលើអ្នកដែលមានព្យាយាម នឹងសេព។

អ្នកប្រព្រឹត្តកន្លង ប្រព្រឹត្តធ្វើឱ្យគ្រប់ព្រម ដោយអង្គទាំង៣ ឬ ទាំង ៤ នេះ ទើបបែកធ្លាយកម្មបថ បើមិនបានគ្រប់ព្រមទេ មិនបានបែកធ្លាយឡើយ ។

## កម្ម-ទ្វារ

អំពើទាំង ៣ ប្រការគឺ : បាណាតិបាត១, អទិន្នាទាន១, កាមេសុមិច្ឆាចារ១ដូចពោលមកនេះ លោកចាត់ជាកាយកម្ម ព្រោះជាអំពើធ្វើបានដោយកាយ, បណ្តាអំពើទាំង ៣ ប្រការ នុ៎ះ បាណាតិបាត ១, អទិន្នាទាន ១ ប្រព្រឹត្តទៅបានក្នុងទ្វារ ២ គឺ : កាយទ្វារ និងវិចីទ្វារ,ឯកាមេសុមិច្ឆាចារ ប្រព្រឹត្តទៅបាន តែក្នុងកាយទ្វារ ១ ប៉ុណ្ណោះ។

មែនពិត កាយកម្មជាអកុសល រមែងតាំងឡើង តែក្នុង កាយទ្វារនិងវចីទ្វារប៉ុណ្ណោះ មិនអាចតាំងឡើង ក្នុងមនោទ្វារ បានឡើយ ព្រោះហេតុនោះ បើបុគ្គល សម្លាប់សត្វមានជីវិត ដោយកាយរបស់ខ្លួន, លួចយកនូវ ទ្រព្យដែលមានម្ចាស់កាន់ កាប់រក្សាដោយកាយរបស់ខ្លួន,ប្រព្រឹត្តកាមេសុមិច្ឆាចារ ដោយ កាយរបស់ខ្លួន , ដូច្នេះ អំពើដែលបុគ្គលធ្វើទាំងនុ៎ះ ចាត់ ជាកាយកម្ម, ឯទ្វារដែលធ្វើចាត់ជាកាយទ្វារ , បើបុគ្គលបង្គាប់

អ្នកដទៃឱ្យធ្វើដោយវាចាថា "អ្នកចូរសម្លាប់ឈ្មោះនេះ ឬសត្វនេះ, អ្នកចូរលួចទ្រព្យនេះ (១) ដូច្នេះ អំពើដែលបុគ្គលធ្វើទាំងនោះចាត់ជាកាយកម្មដូចគ្នា, តែឯទ្វារដែលធ្វើចាត់ជាវចីទ្វារព្រោះបង្គាប់អ្នកដទៃឱ្យធ្វើដោយវាចា, កាយកម្មជាអកុសលតាំងឡើងក្នុងកាយទ្វារនិងវចីទ្វារ មានទំនងដូចអធិប្បាយមកនេះ ។ ឯអភិជ្ឈា, ព្យាបាទ មិច្ឆាទិដ្ឋិ ដែលកើតរួមគ្នានឹងវធកចិត្ត, ថេយ្យចិត្ត, សេវនចិត្ត ទាំង៣នោះ, ខ្លះជាចេតនាបក្ខិកា ចាត់ថាជាពួករបស់ចេតនា ដែលប្រព្រឹត្តទៅក្នុងកាយទ្វារ បានឈ្មោះថាកាយកម្ម, ខ្លះជាអព្វោហារិកា ចាត់ថាមិនមែនជាអង្គរបស់បញ្ញត្តិ គឺមិនគួរពោលថាជាបាណាតិបាតជាដើម ឬបើនឹងហៅថា មនោកម្មក៏មិនបាន។

ក៏អភិជ្ឈា, ព្យាបាទ និងមិច្ឆាទិដ្ឋិ ទាំង៣នេះ លោកចាត់ទុកជាមនោកម្ម មានសេចក្តីច្បាស់លាស់ទៅខាងចុងក៏ពិតមែនហើយ តែទុកណាជាដូច្នោះ ក៏ក្នុងកាយកម្មនេះ គង់មានកើតខ្លះៗ ជាជំនួយដល់ចិត្តទាំង៣ នោះតែនឹងបាន ឈ្មោះថាបាណាតិបាតជាដើមក៏ទេ ឬ នឹងបានឈ្មោះថា មនោកម្មក៏ទេដែរ តែ

---

១ កាមេសុ មិច្ឆាចារ ប្រើគេធ្វើមិនមានទោស ទើបមិនមានវិធីបង្គាប់ឱ្យគេធ្វើ

បើហៅថាកាយកម្មវិញបានខ្លះ ព្រោះចូលជាពួករបស់ចេតនា ដែលប្រព្រឹត្តិទៅក្នុងកាយទ្វារហើយ។ ជាពួករបស់ចេតនាដែល ប្រព្រឹត្តិទៅក្នុងកាយទ្វារហើយ។ រឿងនេះ គួរយល់ឧទាហរណ៍ ដូចធាតុទាំង៤ មានបឋវីធាតុជាដើម។

សេចក្ដីថា : ធាតុទាំង៤ ជាបច្ច័យដល់គ្នានឹងគ្នា តែង អាស្រ័យគ្នាទៅវិញទៅមក, ធាតុនិមួយៗ ត្រូវអាស្រ័យធាតុ៣ ក្រៅអំពីខ្លួនជាជំនួយ ដូចបឋវីធាតុ ក៏គង់មាន អាបោធាតុ, តេជោធាតុ វាយោធាតុ នៅក្នុងនោះ តែដែលបានឈ្មោះថា បឋវីធាតុ ព្រោះធាតុដីផ្សាយឡើងច្រើនជាងគេ, ឯធាតុ៣ ក្រៅអំពីនេះ មានតិចគ្រាន់តែជាជំនួយប៉ុណ្ណោះ នឹងហៅតាមសភាពរបស់ខ្លួនថា "អាបោធាតុ, តេជោធាតុ, វាយោធាតុ " ដូច្នេះ មិនបាន តែបើហៅថា "បឋវីធាតុ" ដូច្នេះវិញបាន ព្រោះចូលមកជាពួក របស់បឋវីធាតុហើយ។ សូម្បីធាតុទាំង ៣ ខាង ចុង ក៏គង់មានដំណើរសេចក្ដីប្រហែលៗគ្នា លោកអ្នកសិក្សា គប្បីពិចារណាតាមលំអាននេះផងចុះ ។

ឧទាហរណ៍ ដែលនាំមកពន្យល់នេះ មានទំនងយ៉ាងណា សូម្បី អភិជ្ឈា, ព្យាបាទ នឹងមិច្ឆាទិដ្ឋិ ដែលរួមគ្នានឹង វធកចិត្ត

កើតជាដើមដូចអធិប្បាយរួចមកហើយ ក៏រួមគ្នានឹងវេធកចិត្ត ជាដើម ដូចអធិប្បាយរួចមកហើយ ក៏មានទំនងយ៉ាងនោះដែរ. បណ្ឌិតជន គប្បីសន្និដ្ឋាន ជ្រាបតាមន័យនេះចុះ ។

កាយកម្មកថា ចប់

-------------

## វចីកម្មកថា

## មុសាវាទ

កាយប្បយោគ ឬវចីបយោគ របស់បុគ្គលដែលប្រាថ្នាចង់ពោលនូវពាក្យ ឱ្យឃ្លៀងឃ្លាតចាកសេចក្តីពិត ជាហេតុនឹងបំបាត់នូវប្រយោជន៍របស់បុគ្គលដទៃ (១) ហៅថាមុសា គឺពាក្យកុហក ឬពាក្យមិនពិត។ ចេតនា ដែលអាចញុំាងកាយប្បយោគ ឬវចីបយោគ ឱ្យកើតឡើងដើម្បីពោលនូវពាក្យឃ្លៀងឃ្លាតនោះ ដោយសេចក្តីប្រាថ្នា ចង់ពោលឱ្យឃ្លៀងឃ្លាតចំពោះបុគ្គលដទៃ ហៅថាមុសាវាទ បានដល់ចេតនាជាហេតុពោលនូវពាក្យមិនពិតឬចេតនាជាហេតុញុំាងពាក្យមិនពិតឱ្យកើតឡើង។

**មុសាវាទ** នុ៎ះ បើបំបាត់នូវប្រយោជន៍របស់បុគ្គលដទៃតិច មានទោសតិច, បំបាត់នូវប្រយោជន៍របស់បុគ្គលដទៃច្រើន មានទោសច្រើន, បំបាត់នូវប្រយោជន៍របស់បុគ្គលដែលមានសីលគុណជាដើមតិច មានទោសតិច, ដែលមានសីលគុណជា

១ ពាក្យថាបំបាត់នូវប្រយោជន៍របស់បុគ្គលដទៃនេះ លោកចង្អុលឱ្យឃើញថា ជាមុសាវាទដែលដល់នូវកម្មបថ, បើមិនមានបំបាត់នូវប្រយោជន៍របស់បុគ្គល ដទៃ មិនដល់នូវកម្មបថឡើយ ។

ដើមច្រើន មានទោសច្រើន, អ្នកពោលមានកិលេសទន់ មានទោសតិច, មានកិលេសក្លា មានទោសច្រើន ។

ន័យមួយទៀតថា : មុសាវាទ នុ៎ះ ប៉ែកខាងគ្រហស្ថ បើមានគេមករករបស់ដែលខ្លួនមាន ហើយពោលកុហកដោះថាមិនមានដោយមិនចង់ឱ្យ ឬពោលកុហកដោះទាល់ឯណានីមួយចំពោះខ្លួនមានទោសតិច, បើធ្វើជាបន្ទាល់សាក្សី ឱ្យគេ ហើយពោលកុហក ដើម្បីបំបាក់នូវប្រយោជន៍របស់បុគ្គលដទៃ មានទោសច្រើន, ប៉ែកខាងបព្វជិត បើបានប្រេង ឬសប្បិ (១) បន្តិចបន្តួច ហើយពោលបំផ្លើសឱ្យច្រើនឡើងថា "ហូរគគ្រាំគគ្រេងដូចជាទឹកស្ទឹង " ដោយប្រាថ្នានឹងសើចលេងមាន ទោសតិច, បើមិនឃើញសោះ ថាឃើញ, មិនឮសោះថាឮ ជាដើមមានទោសច្រើន ។

ន័យខាងចុងនេះ បើពោលរួបរួមឱ្យខ្លីចុះមក ក៏ឃើញថាមុសាវាទ នុ៎ះ បើបុគ្គលណា១ ទោះបីគ្រហស្ថក្ដី, បព្វជិតក្ដីពោលបំនងនឹងមិនឱ្យខូចប្រយោជន៍ខ្លួន ឬមិនឱ្យកើតអន្តរាយ

---

១ ទឹកដោះគោឬទឹកដោះពពែជាដើម ១បែបដែលគេដាំចម្រាញ់ច្រើនភ្លើងឬច្រើនអំពុះជរាបដល់នៅតែជាតិថ្មៀ ដើម្បីទុកឱ្យបានយូរ ។

ដល់ខ្លួន មានទោសតិច, បំណងនឹងឱ្យបានប្រយោជន៍ ដល់បុគ្គលដែលមិនគួរឱ្យបាន, ឱ្យខាតប្រយោជន៍របស់បុគ្គលដែលមិនគួឱ្យខាត ដូចធ្វើជាសាក្សីកោងជាដើម មានទោសច្រើន, ពោលបំផ្លើសរបស់តិចឱ្យទៅជាច្រើន, របស់តូចឱ្យទៅជាធំ, របស់ល្អមឱ្យទៅជាណាស់ ដោយបំណងនឹងសើចលេង មានទោសតិច, របស់ដែលមិនឃើញសោះថាឃើញ, មិនឮសោះថាឮ, មិនដឹងសោះថាដឹង មានទោសច្រើន ។

អង្គរបស់មុសាវាទនោះ មាន ៤ គឺ :

**១. អតថំ វត្ថុ** វត្ថុមិនពិត ឬ មិនពិត,

**២. វិសំវាទនចិត្តំ** ចិត្តចង់ពោលឱ្យឃ្លៀងឃ្លៀត,

**៣. តជ្ជោ វាយាមោ** សេចក្ដីព្យាយាមដ៏សមគួរ ដល់ពាក្យដែលចង់ពោលឱ្យឃ្លាងឃ្លាត គឺថាព្យាយាមនឹងពោលឱ្យឃ្លៀងឃ្លាត ចាកហេតុដែលពិត តាមទំនងដែលចិត្តចង់ពោលនោះ,

**៤. បរស្ស តទត្ថវិជាននំ** កិរិយា ញុំាងបុគ្គលដទៃឱ្យដឹងច្បាស់ នូវសេចក្ដីនេះ ។

ន័យមួយទៀត អង្គរបស់មុសាវាទនោះ មានលោកអង្គខ្លះថាមានតែ ៣ ដូច្នេះវិញ គឺ :

១- **អតថំ វចន** ពាក្យមិនពិត,

២- **វិសំវាទនចិត្តំ** ចិត្តចង់ពោលឱ្យឃ្លៀងឃ្លាត,

៣- **បរស្ស តទត្ថវិជាននំ** កិរិយា ញុំាងបុគ្គលដទៃឱ្យដឹងច្បាស់នូវសេចក្តីនោះ ([១]) ។

អ្នកប្រព្រឹត្តកន្លង ប្រព្រឹត្តធ្វើឱ្យគ្រប់ព្រមដោយអង្គទាំង៤ ឬទាំង៣នេះ ទើបបែកធ្លាយកម្មបថ បើមិនបានគ្រប់ព្រមទេ មិនបានបែកធ្លាយឡើយ ។

## **បិសុណា វាចា**

ចេតនារបស់បុគ្គលដែលមានចិត្តសៅហ្មងដោយលោភៈ ឬទោសៈ អាចញុំាងកាយប្បយោគ ឬវចីបយោគ ឱ្យកើតឡើង ដើម្បីញុំាងអ្នកដទៃឱ្យបែកចាកគ្នា ឬដើម្បីនឹងបំបែកអ្នកម្ខាងយកមកធ្វើជាទីស្រឡាញ់របស់ខ្លួន ហៅថាបិសុណាវាចា បានដល់ចេតនា ជាហេតុពោលនូវពាក្យញុះញង់ នាំចុះនាំឡើង។

---

១ ន័យទាំងពីរនេះ គង់មានដំណើរសេចក្តីជាមួយគ្នា ដូចត្រង់អង្គទី១ ក្នុងន័យដើមថា វត្ថុមិនពិត ន័យចុងថា ពាក្យមិនពិត ក៏មិនបែកគ្នាប៉ុន្មាន ប្លែកតែសំដីប៉ុណ្ណោះ. ន័យដើមចែកអង្គ៤ ប្រាប់សេចក្តីព្យាយាមដោយឡែក. ន័យចុងចែកអង្គតែ៣ អាងពាក្យថា ញុំាងអ្នកដទៃ ឱ្យដឹងច្បាស់នូវសេចក្តីនោះថាមុខជាមានសេចក្តីព្យាយាមនៅក្នុងនោះ ដើម្បីនឹងពោល ឬ នឹងសំដែងនូវកាយវិការៈណា ១ ឱ្យគេដឹង ។

**បិសុណា វាចា** នុ៎ះ បើបំបែកបុគ្គលដែលមានសីលគុណជាដើមតិច មានទោសតិច, បំបែកបុគ្គលដែលមានសីលគុណជាដើមច្រើន មានទោសច្រើន, បើបំបែកមិនបែក មានទោសតិច, បំបែកបែក មានទោសច្រើន, អ្នកពោលបំបែកមានកិលេសទន់ មានទោសតិច, មានកិលេសក្លាមានទោសច្រើន ។

អង្គរបស់បិសុណា វាចានោះ មាន ៤ គឺ :

១- **ភិន្ទិតព្វោ បរោ** អ្នកដទៃដែលគួរបំបែកបាន,

២- **ភេទបុរេក្ខារតា វា បិយកម្យតា វា** សេចក្ដី ប៉ុនប៉ងចង់ឱ្យបែកចែកគ្នា ឬសេចក្ដីប្រាថ្នា ចង់ឱ្យបានមកជាទីស្រឡាញ់របស់ខ្លួន,

៣- **តជ្ជោ វាយាមោ** សេចក្ដីព្យាយាម ដ៏សមគួរដល់សេចក្ដីប៉ុនប៉ង ឬសេចក្ដីប្រាថ្នានោះ គឺថាសេចក្ដីព្យាយាមនឹងបំបែកតាមសេចក្ដីប៉ុនប៉ង ឬសេចក្ដីប្រាថ្នានោះ,

៤- **តទត្ថវិជាននំ** កិរិយា ញុំាងបុគ្គលដែលខ្លួនប្រុងនឹងបំបែក ឱ្យដឹងច្បាស់នូវសេចក្ដីនោះ (១) ។

អ្នកប្រព្រឹត្តកន្លង ប្រព្រឹត្តធ្វើឱ្យគ្រប់ព្រម ដោយអង្គទាំង៤ នេះ ទើបបែកធ្លាយកម្មបថ, បើមិនបានគ្រប់ព្រមទេ មិនបាន

បែកធ្លាយឡើយ ។

## ផរុសវាចា

ចេតនាដ៏អាក្រក់ចំណែក[១] របស់បុគ្គលដែលប្រកបដោយទោសចិត្ត អាចញ៉ាំងកាយប្បយោគ ឬវចីបយោគ ឱ្យកើតឡើងដើម្បីកាត់បង់នូវវត្ថុជាគ្រឿងរាប់អាន ([២]) របស់បុគ្គលដទៃ ហៅថា ផរុសវាចា បានដល់ចេតនា ជាហេតុពោលនូវពាក្យគ្រគោះ ឬពាក្យចាក់ដោត ។

មានពាក្យពន្យល់ថា : វចីបយោគ ដែលជាហេតុកាត់បង់នូវវត្ថុជាគ្រឿង រាប់អានមានពាក្យជេរចំពោះជាតិជាដើម បើប្រកបដោយចិត្តដ៏ទន់ មិនបានឈ្មោះថាផរុសវាចាឡើយ ([៣]) ក្នុងយ៉ាងដូចមាតា បិតាជេរបន្ទោសកូន, អាចារ្យនិងឧបជ្ឈាយ៍ស្តីបន្ទោសសិស្សជាដើម, លុះតែប្រកបដោយចិត្តអាក្រក់គ្រោតគ្រាតផង ទើបហៅថា ផរុសវាចា ។

---

១ អង្គទី៤នេះ លោកពោលថា អ្នកនាំពាក្យញុះញង់ទៅប្រាប់ដល់បុគ្គលណា ឱ្យតែបុគ្គលនោះបានដឹងសេចក្តីច្បាស់ ទោះបីបែកចាកគ្នាក្តី, មិនបែកក្តី ឈ្មោះថាកម្មបថ បែកធ្លាយ យកត្រង់ដឹងសេចក្តីច្បាស់ជាប្រមាណ, តែមានលោកអង្គខ្លះ ពោលថាបើគេមិនបែកចាកគ្នា កម្មបថក៏មិនបែកធ្លាយដែរ ។ ២ សំដៅយក អក្កោសវត្ថុ ១០ មានជាតិជាដើម ។ ៣ ក្នុងព្រហ្មជាលសុត្តដីកាថា : មិនបានឈ្មោះថា ផរុសវាចា ក៏ពិត ព្រោះចិត្តស្រទន់តែកង់ដល់ នូវកម្មបថ ។

មែនពិត មានមាតាបិតាខ្លះជេរកូនថា : "អាចោរចិញ្រ្ចាំ, មេចោរចិញ្រ្ចាំ ឬអាគេកាប់ មេគេកាប់ " ដូច្នេះជាដើម តែចិត្តទន់ សូម្បីតែស្លឹកឧប្បល១ ក៏មិនចង់ឱ្យធ្លាក់មកលើកូនផង។ មានអាចារ្យនិងឧបជ្ឈាយ៍ខ្លះស្តីបន្ទោសថា : " អ្នកអស់នេះ អស់លោកនេះនិយាយស្តីឥតអៀនខ្មាស, ឥតកោតញញើតដូចម្តេច? អ្នកទាំងឡាយចូរកំទេចវាចោលចេញទៅ " ដូច្នេះជាដើម តែចិត្តប្រាថ្នា ចង់ឱ្យសិស្សទាំងនោះបានបរិបូរណ៍ ដោយចំណេះវិជ្ជា និងគុណសម្បត្តិប៉ុណ្ណោះព្រោះ ហេតុនោះទើបលោកមិនបានចាត់ចូលក្នុងផរុសវាចាផង ។

មានរឿងដំណាលថា : មានទារកម្នាក់ មិនកាន់តាមពាក្យរបស់មាតា ហើយដើរទៅកាន់ព្រៃ, មាតាឃាត់មិនស្តាប់ស្រែកជេរផ្តាសាទារកនោះថា "មេក្របីកាចចូរដេញតាម អាទៅ", ស្រាប់តែដល់កណ្តាលព្រៃ, ក៏លេចមេក្របីមកពិតមែន។ ទារកនោះក្រឡេកឃើញ ក៏ធ្វើនូវសច្ចកិរិយាអធិដ្ឋានថា "មាតារបស់ខ្ញុំពោលនូវហេតុឯណាដោយមាត់, ហេតុនោះសូមកុំឱ្យមាន, គាត់គិតនូវហេតុឯណាដោយចិត្ត ហេតុនោះសូម ឱ្យមានចុះ", គ្រាន់តែប៉ុណ្ណេះស្រាប់តែមេក្របីនោះឈរទក់នៅនឹងថ្កល់

ដូចជាគេចងក្នុងទីនោះឯង។

រឿងនេះ លោកនាំមកដំណាលឱ្យឃើញប្រាកដថា បើសំដីគ្រគោះ តែចិត្តស្រទន់ មិនបានឈ្មោះថាផរុសវាចាឡើយ ត្រាតែសំដីក៏គ្រគោះ ចិត្តក៏អាក្រក់ ទើបបានឈ្មោះថា ផរុសវាចា. ពុំនោះ បើវាចាស្រទន់ទេ ប៉ុន្តែចិត្តអាក្រក់ ដូចជាបុគ្គលមានប្រាថ្នាចង់សម្លាប់បុគ្គលណា១ ហើយនិយាយបញ្ឆោះថា "អ្នកទាំងឡាយ ចូរផ្ដេកអ្នកនេះឱ្យស្រួលទៅចុះ" ដូច្នេះជាដើម ក៏ហៅថា ផរុសវាចា ដោយពិត ព្រោះចិត្តអាក្រក់ ។

ផរុសវាចា នុ៎ះ បុគ្គលឱ្យប្រព្រឹត្តទៅចំពោះបុគ្គលណា. បើបុគ្គលនោះមានសីលគុណជាដើមតិច មានទោសតិច, មានសីលគុណជាដើមច្រើន មានទោសច្រើន ឬផរុសវាចា ដែលមិនដល់នូវភាពជាកម្មបថ គឺថាមិនដល់ថ្នាក់បែកធ្លាយ កម្មបថមានទោសតិច. ដែលដល់នូវភាពជាកម្មបថ គឺថាដល់ថ្នាក់បែកធ្លាយកម្មបថ មានទោសច្រើន. បើអ្នកពោលមានកិលេសទន់មានទោសតិច. មានកិលេសក្លា មានទោសច្រើន ។

អង្គ របស់ផរុសវាចា នោះ មាន ៣ គឺ :

**១- អក្កោសិតព្វោ បរោ** អ្នកដទៃ ដែលគប្បីជេរបាន.

**២. ព្យាបាទចិត្ត** ចិត្តកំរើក ឬថា ចិត្តខឹង([១]).

**៣. អភិជ្ឈាសនា** ការជេរដោយអក្កោសវត្ថុ១០ អក្កោសវត្ថុណា ១ ។

អ្នកប្រព្រឹត្តកន្លង ប្រព្រឹត្តធ្វើឱ្យគ្រប់ព្រម ដោយអង្គទាំង៣នេះ ទើបបែកកម្មបថ បើមិនបានគ្រប់ព្រមទេ មិនបានបែកធ្លាយឡើយ ។

## សម្ផប្បលាបៈ

**អកុសលចេតនា** ដែលអាចញាំង កាយប្បយោគ ឬ វចីបយោគ ឱ្យកើតឡើង ដើម្បីញាំងបុគ្គលដទៃឱ្យដឹងច្បាស់នូវពាក្យប្រឌិតឥតមូលហេតុ ហៅថា សម្ផប្បលាបៈ បានដល់ចេតនាជាហេតុពោលនូវពាក្យប្រឌិតរោយរាយឥតមូលដ្ឋាន ។

សម្ផប្បលាបៈ នុ៎ះ បើបុគ្គលសេពតិច ឬសន្សំតិច មានទោសតិច សេពច្រើន ឬសន្សំច្រើន មានទោសច្រើន។ បើមិនមានគេកាន់តាម ឬជឿតាម មានទោសតិច. មានគេកាន់តាម ឬជឿតាម មានទោសច្រើន. បើអ្នកពោលមានកិលេសទន់មាន

១ អង្គទី២នេះ សំដៅយកតែចិត្តខឹងប្រាថ្នាចង់ជេរបំបាក់មុខតែប៉ុណ្ណោះ. មិនមែនសំដៅយកចិត្តខឹងប្រាថ្នាចង់ឱ្យស្លាប់នោះឡើយ. បើខឹងដូច្នោះលោកចាត់ជាព្យាបាទវិញ ។

ទោសតិច, មានកិលេសក្លា មានទោសច្រើន ។

អង្គរបស់សម្ផប្បលាបៈ នោះមាន ២ គឺ :

**១- ការតយុទ្ធសិតាហរណាធិនិរត្ថកកថាបុរេក្ខារតា** សេចក្តីប្រាថ្នា ចង់ពោលនូវពាក្យឥតប្រយោជន៍ មានរឿងចម្បាំង មហាភារតៈ និងរឿងរាពណ៍នាំនាងសិតាជាដើម,

**២- តថារូបីកថាកថនំ** ការពោលនូវពាក្យ មានសភាពដូច្នោះ ។

អ្នកប្រព្រឹត្តកន្លង ប្រព្រឹត្តធ្វើឱ្យគ្រប់ព្រមដោយអង្គទាំង ២ នេះ ទើបបែកធ្លាយកម្មបថ, បើមិនបានគ្រប់ព្រមទេ មិនបានបែកធ្លាយឡើយ ។

## **កម្ម-ទ្វារ**

អំពើទាំង៤ ប្រការគឺៈ មុសាវាទ១, បិសុណាវាចា១, ផរុសវាចា១, សម្ផប្បលាបៈ១ ដូចពោលមកនេះ លោកចាត់ជាវចីកម្ម ព្រោះអំពើបានដោយវាចា ហើយសុទ្ធតែជាអំពើប្រព្រឹត្តទៅក្នុងទ្វារ ២ គឺៈ កាយទ្វារ វចីទ្វារដូចគ្នាទាំង ៤ ។

ពិតមែន វចីកម្ម ជាអកុសល រមែងតាំងឡើងតែក្នុងកាយទ្វារ និងវចីទ្វារប៉ុណ្ណោះ មិនអាចតាំងឡើងក្នុង**មនោទ្វារ**

បានឡើយ ព្រោះហេតុនោះបើបុគ្គលពោលនូវមុសាវាទជាដើម ដោយលំនាំដៃ ក្តាប់ដៃ, វាសដៃ ឬសរសេរអក្សរជាដើម, អំពើដែលបុគ្គលប្រព្រឹត្តធ្វើទាំងនោះ ចាត់ថា វចីកម្ម, ឯទ្វារដែលធ្វើ ចាត់ជាកាយទ្វារ, បើបញ្ចេញវចីភេទ ពោលនូវមុសាវាទជាដើម ដោយវាចា, អំពើដែលបុគ្គលប្រព្រឹត្តធ្វើទាំងនោះចាត់ជាវចីកម្ម។ ឯទ្វារដែលធ្វើ ចាត់ជា វចីទ្វារ ។

**វចីកម្ម** ជាអកុសលតាំងឡើងក្នុងកាយទ្វារ និងវចីទ្វារ មានទំនងដូចអធិប្បាយមកនេះឯង ។ ឯអភិជ្ឈា, ព្យាបាទ និងមិច្ឆាទិដ្ឋិ ដែលកើតរួមគ្នានឹងវិសំវាទនចិត្តជាដើមនោះ, ខ្លះជាចេតនាបក្ខិកា ចាត់ថាជាពួករបស់ចេតនាដែលប្រព្រឹត្តទៅក្នុងវចីទ្វារ បានឈ្មោះថា វចីកម្ម, ខ្លះជាអព្វោហារិកា ចាត់ថាមិនមែនជាអង្គរបស់បញ្ញត្តិ គឺមិនគួរពោលថាជាមុសាវាទជាដើម ឬបើនឹងហៅថា មនោកម្ម ក៏មិនបាន មានឧទាហរណ៍ពន្យល់ដូចក្នុងកាយកម្មដែរ ។

វចីកម្មកថា ចប់

## មនោកម្មកថា

# អភិជ្ឈា

ធម្មជាតិ សំឡឹងរំពៃបែរឈមទៅរកទ្រព្យ របស់បុគ្គលដទៃ ហៅថា អភិជ្ឈា បានដល់សេចក្តីលោភសំយុងមុខឈមទៅរកទ្រព្យអ្នកដទៃ ។

អភិជ្ឈា នុ៎ះ បើសំឡឹងឈមទៅរកទ្រព្យរបស់បុគ្គលដែលមានសីលគុណជាដើមតិច មានទោសតិច, សំឡឹងឈមទៅរកទ្រព្យរបស់បុគ្គលដែលមានសីលគុណជាដើមច្រើន មានទោសច្រើន (ក្រៅអំពីនេះ ដូចក្នុងអទិន្នាទាន) ។

អង្គ របស់អភិជ្ឈានោះមាន ២ គឺ:

១- **បរភណ្ឌំ** ទ្រព្យជារបស់បុគ្គលដទៃ,

២- **អត្តនោ បរិណាមនំ** ការបង្អោនមកដើម្បីខ្លួន ([1])

អភិជ្ឈានេះ បើគ្រាន់តែមានសេចក្តីលោភដែលមានទ្រព្យនៃបុគ្គលដទៃជាវត្ថុកើតឡើង តែមិនបានគិតបង្អោនមកដើម្បីខ្លួនដោយដាច់ណាត់ថា "ទ្រព្យនេះត្រូវតែបានមកជារបស់អញ" ដូច្នេះទេ មិនបែកធ្លាយកម្មបថឡើយ, ត្រាតែបានបង្អោនមក

---

១ សំដៅយកការបង្អោនមកដោយចិត្ត។

ដើម្បីខ្លួនដូច្នោះ ទើបបែកធ្លាយ ។

## ព្យាបាទ

សភាពញ៉ាំងប្រយោជន៍ និងសេចក្តីសុខរបស់បុគ្គលដទៃឱ្យវិនាស ហៅថា ព្យាបាទ បានដល់សេចក្តីគុំគួនដែលកើតមកអំពីអាឃាតវត្ថុ ៩ (១) ។

ព្យាបាទនោះ នុ៎ះ បើញ៉ាំងប្រយោជន៍និងសេចក្តីសុខរបស់បុគ្គល ដែលខ្វះសីលគុណជាដើមឱ្យវិនាស មានទោសតិច, ញ៉ាំងប្រយោជន៍ និងសេចក្តីសុខរបស់បុគ្គល ដែលសម្បូរសីលគុណ ជាដើមឱ្យវិនាស មានទោសច្រើន ( ក្រៅអំពីនេះដូចក្នុងផរុសវាចា ) ។

អង្គរបស់ព្យាបាទនោះ មាន ២ គឺ:

**១- បរសត្តោ** សត្វដទៃ,

**២- តស្ស វិនាសចិន្តា** គំនិតចង់ឱ្យសត្វនោះវិនាស។

---

២ អាឃាតវត្ថុ ហេតុនាំឱ្យកើតសេចក្តីគុំគួនគឺ ហេតុដែលកើតចំពោះខ្លួន៣. កើតចំពោះសត្វ និងសង្ខារដែលជាទីស្រឡាញ់៣, កើតចំពោះសត្វ និងសង្ខារដែលមិនជាទីស្រឡាញ់៣, កើតចំពោះខ្លួនព្រោះមិនចង់ឱ្យគេធ្វើអំពើអាក្រក់ មកលើខ្លួនចែកជា អតីត, អនាគត, បច្ចុប្បន្នត្រូវជា៣, កើតចំពោះសត្វនិងសង្ខារដែលជាទី សឡាញ់ព្រោះកាន់ជើង, កើតចំពោះសត្វនិងសង្ខារដែល មិនជាទីស្រឡាញ់ ព្រោះមិនចង់ឱ្យគេទៅរាប់រក បែកជាកាលបី១ដូចគ្នា។

ព្យាបាទនេះ បើគ្រាន់តែមានសេចក្តីក្រោធ ដែលមានសត្វជនៃផាវត្ថុកើតឡើង តែមិនបានគិតចង់ឱ្យសត្វនោះវិនាស ដោយដាច់ណាត់ថា " សត្វនេះគប្បីសូន្យទៅ, គប្បីវិនាសទៅ" ដូច្នេះទេ មិនបានបែកធ្លាយកម្មបថឡើយ ត្រាតែបានគិតដូច្នេះ ទើបបែកធ្លាយ ។

## មិច្ឆាទិដ្ឋិ

ធម្មជាតិឃើញខុស ដោយការប្រកាន់ផ្ទុយចាកសេចក្តីពិត ហៅថា មិច្ឆាទិដ្ឋិ បានដល់សេចក្តីយល់ឃើញឃ្លាង ឬប្រកាន់ឃ្លាងខុសចាកសភាពដែលពិតមែន ។

មិច្ឆាទិដ្ឋិ នុ៎ះ បើបុគ្គលសេពតិច ឬសន្សំតិចមានទោសតិច, សេពច្រើន ឬសន្សំច្រើន មានទោសច្រើន ឬមិច្ឆាទិដ្ឋិ ដែលមិនទៀង នៅវិវុះបាន មានទោសតិច, ដែលទៀងវិវុះមិនបាន មានទោសច្រើន ។

អង្គ របស់មិច្ឆាទិដ្ឋិនោះ មាន ២ គឺ:

**១-វត្ថុនោ គហិតាការវិបរីតតា** ភាពនៃអាការប្រកាន់ ដ៏ឃ្លៀងឃ្លាត ចាកវត្ថុដែលពិតមែន.

**២-យថាចតំ គណ្ហាតិតថាភាវេន តស្សុបដ្ឋានំ**

ការប្រកាន់នូវវត្ថុនោះ ដោយអាការៈដ៏ឃ្លៀងឃ្លាតយ៉ាងណា វត្ថុនោះ នៅប្រាកដជាឃ្លៀងឃ្លាត ដោយសភាពយ៉ាងនោះ ដដែលមិនលះបង់ចេញ ។

អ្នកប្រកាន់មិច្ឆាទិដ្ឋិ លុះតែគ្រប់ព្រមដោយអង្គទាំង ២ នេះ ទើបកម្មបថបែកធ្លាយ បើមិនបានគ្រប់ព្រមទេ មិនបានបែកធ្លាយឡើយ។ ន័យ១ទៀត លោកពោលកម្រិតទុកថា កម្មបថបែកធ្លាយតែដោយទិដ្ឋិ៣ គឺៈ នត្ថិកទិដ្ឋិ១, អកិរិយទិដ្ឋិ១, អហេតុកទិដ្ឋិ ១ ([១]) មិនបានបែកធ្លាយ ដោយទិដ្ឋិដទៃឡើយ ។

## កម្ម~ទ្វារ

**មនោកម្ម** ទាំង៣ ពួកគឺៈ អភិជ្ឈា១, ព្យាបាទ១, មិច្ឆាទិដ្ឋិ១ ដូចពោលមកនេះ ប្រព្រឹត្តទៅបានគ្រប់ទ្វារទាំង៣គឺៈ កាយទ្វារ, វចីទ្វារ និងមនោទ្វារ។ សេចក្តីថាៈ បើបុគ្គលមានចិត្តប្រកបដោយអភិជ្ឈា ញ៉ាំងកាយឱ្យកំរើក ធ្វើនូវអំពើដែលគួរចាប់កាន់បានដោយដៃជាដើម, មានចិត្តប្រកបដោយព្យាបាទ ធ្វើនូវអំពើផ្សេងៗ មានវាយរកដំបងព្រនង់ជាដើម, មានចិត្តប្រកបដោយមិច្ឆាទិដ្ឋិ យល់ឃើញថា "ខន្ទកុមារ និងព្រះសិវៈជាដើមប្រសើរ

---

១ ទិដ្ឋិទាំង៣នេះនឹងមានពោលពិស្តារទៅខាងចុង។

បំផុត " ហើយធ្វើនូវអភិវាទនកម្ម, អញ្ជលិកម្ម ឬតាក់តែងធ្វើរាន, តាំងនិងគ្រឿងប្រស់ព្រំជាដើម ចំពោះខន្ទកុមារ និងព្រះសិវៈជាដើម (១) នោះ, អំពើដែលបុគ្គលធ្វើទាំងនោះចាត់ជាមនោកម្ម, ឯទ្វារដែលធ្វើ ចាត់ជាកាយទ្វារ។ ក្នុងទីនេះ ចេតនាដែលតាំងឡើងក្នុងកាយទ្វារ ជាអព្យោហារិកា មិនមែនជាអង្គរបស់បញ្ញត្តិ គឺមិនគួរពោលថាជាកាយកម្មបាន។ បើបុគ្គលមានចិត្តប្រកបដោយអភិជ្ឈា សំឡឹងរំពៃ បែរឈមទៅរកទ្រព្យសម្បត្តិរបស់អ្នកដទៃ ហើយញាំងវាចាឱ្យកំរើកថា "ទ្រព្យជារបស់អ្នកដទៃនោះ ត្រូវតែបានមកជារបស់អញ " ដូច្នេះ, មានចិត្តប្រកបដោយព្យាបាទ ញាំងវាចាឱ្យកំរើកថា "សត្វទាំងឡាយនេះ ចូរវិនាសទៅ, ចូរស្លាប់ទៅ ចូរកុំមាន " ដូច្នេះ មានចិត្តប្រកបដោយមិច្ឆាទិដ្ឋិ ញាំងវាចាឱ្យកំរើកថា "ទានដែលបុគ្គលឱ្យហើយ មិនមានផល " ដូច្នេះជាដើម, អំពើដែលបុគ្គលធ្វើ

១ ពួកបុត្ររបស់ព្រះសិវៈហៅថា ខន្ទកុមារ,ព្រះឥស្វរ ឬព្រះម្ចាស់សួគ៌ ដែលពួកអ្នកកាន់សាសនាព្រាហ្មណ៍ជាដើម សន្មតឡើងថាជាតួព្រះ១អង្គគត នៅក្នុងស្ថានសួគ៌សម្រាប់ត្រួតត្រាលោកមិនចេះនិព្វាន ហៅថាព្រះសិវៈ, ពួកជនមិច្ឆាទិដ្ឋិ ប្រកាន់ថា សត្វដែលទៅកើតក្នុងសុគតិភព ឬទុគ្គតិភព មិនមែនទៅព្រោះ អំពើល្អ ឬអាក្រក់ឡើយ គឺទៅដោយធ្វើត្រូវ ឬធ្វើខុសចំពោះពួកបុត្រព្រះសិវៈ នឹងតួព្រះសិវជាដើម ។

ទាំងនោះចាត់ជា មនោកម្ម, ឯទ្វារដែលធ្វើ ចាត់ជាជាវចីទ្វារ។ ក្នុងទីនេះ ចេតនាដែលតាំងឡើងក្នុងវចីទ្វារ ក៏ជាអព្យោហារិកា មិនមែនជាអង្គរបស់បញ្ញត្តិ គឺមិនគួរពោលថាជា វចីកម្មបាន។ បើបុគ្គលមិនបានញុំាងកាយ និងវាចាឱ្យកំរើកសោះ អង្គុយនៅតែក្នុងទីស្ងាត់, ញុំាងចិត្តដែលប្រកបដោយអភិជ្ឈា, ព្យាបាទនិងមិច្ឆាទិដ្ឋិ ឱ្យកើតឡើងស្មើៗ, អំពើដែលបុគ្គលធ្វើទាំងនោះ ចាត់ជាមនោកម្ម ឯទ្វារដែលធ្វើ ចាត់ជាមនោទ្វារ ។ ក្នុងទីនេះចេតនាក្តី, អភិជ្ឈាធម៌ជាដើម ដែលសម្បយុត្តដោយចេតនាក្តី សុទ្ធតែតាំងឡើងក្នុងមនោទ្វារទាំងអស់ ([១]) ។

មនោកម្ម ជាអកុសលតាំងនៅក្នុងទ្វារទាំង៣ មានទំនងដូចអធិប្បាយមកនេះ ។

មនោកម្មកថា ចប់

---

១ ក្នុងមនោកម្មនេះ លោកមិនបានពោលទុកថាជា អព្យោហារិកា ដូចក្នុងកម្មឯទៀតឡើយ

អកិរិយវាទាទិកថា

## អកិរិយវាទ អហេតុកវាទ នត្ថិកវាទ (១)

លំដាប់នេះ នឹងពណ៌នាអំពីអកិរិយវាទ, អហេតុកវាទ និង នត្ថិកវាទ ឬឧច្ឆេទវាទតទៅ ដើម្បីនឹងញ៉ាំងអ្នកសិក្សា ឱ្យបាន ឈ្លាសវៃក្នុងមិច្ឆាទិដ្ឋិដែលមានមកក្នុងមនោកម្មកថា ដូចពោល រួចមកហើយ ។

ក៏ពាក្យថា: "បុគ្គលធ្វើបាបដោយខ្លួនឯង ឬប្រើគេឱ្យធ្វើ, កាត់ដៃកាត់ជើង របស់សត្វដទៃជាដើមដោយខ្លួនឯង ឬប្រើគេ ឱ្យកាត់, បៀតបៀនកំដៅអ្នកដទៃដោយអាជ្ញាជាដើមដោយខ្លួន ឯង ឬប្រើគេឱ្យបៀតបៀន, ធ្វើសេចក្ដីសោកឱ្យកើតដល់អ្នក ដទៃដោយរឹបអូសយកទ្រព្យសម្បត្តិជាដើមដោយខ្លួនឯង ឬប្រើ គេឱ្យធ្វើ, ធ្វើឱ្យអ្នកដទៃលំបាកដោយបង្អត់អាហារ និងបញ្ចូល គុកជាដើមដោយខ្លួនឯង ឬប្រើគេឱ្យធ្វើ, ធ្វើឱ្យអ្នកដទៃញាប់ញ័រ ដោយចាប់ចងជាដើមដោយខ្លួនឯង ឬប្រើគេឱ្យធ្វើ, សម្លាប់ សត្វ, លួចទ្រព្យគេ, កាត់តំណផ្ទះរបស់អ្នកដទៃ, រឹបជាន់ ឬ ប្លន់ដណ្ដើមយកទ្រព្យសម្បត្តិរបស់អ្នកស្រុក, ចោមប្លន់អ្នកផ្ទះ មួយៗ, ឈរនៅកណ្ដាលផ្លូវ ចាំស្កាត់ដណ្ដើមយកទ្រព្យសម្បត្តិ

អ្នកដំណើរ, ប្រព្រឹត្តិក្បត់ក្នុងភរិយារបស់អ្នកដទៃ, និយាយកុហកបោកប្រាស់អ្នកដទៃជាដើម មិនបានឈ្មោះថាធ្វើអំពើបាប គឺថាមិនមែនបានបាប ដូច្នេះជាដើមហៅថាអកិរិយវាទ ១ នេះ សាស្តាឈ្មោះបូរណកស្សប ពោលបញ្ញត្តទុកមក ព្រោះគេជាអកិរិយវាទី អ្នកពោលថាបុគ្គលធ្វើអំពើអាក្រក់មិនបានបាប។

ពាក្យថា: " ហេតុនិងបច្ច័យ ដែលនាំឱ្យសត្វសៅហ្មងមិនមាន, សត្វទាំងឡាយសៅហ្មងឯង១ មិនមានហេតុមិនមានបច្ច័យ, ហេតុនិងបច្ច័យដែលនាំឱ្យសត្វបរិសុទ្ធក៏មិនមាន, សត្វទាំងឡាយបរិសុទ្ធឯង១ មិនមានហេតុមិនមានបច្ច័យ " ដូច្នេះជាដើមហៅថា អហេតុកវាទ ១ នេះ សាស្តាឈ្មោះមក្ខលិគោសាលពោលបញ្ញត្តទុកមក ព្រោះគេជាអហេតុកវាទីយល់ឃើញថាសេចក្តីបរិសុទ្ធសម្រាប់សង្សារ, តែងពោលថាសេចក្តីសៅហ្មង និងសេចក្តីបរិសុទ្ធរបស់សត្វ មិនមានអ្វីជាហេតុ ។

ពាក្យថា:" ទានមិនមានផល, បូជាមិនមានផល" ដូច្នេះជាដើម ហៅថានត្ថិកវាទ ១នេះ សាស្តាឈ្មោះអជិតកេសកម្ពលពោលបញ្ញត្តទុកមកព្រោះគេជានត្ថិកវាទី អ្នកពោលថា " ទានមិនមានផល "ដូច្នេះជាដើម ឬនឹងថា "ឧច្ឆេទវាទី" ដូច្នេះវិញ

ក៏បាន ព្រោះគេតែងពោលនូវឧច្ឆេទវាទថា: " សត្វទាំងឡាយ តែងទំលាយកាយទៅហើយ សូន្យទទេ វិនាសឈឹងទៅ, ខាងនាយ អំពើមរណៈទៅមិនមានអ្វីឡើយ " ។

## **នត្ថិកទិដ្ឋិ, អកិរិយទិដ្ឋិ, អហេតុកទិដ្ឋិ**

វាទ: ទាំង ៣ ដូចពោលមកនេះ ក្នុងអបណ្ណកសូត្រ រៀងនត្ថិកវាទនៅខាងដើម ហើយប្លែងឈ្មោះឱ្យខុសគ្នាបន្តិច ថា "**នត្ថិកទិដ្ឋិ, អកិរិយទិដ្ឋិ, អហេតុកទិដ្ឋិ** ដូច្នេះវិញ ។ ទិដ្ឋិទាំង ៣ នេះ នត្ថិកទិដ្ឋិ ឃាតវិបាក គឺយល់ថាផលរបស់បុណ្យ និងផលរបស់បាបមិនមាន ។ អកិរិយទិដ្ឋិ ឃាតកម្ម គឺយល់ថាបុណ្យនិងបាបមិនមាន ។ អហេតុកទិដ្ឋិ ឃាតទាំងពីរ គឺយល់ថាបុណ្យនិងបាបក៏មិនមាន, ផលរបស់បុណ្យនិងផលរបស់បាបក៏មិនមាន ។

សាស្តាឈ្មោះបូរណកស្សបពោលបញ្ញត្តថា" ធ្វើបាបហៅថាមិនធ្វើ " ឈ្មោះថាឃាតកម្ម ។ សាស្តាឈ្មោះអជិតកេសកម្ពលពោលបញ្ញត្តថា "សត្វទាំងឡាយ តែទំលាយកាយទៅហើយសូន្យលែងកើតទៀត" ឈ្មោះថា ឃាតវិបាក ។ សាស្តាឈ្មោះមក្ខលិគោសាល ពោលបញ្ញត្តថា " សត្វទាំងឡាយ មិនមាន

ហេតុ" ឈ្មោះថាឃាត់ទាំងកម្ម ទាំងវិបាក ។

មានដំណើរសេចក្តីលោកពោលរូបរួមទុកដូច្នេះថា: តែបុគ្គលណាឃាត់កម្ម បុគ្គលនោះបានឈ្មោះថា ឃាត់ទាំងវិបាកផង ព្រោះថាបើកម្មមិនមានហើយ វិបាកក៏នឹងមានមកពីណា ? បុគ្គលណាឃាត់ វិបាកបុគ្គល នោះបានឈ្មោះថាឃាត់ទាំងកម្មផង ព្រោះវិបាករមែងមានមកតែអំពីកម្ម, បើវិបាកមិនមានលុះណាតែកម្មក៏មិនមានដែរ ព្រោះហេតុនោះ វាទៈ ឬ ទិដ្ឋិទាំង ៣ នុ៎ះ បានឈ្មោះថាឃាត់ទាំងកម្ម ទាំងវិបាកដូចគ្នា ។

## និយតមិច្ឆាទិដ្ឋិ[១]

សាស្តាអ្នកប្រដៅនូវទិដ្ឋិទាំង ៣ នុ៎ះបើមានបុគ្គលណាជឿតាមកាន់តាម ហើយអង្គុយស្វាធ្យាយស្ទឹងស្ទាធតាមក្បួនតម្រាដែលសំដែងអំពីទិដ្ឋិទាំងនុ៎ះសព្វទិវារាត្រី,ពិចារណាសេចក្តីឱ្យសព្វគ្រប់ទៅ មិច្ឆាសតិ សេចក្តីរលឹកខុស នឹងដំកល់នៅស៊ប់ក្នុងអារម្មណ៍ដែលថា "អ្នកធ្វើបាប ហៅថាមិនធ្វើ. ហេតុនិងបច្ច័យមិនមាន. សត្វស្លាប់ទៅសូន្យមិនកើតទៀត" នោះ ហើយចិត្តក៏តំកល់នៅនឹងក្នុងអារម្មណ៍តែ ១ ជាមច្ឆាសមាធិ ហាក់ដូចជាដល់នូវអប្បនា. លំដាប់នោះជវន

---

១- សេចក្តីយល់ខុសទៀងលែងប្រែប្រួល

ទាំងឡាយក៏ប្រព្រឹត្តទៅ ។ ក្នុងថ្នាក់ជវន ទី ១, ទី ២, ដល់ទី ៦ បុគ្គលនោះនៅកែបាននៅឡើយ តែដល់ថ្នាក់ជវនទី ៧ ហើយ កុំថាឡើយមនុស្សធម្មតា សូម្បីតែព្រះពុទ្ធរាប់រយ រាប់ពាន់ព្រះអង្គ ក៏រកកែបុគ្គលនោះឱ្យរបើកមិនបានឡើយ ព្រោះដល់ថ្នាក់ជានិយតមិច្ឆាទិដ្ឋិហើយ។

មែនពិត មិច្ឆាទិដ្ឋិ ទាំង ៣ នេះ បើសត្វណាមួយចុះចិត្តស៊ប់តែក្នុងមិច្ឆាទិដ្ឋិ ១ ក្តី, ២ ក្តី, ទាំង ៣ ក្តី ក៏បានឈ្មោះថាជាអ្នកប្រកបដោយនិយតមិច្ឆាទិដ្ឋិដូចគ្នា, ជាអ្នកដល់ថ្នាក់ទោសដែលរាំងផ្លូវសួគ៌ និងផ្លូវព្រះនិព្វាន មិនគួរនឹងទៅកាន់ស្ថានសួគ៌ក្នុងអត្តភាពជាបន្ទាប់បាន កុំថាដល់ទៅព្រះនិព្វាន ។ សត្វនោះឈ្មោះថាជាដង្កត់ឬជាចរឹងរបស់វដ្ដៈ, ឈ្មោះថាជាគម្របផែនដី មិនងាយនឹងចេញរួចអំពីភពទៅបានឡើយ ។

សួរថាៈ សត្វដែលប្រកាន់មិច្ឆាទិដ្ឋិទៀងបែបនេះ តើទៀងតែក្នុងអត្តភាពនេះ ១ ប៉ុណ្ណោះទេ ឬក្នុងអត្តភាពដទៃទៅនឹងទៀងទៀតដែរ ។

តបថា សត្វនោះឯងប្រកាន់ទៀងតែក្នុងអត្តភាពនេះទេ តែដល់ទៅក្នុងអត្តភាពដទៃៗ ទៅ ច្រើនពេញចិត្តនឹងទិដ្ឋិបែបនេះ

ទៀត ព្រោះធ្លាប់សេពមកដោយច្រើនហើយ. កាលបើដូច្នេះមុខជានឹងធ្លាក់ចុះកាន់ទិដ្ឋិ បែបនេះទៀតជារឿយៗ ព្រោះហេតុនោះទើបលោកពោលថា សត្វនោះមិនងាយនឹង ចេញរួចអំពីភពទៅបានឡើយ ។

## ទោសរបស់មិច្ឆាទិដ្ឋិ

មិច្ឆាទិដ្ឋិទាំង ៣ នុ៎ះ បើដល់ថ្នាក់ជានិយតៈទៀងលែង ប្រែប្រួលដូច ពោលមកយ៉ាងនេះហើយ ត្រូវជ្រាបថា មានទោសច្រើនជាងអនន្តរិយកម្ម[១] ទៅទៀត ។ ព្រះមានជោគទ្រង់ត្រាស់ទុកក្នុងគម្ពីរអង្គុត្តរនិកាយឯកនិបាត ថាៈ ព្រះអង្គទ្រង់ស្រាវជ្រាវរកអំពើដែលមានទោសច្រើន ដូចមិច្ឆាទិដ្ឋិ មិនឃើញមានសោះឡើយ. មានតែមិច្ឆាទិដ្ឋិនេះឯងហើយ ដែលមានទោសច្រើនជាងគេបំផុត ។ ព្រះពុទ្ធតម្រាស់នេះពិតមែន អនន្តរិយកម្មទាំង ៥ ចាត់ថាជាអំពើមានទោសច្រើនហើយ តែមិច្ឆាទិដ្ឋិទោសច្រើនជាងនោះទៅទៀត. ព្រោះហេតុអ្វី ? ព្រោះថាទោសរបស់អនន្តរិយកម្មទាំង ៥ នោះនៅមានកំណត់. តួយ៉ាងដូចអនន្តរិយកម្ម ៤ ខាងដើម លោកគ្រាន់តែពោល

---

១-កម្មដែលបុគ្គលអ្នកធ្វើត្រូវទទួលសោយផលក្នុងជាតិជាបន្ទាប់ ហៅថា អនន្តរិយកម្ម មាន ៥ គឺ សម្លាប់មាតាបង្កើត១. សម្លាប់បិតាបង្កើត ១. សម្លាប់ព្រះអរហន្ត ១. ញុំាងឈាមឱ្យពុះពងឡើងក្នុង កាយរបស់ព្រះពុទ្ធ ១. បំបែកសង្ឃដែលកំពុងព្រមព្រៀងឱ្យបែកចាកគ្នា ១ ។

ថា "ញុំាងអ្នកធ្វើឱ្យកើតក្នុងនរក "ប៉ុណ្ណោះ, ឯសង្ឃភេទកម្មជាគំរប់ ៥ លោកពោលថា "ញុំាងអ្នកធ្វើឱ្យតាំងក្នុងនរកអស់កប្ប" ដូច្នេះ ឃើញថាទោសរបស់អនន្តរិយកម្មមានកំណត់, នៅមានទីបំផុតប្រាកដនៅឡើយ, ឯទោសរបស់និយតមិច្ឆាទិដ្ឋិរកកំណត់មិនបានឡើយ ហេតុនោះទើបលោកពោលថា; សត្វដែលប្រកបដោយមិច្ឆា-ទិដ្ឋិទាំងនុ៎ះ ចាត់ថាជាមូលរបស់វដ្តៈ នឹងរកច្រកចេញអំពីភពមិនរួចឡើយ ។ បើជនទាំងឡាយឯណាសំគាល់នូវពាក្យរបស់បុគ្គលដែលប្រកបដោយមិច្ឆាទិដ្ឋិ ថាជាពាក្យត្រឹមត្រូវគួរស្តាប់ហើយ ជនទាំងឡាយនោះ មុខជាបុគ្គលដែលប្រកបដោយមិច្ឆាទិដ្ឋិទាំងនោះនឹងដឹកនាំឱ្យប្រតិបត្តិខុសតាមខ្លួនមិនខានឡើយ ។

ពុទ្ធោអើយ គួរអនិច្ចាពេក ! ធម្មតាបុគ្គលដែលប្រកបដោយមិច្ឆាទិដ្ឋិយ៉ាងនេះ មិនមានស្ថានសួគ៌និងអរិយមគ្គ គ្រាន់ជាទីសង្ឃឹមឡើយ ។ ក្នុងគ្រាដែលកប្បវិនាស[១] អស់ទាំងមហាជនគេទៅកើតក្នុងស្ថានព្រហ្មលោកទាំងអស់គ្នា, ឯបុគ្គលដែលប្រកបដោយនិយត-មិច្ឆាទិដ្ឋិ មិនបានទៅកើតក្នុងទីនោះនឹងគេឡើយ, បែរជាទៅឆេះ

---

១-វេលាដែលលោកធាតុវិនាសទៅ ដោយភ្លើងឆេះ, ទឹកលិច, ខ្យល់បោក ។

នៅក្នុងលោកន្តរិកនរក[១] ជាចន្លោះនៃចក្កវាឡ[២] ត្រង់ដែលភ្លើងប្រឡែកប្បឆេះមិនដល់នោះទៅវិញដោយកម្លាំងកម្មរបស់ខ្លួន ។ មិនត្រឹមតែប៉ុណ្ណោះឡើយ បុគ្គលដែលប្រកបដោយនិយតមិច្ឆាទិដ្ឋិរមែងតែធ្វើនូវសេចក្ដីអន្តរាយដល់អ្នកដែលទៅសេពគប់ផងទៀត ព្រោះហេតុនោះអ្នកដែលប្រាថ្នានូវសេចក្ដីចំរើន ត្រូវតែចៀសវាងបុគ្គលបែបនោះឱ្យឆ្ងាយឱ្យដូចជាគេចៀសវាងសត្វអាសិរពិសដូច្នោះឯង ។

ក្នុងខាងដើមបានពោលមកហើយថា: កម្មបថដែលនឹងបែកធ្លាយនោះ តែដោយមិច្ឆាទិដ្ឋិទាំង ៣ នេះឯង មិនបានបែកធ្លាយដោយមិច្ឆាទិដ្ឋិឯទៀតៗឡើយ តែទុកណាជាដូច្នោះ ក៏មិនត្រូវប្រកាន់មិច្ឆាទិដ្ឋិណាមួយឱ្យសោះ ព្រោះឱ្យតែហៅថាមិច្ឆាទិដ្ឋិ សុទ្ធតែជាធម៌នាំទៅកាន់អបាយទាំងអស់ទោះបីទោសធ្ងន់ ឬ ស្រាលយ៉ាងណាក្ដី ។ ព្រះមានព្រះភាគទ្រង់ត្រាស់ទុកក្នុងគម្ពីរអង្គុត្តរនិកាយឯកនិបាតថា: ព្រះអង្គទ្រង់ស្រាវជ្រាវរកធម៌ដែលដឹកនាំសត្វឱ្យទៅកាន់អបាយ, ទុគ្គតិ, វិនិបាត, នរក ឱ្យបានដូចជាមិច្ឆាទិដ្ឋិមិនឃើញមានសោះឡើយ ។ មានវិធីឯទៀតសំដែងថា: មិច្ឆាទិដ្ឋិពួកខ្លះ រាំងទាំង

---

១-នរកតាំងនៅត្រង់ចន្លោះលោកធាតុប្រជុំបគ្គា ។ ២-ចក្កវាឡ ប្រែថារបៀបកង់ ឬ កន្ទុយកង់ សេចក្ដីថា លោកធាតុតម្រៀបគ្នាដូចជាគេផ្ដេកកង់ប្រទល់ៗ គ្នា ត្រង់ចន្លោះៗជាលោកន្តរិកនរក

ស្ថានសួគ៌, រាំងទាំងមគ្គ ដូចអហេតុកទិដ្ឋិ, អកិរិយទិដ្ឋិ និងនត្ថិកទិដ្ឋិ ដែលកំពុងពោលមកនេះ, មិច្ឆាទិដ្ឋិពួកខ្លះ រាំងតែមគ្គ មិនរាំងស្ថានសួគ៌ ដូចអន្តគ្គាហិកា មិច្ឆាទិដ្ឋិ ដែលមានវត្ថុសម្រាប់បញ្ញត្ត ១០[(១)] ; មិច្ឆាទិដ្ឋិពួកខ្លះ ស្ថានសួគ៌ក៏មិនរាំង មគ្គក៏មិនរាំង ដូចសក្កាយទិដ្ឋិ ដែលមានវត្ថុសម្រាប់បញ្ញត្ត២០[(២)] ;តែទុកណាជាដូច្នោះ ក៏មិនឃើញបានសំដែងថា មិច្ឆាទិដ្ឋិណា ១ ដែលអាចនាំសត្វទៅកើតក្នុងស្ថានសួគ៌បាន, មានតែនាំសត្វឱ្យជ្រមុជចុះទៅកើតក្នុងស្ថាននរកតែប៉ុណ្ណោះ, ប្រៀបដូចថ្មនិងគ្រួស ដែលបុគ្គលដាក់ចុះទៅក្នុងទឹក មិនដែលអណ្តែតនៅលើទឹកឡើយ មានតែលិចចុះទៅខាងក្រោមជាដរាប ព្រោះហេតុនោះត្រូវតែកុំប្រកាន់មិច្ឆាទិដ្ឋិណាមួយឱ្យសោះ បើអាណិតខ្លួន ។

អកិរិយវាទាទិកថា ចប់

# បាណាតិបាតាទិអារម្មណកថា

លំដាប់នេះនឹងពោលអំពីអារម្មណ៍ របស់បាណាតិបាតជាដើមតទៅ ។ ក្នុងកថានេះ លោកសំដែងទុកថាៈ បាណាតិបាត មានជីវិតិ

---

១-មិច្ឆាទិដ្ឋិ ដែលប្រកាន់តែត្រង់ទីបំផុតថាទៀងនិងមិនទៀងជាដើម មានវត្ថុសម្រាប់បញ្ញត្ត ១០ មាន "សស្សតោ លោកោជាដើម" ។ ២-មិច្ឆាទិដ្ឋិ ដែលប្រកាន់ខុសក្នុងបញ្ចក្ខន្ធ ដែលហៅថាសក្កាយ មានវត្ថុសម្រាប់បញ្ញត្ត ២០ មាន "រូបំ អត្តោ សមនុបស្សតិ"ជាដើម ។

ឥន្ទ្រិយគឺជីវិតរបស់សត្វដែលត្រូវគេសម្លាប់ជាអារម្មណ៍ ។អទិន្នាទាន ១. អព្រហ្មចរិយៈ(១) ១. សុរាមេរិយមជ្ជប្បមាទដ្ឋានៈ ១ មានសង្ខារណាមួយ ក្នុងពួករូបធម៌មានរូបាយតនៈជាដើមជាអារម្មណ៍ ។ មុសាវាទ មានសត្វជាអារម្មណ៍ ព្រោះអ្នកពោលនូវពាក្យកុហកប្រុងពោលចំពោះបុគ្គលណា មុសាវាទប្រារព្ធនូវបុគ្គលនោះហើយទើបប្រព្រឹត្តទៅបាន ។ អទិន្នាទាន លោកអង្គខ្លះកែថាៈ កាលណាបើបុគ្គលលួចយកនូវសត្វ បែរជាមានសត្វជាអារម្មណ៍វិញ ។អព្រហ្មចរិយៈ ក៏មានលោកអង្គខ្លះកែថា មានសត្វជាអារម្មណ៍ដែរ ន័យដែលពោលមកនេះ គឺពោលតាមវិធីបញ្ចទ្វារ (ទៀវ៥) នៅមានន័យខាងចុងទៀត លោកពោលត្រង់ទៅតាមវិធីរបស់អកុសលកម្មបថទាំង ១០ ដែលពោលមកជាលំដាប់ តែមានសេចក្ដីប្លែកគ្នាដោយអន្លើ ៗ តាមលំអានដែលលោកនាំមកអំពីគម្ពីរផ្សេងៗគ្នាដូចនឹងពោលតទៅនេះ។ ក៏ក្នុងន័យនុ៎ះលោកពោលថាៈ បាណាតិបាត មានសង្ខារជាអារម្មណ៍ ព្រោះបាណាតិបាតនេះ ប្រារព្ធយកជីវិតិន្ទ្រិយដែលជាតួសង្ខារមកជាអារម្មណ៍។ អទិន្នាទាន មានសត្វជាអារម្មណ៍ខ្លះ មានសង្ខារជាអារម្មណ៍ខ្លះ ។ កាមេសុមិច្ឆាចារ មានសង្ខារ គឺផ្សព្វជាអារម្មណ៍ តែមាន

១ កាមេសុ មិច្ឆាចា ក៏ដូចគ្នា ។

លោកអង្គខ្លះកែថា មានសត្វជាអារម្មណ៍ ។ មុសាវាទ និងបិសុណាវាចា មានសត្វជាអារម្មណ៍ខ្លះ, មានសង្ខារជាអារម្មណ៍ខ្លះ។ ផរុសវាចា មានសត្វជាអារម្មណ៍ ។ សម្ផប្បលាបៈ មានសត្វជាអារម្មណ៍ខ្លះ, មានសង្ខារជាអារម្មណ៍ខ្លះ តាមអារម្មណ៍ដែលបុគ្គលបានឃើញ, បានឮ, បានហិត, បានស្រូប, បានប៉ះ និងបានដឹងមក[១] ។ អភិជ្ឈាក៏ដូចសម្ផប្បលាបៈដែរ ។ព្យាបាទ មានសត្វជាអារម្មណ៍តែមួយមុខ ។ មិច្ឆាទិដ្ឋិ កាលបើយល់ឃើញថា "សត្វដែលស្លាប់ហើយមិនកើតទៀត"ដូច្នេះជាដើម ចាត់ថា មានតេភូមិកធម៌ គឺធម៌ដែលប្រព្រឹត្តទៅក្នុងភូមិ ៣[២] ជាអារម្មណ៍ ឬ នឹងថាមានសង្ខារជាអារម្មណ៍ដូច្នេះវិញក៏បាន, សូម្បីមិច្ឆាទិដ្ឋិ ដែលប្រព្រឹត្តទៅតាមទំនងឯទៀតៗ ក្រៅពីនេះ ក៏មានសង្ខារអារម្មណ៍ដូចគ្នា ។ ក្នុងកថានេះឃើញថាមានសេចក្តីចង្អៀតលំបាកយល់បន្តិច តែបើនឹងអធិប្បាយឱ្យពិស្តារតទៅឱកាសមិនល្មម ហេតុនោះសូមសង្ស៊ឹមដល់ការស្តាប់ និងការសាកសួររបស់លោកអ្នកត្រូវការតទៅទៀតចុះ ។

## បាណាតិបាតាទិអារម្មណកថាចប់

## អកុសលកម្មបថកថាចប់

---

១-សំដៅរូបារម្មណ៍, សទ្ទារម្មណ៍, គន្ធារម្មណ៍, រសារម្មណ៍, ផោដ្ឋព្វារម្មណ៍និងធម្មារម្មណ៍ ។

២-កាមាវចរភូមិ ១, រូបាវចរភូមិ ១, អរូបាវចរភូមិ ១ ។

# កុសលកម្មបថកថា

លំដាប់នេះនឹងពណ៌នាអំពីកុសលកម្មបថតទៅទៀត ។ ក៏កុសលកម្មបថនេះ បើពោលរួបរួមតាមសេចក្ដី សំដៅយកការវៀរចាកអកុសលកម្មបថទាំង ១០ ដូចបានអធិប្បាយមកហើយក្នុងខាងដើមនោះឯង តែបើពោលតាមប្រភេទនៃអំពើដែលត្រូវវៀរ ឬចេតនាដែលវៀរមាន ១០ គឺៈ

**១-បាណាតិបាតា វេរមណី** ចេតនាជាហេតុវៀរចាកកិរិយាញុំាងសត្វមានជីវិតឱ្យធ្លាក់ចុះកន្លង ឬឱ្យធ្លាក់ចុះឆាប់ គឺវៀរលែងសម្លាប់សត្វ ។

**២-អទិន្នាទានា វេរមណី** ចេតនាជាហេតុវៀរចាកកិរិយាកាន់យកនូវទ្រព្យដែលម្ចាស់គេមិនបានឱ្យដោយកាយ ឬដោយវាចា ។

**៣-កាមេសុ មិច្ឆាចារា វេរមណី** ចេតនាជាហេតុវៀរចាកកិរិយាប្រព្រឹត្តក្នុងកាមទាំងឡាយ ។

**៤-មុសាវាទា វេរមណី** ចេតនាជាហេតុវៀរចាកកិរិយាពោលនូវពាក្យកុហក ។

**៥-បិសុណាវាចា វេរមណី** ចេតនាជាហេតុវៀរចាកកិរិយាពោលនូវពាក្យញុះញង់ ។

**៦-ផរុសាវាចា វេរមណី** ចេតនាជាហេតុវៀរចាកកិរិយាពោលនូវពាក្យត្រគោះ ។

**៧-សម្ផប្បលាបា វេរមណី** ចេតនាជាហេតុវៀរចាកកិរិយាពោលនូវពាក្យប្រឌិតឥតមូលហេតុ ។

**៨-អនភិជ្ឈា** ធម្មជាតិមិនសំឡឹងរំពៃរកទ្រព្យនៃបុគ្គលដទៃ គឺសេចក្តីមិនលោភបែរឈមទៅរកទ្រព្យនៃបុគ្គលដទៃ ។

**៩-អព្យាបាទៈ** សភាពមិនញ៉ាំងប្រយោជន៍និងសេចក្តីសុខនៃបុគ្គលដទៃឱ្យធ្លាក់ចុះ គឺសេចក្តីមិនគុំគួនចង់ធ្វើប្រយោជន៍និងសេចក្តីសុខដែលបុគ្គលដទៃបាន ឱ្យវិនាស ។

**១០-សម្មាទិដ្ឋិ** ធម្មជាតិឃើញត្រូវ គឺសេចក្តីយល់ត្រូវតាមសភាពដែលពិតមែន ។

## កម្ម-ទ្វារ

កុសលកម្មបថទាំង ១០ នេះ លោកចាត់ទុកជា ៣ ពួកដូចអកុសលកម្មបថដែរ គឺ ចេតនាជាហេតុវៀរចាកអំពើដែលគួរធ្វើបានដោយកាយ ហៅថាកាយកម្ម ជាពួក ១, ចេតនាជាហេតុវៀរចាក

ដែលគួរធ្វើបានដោយវាចា ហៅថា វិចីកម្ម ជាពួក ១, ចេតនាជាហេតុ វៀរចាកអំពើដែលគួរធ្វើបានដោយចិត្ត ហៅថាមនោកម្ម ជាពួក ១ ។

ក្នុងកុសលកម្មបថទាំង ១០ នុ៎ះ បាណាតិបាតា វេរមណី ១, អទិន្នាទានា វេរមណី ១, កាមេសុ មិច្ឆាចារា វេរមណី ១, ទាំង ៣ នេះចាត់ទុកជាកាយកម្ម ។ មុសាវាទា វេរមណី ១, បិសុណាយ វាចាយ វេរមណី ១, ផរុសាយ វាចាយ វេរមណី ១, សម្ផប្បលាបា វេរមណី ១, ទាំង ៤ នេះចាត់ទុកជា វចីកម្ម ។ អនភិជ្ឈា ១, អព្យាបាទោ ១, សម្មាទិដ្ឋិ ១, ទាំង ៣ នេះ ចាត់ទុកជាមនោកម្ម ។

មែនពិត កុសលកម្មបថទាំង ១០ នុ៎ះ សុទ្ធតែប្រព្រឹត្តទៅបានគ្រប់ទ្វារទាំង ៣ ដូចគ្នា គឺប្រព្រឹត្តទៅបានទាំងក្នុងកាយទ្វារ,វចីទ្វារ, មនោទ្វារ មិនមានលោះទ្វារណាមួយ ដូចអកុសលកម្មបថឡើយ ។ សេចក្ដីថា: សិក្ខាបទ ៣ ក្នុងពួកកាយកម្មគឺ: **បាណាតិបាតា បដិវិរមាមិ**=ខ្ញុំវៀរចាកបាណាតិបាតា ១, **អទិន្នាទានា បដិវិរមាមិ**=ខ្ញុំវៀរចាកអទិន្នាទា ១, **កាមេសុ មិច្ឆាចារា បដិវិរមាមិ**=ខ្ញុំវៀរចាក កាមេសុ មិច្ឆាចារ ១, បើបុគ្គលមិនបានបញ្ចេញវចីភេទ គ្រាន់តែទទួលដោយលំនាំដៃទទេ មានវាសដៃ និង សរសេរ

សំបុត្រជាដើម. អំពើដែលបុគ្គលធ្វើទាំងនោះចាត់ជា កាយកម្ម. ឯទ្វារដែលធ្វើចាត់ជា កាយទ្វារ; បើបុគ្គលបានបញ្ចេញវចីភេទទទួល. អំពើដែលបុគ្គលធ្វើទាំងនោះ ចាត់ជា កាយកម្ម. ឯទ្វារដែលធ្វើចាត់ជាវចីទ្វារ; បើបុគ្គលមិនបានញុំាងកាយ ឬវាចាឱ្យកំរើកសោះ គ្រាន់តែទទួលដោយចិត្ត គឺគ្រាន់តែតាំងចិត្តទទួលតែប៉ុណ្ណោះ. អំពើដែលបុគ្គលធ្វើទាំងនោះ ចាត់ជា កាយកម្មដូចគ្នា. តែឯទ្វារដែលធ្វើ ចាត់ជាមនោទ្វារ ។ សិក្ខាបទ ៤ ក្នុងពួកវចីកម្ម មាន "**មុសាវាទា បដិវិរមាមិ**=ខ្ញុំវៀរចាកមុសាវាទ"ជាដើម. មាន "**សម្ផប្បលាបា បដិវិរមាមិ**=ខ្ញុំវៀរចាកសម្ផប្បលាប;"ជាទីបំផុត ក៏មានវិធីចែកដូចគ្នា. ប្លែកគ្នាខ្លះតែត្រង់អំពើដែលធ្វើ ចាត់ជា វចីកម្មប៉ុណ្ណោះ ក្រៅអំពីនោះដូចគ្នាទាំងអស់[(១)] ។ កាយកម្ម និងវចីកម្មជាកុសលតាំងឡើងក្នុងទ្វារទាំង ៣ យ៉ាងនេះឯង[(២)] ។

**ឯអនភិជ្ឈា, អព្យាបាទ** និងសម្មាទិដ្ឋិដែលកើតរួមជាមួយ

---

១-កុសលកម្មបថខាងដើមនេះ ក្នុងគម្ពីរវិសុទ្ធិមគ្គ ហៅថា អាទិព្រហ្មចរិយកសីល គឺសីលជាខាងដើមនៃមគ្គព្រហ្មចរិយៈផង. ហៅថា ចេតនាសីលផង បើថែមអាជីវបារិសុទ្ធិ ១ មកទៀត ហៅថា អាជីវមគ្គកសីល គឺសីលមានអាជីវៈជាគំរប់ ៨ ។ (២)-តាមន័យនេះ កម្មបថទាំង ១០. ឃើញថាត្រូវមានវិធីទទួលដូចនិច្ចសីលនិងឧបោសថសីលដែរ តែដូចជាពុំទាន់ឃើញមានលោកអ្នកអ្នកប្រាជ្ញអង្គណារៀបរៀងទុកនៅឡើយ ។

នឹងចិត្តទាំងនោះ, ខ្លះជាចេតនាបក្ខិកា ប្រព្រឹត្តទៅក្នុងពួកនៃចេតនា ដែលប្រព្រឹត្តទៅក្នុងកាយទ្វារ ឬវចីទ្វារ ជាសត្រូវដល់បាណាតិជា ដើម, ខ្លះជា អព្វោហារិកា មិនមែនជាអង្គរបស់បញ្ញត្តិ គឺមិនគួរ ពោលថាជា បាណាតិបាតវិរតិ[១] ជាដើម ។ ក្នុងពួកមនោកម្ម បើ បុគ្គលមានចិត្តប្រកបដោយ អនភិជ្ឈា, អព្យាបាទ និងសម្មាទិដ្ឋិ ញ៉ាំងកាយឱ្យកំរើក ធ្វើនូវកុសលកម្ម មានទោសសំអាតនូវលានព្រះ ចេតិយ និងបូជាព្រះចេតិយដោយគ្រឿងក្រអូបនិងផ្កាកម្រងជាដើម ឬថ្វាយបង្គំនូវព្រះចេតិយជាដើម, អំពើដែលបុគ្គលធ្វើទាំងនោះ ចាត់ជាមនោកម្ម, ឯទ្វារដែលធ្វើ ចាត់ជា កាយទ្វារ ។ បើបុគ្គលមាន ចិត្តប្រកបដោយអនភិជ្ឈា ញ៉ាំងវាចាឱ្យកំរើកថា "វត្ថុឯណាជា ឧបករណ៍របស់សម្បត្តិនៃបុគ្គលដទៃ វត្ថុនោះកុំគប្បីបានជារបស់អញ ឡើយ", មានចិត្តប្រកបដោយ អព្យាបាទ ញ៉ាំងវាចាឱ្យកំរើកថា

---

១-ចេតនាវៀរចាក បាណាតិបាត ។ វិរតិមាន ៣ គឺៈ សម្បត្តិវិរតិ ចេតនាវៀរចាកវត្ថុដែលគួរ ប្រព្រឹត្តកន្លងតាមតែប្រទះ ជាវិរតិរបស់បុគ្គលដែលមិនបានសមាទាន ១, សមាទានវិរតិ ចេតនា វៀរចាកវត្ថុដែលគួរប្រព្រឹត្តកន្លងដោយអំណាចសមាទាន ជាវិរតិរបស់បុគ្គលដែលបានសមាទាន ១, សេតុឃាតវិរតិ ចេតនាសម្លាប់នូវបាបធម៌ដោយស្ពានគឺអរិយមគ្គ ១, វិរតិនេះ ក្នុងទីខ្លះ ហៅ ថាសមុច្ឆេទវិរតិ ចេតនាវៀរចាកអំពើអាក្រក់ដោយអំណាចនៃកិរិយាកាត់ផ្តាច់នូវបាបធម៌, ។ វិរតិ ២ ខាងដើមជាលោកិយ, វិរតិ ១ ខាងចុងជាលោកុត្តរៈ ។

"សព្វសត្វទាំងអស់ចូរកុំឱ្យមានពៀរ, កុំឱ្យមានជម្ងឺតម្កាត់, កុំឱ្យមានទុក្ខ, ចូររក្សាខ្លួនឱ្យបានសុខចុះ", មានចិត្តប្រកបដោយសម្មាទិដ្ឋិញុំាងវាចាឱ្យកំរើកថា "ទានដែលបុគ្គលឱ្យហើយនឹងមានផល" ដូច្នេះជាដើម អំពើដែលបុគ្គលធ្វើទាំងនោះ ចាត់ជាមនោកម្ម, ឯទ្វារដែលធ្វើ ចាត់ជាវចីទ្វារ ។ មនោកម្ម ជាកុសលតាំងឡើងក្នុងកាយទ្វារ និងវចីទ្វារ មានទំនងយ៉ាងនេះ។ ឯចេតនាដែលតាំងឡើងក្នុងកាយទ្វារនិងវចីទ្វារទាំងនេះជា អព្វោហារិកា មិនមែនជាអង្គរបស់បញ្ញត្តិ គឺមិនគួរពោលថាជា កាយកម្ម ឬវចីកម្មបាន ព្រោះមានអនភិជ្ឈាជាដើមជាប្រធាន។ បើបុគ្គលមិនបានញុំាងកាយនិងវាចាឱ្យកំរើកសោះគ្រាន់តែអង្គុយនៅក្នុងទីស្ងាត់ ញុំាងចិត្ត ដែលប្រកបដោយអនភិជ្ឈាជាដើមឱ្យកើតឡើងតែដោយចិត្តប៉ុណ្ណោះ, អំពើដែលបុគ្គលធ្វើទាំងនោះ ចាត់ជាមនោកម្ម, ឯទ្វារដែលធ្វើ ក៏ចាត់ជាមនោទ្វារដែរ ។ មនោកម្មជាកុសលតាំងឡើងក្នុងមនោទ្វារ មានទំនងយ៉ាងនេះឯង។ ក្នុងទីនេះ ទាំងចេតនាទាំងអនភិជ្ឈាជាដើមដែលសម្បយុត្តដោយចេតនា តាំងឡើងព្រមក្នុងមនោទ្វារទាំងអស់ ។ ក្នុងមនោទ្វារនេះសំដៅយកតួចេតនានោះឯង ដែលហៅថា មនោកម្ម ។

កុសលកម្មបថកថា ចប់

# អាទីនវានិសំសកថា

ទីបំផុតនេះ នឹងពណ៌នានូវទោសនៃអកុសលកម្មបថ និង អានិសង្សនៃកុសលកម្មបថ ដោយសេចក្តីសង្ខេបតទៅ ។

ក៏ក្នុងអកុសលកម្មបថ និងកុសលកម្មបថ ទាំងគូនេះ អកុសលកម្មបថត្រូវឱ្យវៀរ, ឯកុសលកម្មបថ ត្រូវឱ្យប្រព្រឹត្ត មានន័យលោកពោលរួបរួមថា: បើបុគ្គលវៀរចាកតែអកុសល-កម្មបថ ក៏បានឈ្មោះថាប្រព្រឹត្តនូវកុសលកម្មបថផង ឬ បព្រឹត្ត តែកុសលកម្មបថ ក៏បានឈ្មោះថា វៀរចាកអកុសលកម្មបថផង ព្រោះអំពើទាំង ២ នេះ ជាបដិបក្ខដល់គ្នានឹងគ្នា ។ អកុសលកម្ម-បថ ជូនណា លោកហៅថា ទុច្ចរិត.ឯកុសលកម្មបថ ហៅថាសុចរិត។ ទុច្ចរិត ជាអំពើមិនត្រូវឱ្យប្រព្រឹត្តធ្វើ, កាលបើបុគ្គលប្រព្រឹត្តធ្វើនឹង ត្រូវមានទោស ៥ ប្រការដូច្នេះគឺ:

**១.អត្តាបិ អត្តានំ ឧបវទតិ** ខ្លួនឯងនឹងតិះដៀលខ្លួនឯងបាន(១) ។

**២.អនុវិច្ច វិញ្ញូ គរហន្តិ** វិញ្ញូជន(១) ទាំងឡាយពិនិត្យទៅឃើញ លោកតិះដៀលបាន ។

**៣.បាបកោ កិត្តិសទ្ទោ អព្ភុគ្គច្ឆតិ** កិត្តិសព្ទដ៏លាមក

នឹងវន្ទីសុះសាយទៅ ។

**៤-សម្មូឡ្ហោ កាលំ ករោតិ** រមែងវង្វេងវង្វាន់ ក្នុងវេលាធ្វើមរណកាល ។

**៥-អបាយំ ទុគ្គតឹ វិនិបាតំ និរយំ ឧបបជ្ជតិ** ដល់ទំលាយកាយទៅ នឹងទៅកាន់អបាយ, ទុគ្គតិ, វិនិបាត, នរក ។

សុចរិត ជាអំពើត្រូវឱ្យប្រព្រឹត្តធ្វើ, កាលបើបុគ្គលប្រព្រឹត្តធ្វើតាមនឹងត្រូវបានអានិសង្ស ៥ ប្រការដូច្នេះគឺ :

**១-អត្តាបិ អត្តានំ ន ឧបវទតិ** ខ្លួនឯងនឹងតិះដៀលខ្លួនឯងមិនបាន ។

**២-អនុវិច្ច វិញ្ញូ បសំសន្តិ** វិញ្ញូជនទាំងឡាយពិនិត្យទៅឃើញ លោករមែងស្ញើចសរសើរ ។

**៣-កល្យាណោ កិត្តិសទ្ទោ អព្ភុគ្គច្ឆតិ** កិត្តិសព្ទដ៏ល្អនឹងវន្ទីសុះសាយទៅ ។

**៤-អសម្មូឡ្ហោ កាលំ ករោតិ** រមែងមិនវង្វេងវង្វាន់ក្នុងវេលាធ្វើមរណកាល ។

---

១-សំដៅយកវិប្បដិសារៈ សេចក្តីក្តៅក្រហាយចិត្តខ្លួនឯង ។២-អ្នកប្រាជ្ញ ។

**៥-សុគតឹ សគ្គំ លោកំ ឧបបជ្ជតិ** ដល់ទំលាយកាយទៅ រមែងទៅកាន់សុគតិ សគ្គលោក ។

សាធុជន អ្នកប្រាថ្នានូវសេចក្ដីសុខចំរើនចំពោះខ្លួន កាលបើបានឃើញនូវទោសរបស់អកុសលកម្មបថ និងអានិសង្សរបស់កុសលកម្មបថ ដូចបានពោលមកដោយសង្ខេបនេះហើយ ក៏គួរតែខំរំលៀកខ្លួនវៀរចាកអកុសលកម្មបថ ហើយរំកិលខ្លួនឱ្យបានប្រព្រឹត្តនូវកុសលកម្មបថ ដើម្បីនឹងញុំាងសេចក្ដីប្រាថ្នារបស់ខ្លួននោះឱ្យបានសម្រេចចុះ ។

អាទីនវានិសំសកថា ចប់

អាគារិយវិន័យ ចប់តែប៉ុណ្ណេះ

# អារម្ភកថា

ពួកក្រុមនីមួយៗ ដែលនឹងមានរបៀបរាបរយល្អ លុះតែតែមានច្បាប់សម្រាប់ហ្វឹក បើមិនដូច្នោះទេ នឹងធ្វើក្រុមនោះឱ្យមានរបៀបរាបរយល្អមិនបានឡើយ ។

វិន័យជាច្បាប់សម្រាប់ហ្វឹកក្រុមអ្នកកាន់ព្រះពុទ្ធសាសនា ។

មែនពិត ព្រះពុទ្ធសាសនា បានជាល្បីថាបរិសុទ្ធមានរបៀបរាបរយគួរជ្រះថ្លាជាងសាសនាឯទៀតៗ ព្រោះសម្បូរច្បាប់សម្រាប់ហ្វឹកពួកជនអ្នកកាន់ ហើយវិសេសជាងច្បាប់សាសនាឯទៀតៗផង ដោយបុគ្គលជាម្ចាស់សាសនា និងជាមេបញ្ញត្តច្បាប់ គឺតួអង្គព្រះសម្មាសម្ពុទ្ធ ដែលជាបុគ្គលវិសេសផុតក្នុងលោក រកបុគ្គលណាប្រៀបផ្ទឹមពុំបាន ។

វិន័យ ដែលព្រះសម្មាសម្ពុទ្ធទ្រង់បញ្ញត្តនោះមាន ២ ផ្នែក តាមសមគួរដល់ភេទរបស់ជនអ្នកកាន់សាសនារបស់ព្រះអង្គ គឺ អាគារិយវិន័យ សម្រាប់ពួកគ្រហស្ថ ១ អនាគារិយវិន័យ សម្រាប់ពួកបព្វជិត ១ ។

បណ្ដាវិន័យទាំង ២ ផ្នែកនុ៎ះ អាគារិយវិន័យ ខ្ញុំបានរៀបរៀងបោះពុម្ពផ្សាយរួចហើយ លើកនេះត្រូវការខ្ញុំរៀបរៀងអនាគារិយ-វិន័យទៀត ឱ្យបានផ្សាយចេញទៅទាំងគូ ។

កំពាក្យថា "អនាគារិយវិន័យ" នេះ ស្រូបដោយវិន័យបិដកទាំងស្រុងមកផង តែអនាគារិយវិន័យដែលខ្ញុំរៀបរៀងនេះ មិនមែនពិស្តារដល់ទៅម្ល៉េះទេ គឺ ខ្ញុំរៀបរៀងដោយសង្ខេបតាមបែបព្រះសិរិមង្គលាចារ្យ លោករៀបរៀងទុកស្រាប់ក្នុងគម្ពីរមង្គលទីបនីឱ្យគ្រាន់តែបានជាគ្រឿងប្រដាប់ប្រាជ្ញារបស់លោកអ្នកប្រតិបត្តិ និងលោកអ្នកសិក្សាប៉ុណ្ណោះ ។

ក្នុងការរៀបរៀងនេះ ខ្ញុំសូមអភ័យទោសពីសំណាក់លោកអ្នកប្រាជ្ញរាល់ព្រះអង្គត្រង់កន្លែងដែលឆ្គាំឆ្គង ។

ទីបំផុត ខ្ញុំសូមលើកចំណែកបុណ្យនេះបូជាចំពោះលោកអ្នកមានគុណ និងចែកផ្សាយដល់សព្វសត្វក្នុងសកលលោក ។

ដោយអំណាចនៃកុសលកម្មបថនេះ ខ្ញុំសូមឱ្យបានជួបប្រសពតែនឹងឥដ្ឋផល ដរាបដល់ព្រះនិព្វានជាទីបំផុត ។

ភ្នំពេញ,ថ្ងៃទី ១ សីហា ១៩៣៧

ហ្លួងវិសុទ្ធមេធា អ៊ុច-រស់

# អនាគារិយវិន័យ

## នមត្ថុ រតនត្តយស្ស

### ពាក្យផ្ដើម

ឱកាសនេះសូមពណ៌នាអំពីអនាគារិយវិន័យ ទុកសម្រាប់គ្រាន់សិក្ខាកាមកុលបុត្រទាំងឡាយសិក្សារៀនទន្ទេញ ឬមើល អានពិចារណាផ្ដិតយកជាឧបាយនៃសេចក្ដីប្រតិបត្តិរបស់ខ្លួន ឬ ប្រដៅទូន្មានសិស្សានុសិស្សតទៅ ។

ក៏វិន័យដែលព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់ទុក សម្រាប់ឱ្យពួកបព្វជិត ដែលជាអ្នកគ្មានកិច្ចកង្វល់ក្នុងការគ្រប់គ្រងគេហស្ថានកាន់កាប់ប្រតិបត្តិតាម ហៅថា អនាគារិយវិន័យ ។

អនាគារិយវិន័យនុ៎ះ បើពោលដល់ឧក្រិដ្ឋ សំដៅយកការមិនប្រព្រឹត្តកន្លងធ្វើឱ្យត្រូវអាបត្តិណាមួយសោះ ក្នុងអាបត្តិទាំង ៧ កង[១] តែបើពោលដោយបន្ទាប់បន្ទុំចុះមក សូម្បីមិនដល់ម្ល៉េះ បើបានជាប្រព្រឹត្តកន្លងធ្វើឱ្យត្រូវអាបត្តិណាមួយដោយការភ្លាំងភ្លាត់

---

១- កងបារាជិក ១, កងសង្ឃាទិសេស ១, កងថុល្លច្ច័យ ១, កងបាចិត្តិយ ១, កងបាដិទេសន័យ១ កងទុក្កដ ១, កងទុព្ភាសិត ១ ។

ហើយ បានធ្វើកិច្ចតបតាមសមគួរដល់អាបត្តិនោះ ៗ មិនបិទបាំងលាក់លៀមទុក ក៏រាប់បញ្ចូលថាជាអនាគារិយវិន័យបានដែរ ។

ព្រោះហេតុនោះ ក្នុងអាបត្តិទាំង ៧ កងបើភិក្ខុធ្វើឱ្យត្រូវអាបត្តិណាមួយហើយ គប្បីធ្វើកិច្ចតបដោយវុដ្ឋានវិធី[១] ឬទេសនាវិធី[២] តាមសមគួរដល់អាបត្តិនោះៗ ចុះ ព្រោះថា អាបត្តិដែលភិក្ខុត្រូវ បើបានចូលបរិវាស ឬសំដែងចេញហើយ ក៏មិនអាចធ្វើអន្តរាយបានឡើយ ។

## អន្តរាយិកធម៌

ដែលហៅថាធ្វើអន្តរាយនោះ គឺធ្វើឱ្យអន្តរាយដល់ផ្លូវសួគ៌និងផ្លូវនិព្វាន[៣] ធម៌ដែលធ្វើឱ្យអន្តរាយបែបនោះ ឈ្មោះថាអន្តរា-យិកធម៌មាន ៥ ពួកគឺៈ

**១-កម្មន្តរាយិកៈ** ធម៌ធ្វើឱ្យអន្តរាយគឺកម្ម ។

**២-កិលេសន្តរាយិកៈ** ធម៌ធ្វើឱ្យអន្តរាយគឺកិលេស ។

**៣-វិបាកន្តរាយិកៈ** ធម៌ធ្វើឱ្យអន្តរាយគឺវិបាក ។

---

១-វិធីចូលបរិវាស ។ ២-វិធីសំដែងអាបត្តិ ។ ៣-ក្នុងគម្ពីរកង្ខាវិតណីសំដែងថាៈ "ផ្លូវសួគ៌ត្រូវធ្វើឱ្យសម្រេចដោយបុញ្ញកិរិយាវត្ថុមានទានជាដើម ផ្លូវព្រះនិព្វានធ្វើឱ្យសម្រេចដោយឈានជាដើម" កាលបើដូច្នេះ ផ្លូវសួគ៌សំដៅយកកាមាវចរកុសលដែលសម្រេចមកអំពីឱ្យទានជាដើម ឯផ្លូវព្រះនិព្វានសំដៅយកតាំងអំពីឈានដែលជារូបាវចរកុសលឡើងទៅដរាបដល់លោកុត្តរធម៌ ។

**៤.ឧបវាទន្តរាយិកៈ** ធម៌ធ្វើឱ្យអន្តរាយគឺពាក្យតិះដៀល

**៥.អាណាវីតិក្កមន្តរាយិកៈ** ធម៌ធ្វើឱ្យអន្តរាយគឺការប្រព្រឹត្តកន្លងអាជ្ញា ។

**អធិប្បាយៈ** អានន្តរិយកម្ម ៥[(១)] ភិក្ខុនីទូសកកម្ម[(២)] ១. ត្រូវជា ៦ ឈ្មោះថា កម្មន្តរាយិកៈ តែអនន្តរិយកម្ម ៥ ធ្វើឱ្យអន្តរាយទាំងផ្លូវសួគ៌ទាំងផ្លូវនិញ្វន ឯភិក្ខុនី ទូសកកម្ម ធ្វើឱ្យអន្តរាយចំពោះតែផ្លូវនិញ្វន ផ្លូវសួគ៌មិនធ្វើឱ្យអន្តរាយឡើយ តែបែបនោះក៏ចំពោះតែកម្មដែលបុគ្គលឱ្យប្រព្រឹត្តទៅក្នុងភិក្ខុនីជាប្រក្រតីដែលមានឆន្ទស្មើរគ្នាទាំងពីរខាងនោះដែរ បើបុគ្គលឱ្យប្រព្រឹត្តទៅក្នុងភិក្ខុនីជាព្រះអរិយាវិញ ក៏មុខជានាំបុគ្គលនោះឱ្យទៅកាន់អបាយជាប្រាកដតួយ៉ាងដូច នន្ទមាណព[(១)] ពុំនោះភិក្ខុនីជាប្រក្រតីទេ តែបុគ្គលឱ្យប្រព្រឹត្តទៅទាំងបំពាន ក៏មិនអាចឃាត់ថាកុំឱ្យធ្វើឱ្យអន្តរាយដល់

---

១-បាបកម្មដែលមានអំណាចឱ្យផលក្នុងជាតិជាបន្ទាប់ ឬដែលបុគ្គលធ្វើត្រូវសោយផលក្នុងជាតិជាបន្ទាប់ឥតមានរវាង ហៅថា អនន្តរិយកម្ម មាន ៥ គឺៈ មាតុឃាត សម្លាប់មាតាបង្កើត ១, បិតុឃាត សម្លាប់បិតាបង្កើត ១, អរហន្តឃាត សម្លាប់ព្រះអរហន្ត ១, ពុទ្ធលោហិតុប្បាទ ញុំាងពុទ្ធលោហិតឱ្យពុរពងឡើង ១, សង្ឃភេទ បំបែកសង្ឃ ១ ។ ២- សេពមេថុនធម្មនិងភិក្ខុនី ។ ៣-នន្ទមាណពនេះទៅចង្រ្កបសេពអសទ្ធម្មនិងនាងឧប្បលវណ្ណាថេរីទាំងបំពានគ្រាន់តែថយផុតមកផែនដីស្រូបចុះទៅកាន់នរកអវចីទាំងរស់ ។

ផ្លូវសួគ៌ដែរ ។

**អហេតុកទិដ្ឋិ** សេចក្តីយល់ថាសត្វឥតហេតុ ១, **អកិរិយទិដ្ឋិ** សេចក្តីយល់ថា ធ្វើអាក្រក់ឥតបានបាប ១, **នត្ថិកទិដ្ឋិ** សេចក្តីយល់ថាធ្វើអំពើអ្វីៗ ឥតបានផល ១, ទិដ្ឋិ ទាំង ៣ នេះ បើដល់ថ្នាក់និយតមិច្ឆាទិដ្ឋិ ទៀងលែងប្រែប្រួល ឈ្មោះថា **កិលេសន្តរា-យិកៈ** ធ្វើឱ្យអន្តរាយ ទាំងផ្លូវសួគ៌ទាំងផ្លូវនិព្វាន ។

**បដិសន្ធិចិត្ត** របស់ពួកបណ្ឌកៈ មនុស្សខ្ទើយ, តិរច្ឆានគតៈ បុគ្គលកើតក្នុងកំណើតសត្វតិរច្ឆាន, ឧភតោព្យញ្ជនកៈ បុគ្គលមានភេទពីរ(១) ជាដើម ។ ដែលជា **អហេតុកប្បដិសន្ធិ** ទាំងប៉ុន្មានឈ្មោះថា **វិបាកន្តរាយិកៈ** តែធមិពួកនេះធ្វើឱ្យអន្តរាយចំពោះតែផ្លូវនិព្វាន ឯផ្លូវសួគ៌មិនធ្វើឱ្យអន្តរាយឡើយ ។

**អរិយូបវាទ** ចេតនាធមិជាហេតុពោលតិះដៀលចំពោះព្រះអរិយៈ ឈ្មោះថា **ឧបវាទន្តរាយិកៈ** ធ្វើឱ្យអន្តរាយទាំងផ្លូវសួគ៌ទាំងផ្លូវនិព្វាន តែ **អរិយូបវាទ** នោះធ្វើឱ្យអន្តរាយតែត្រឹមរវាង

---

១-បុគ្គលនេះភាវរូបទាំង ២ តាំងឡើងប្រាកដគឺ ឥត្ថីភាវរូបក៏តាំងឡើង បុរិសភាវរូបក៏តាំងឡើង មានទាំងភេទប្រុសទាំងភេទស្រី ។

ដែលគេមិនទាន់បានសូម ខមថទោស[១] ចំពោះលោកបើគេបានសូមខមថទោសរួចហើយ តទៅមិនបានធ្វើឱ្យអន្តរាយឡើយ ។

អាបត្តិដែលភិក្ខុក្លែងធ្វើឱ្យត្រូវទាំងបំពាន ឈ្មោះថាអាណាវីតិក្កមន្តរាយិកៈ ធ្វើឱ្យអន្តរាយទាំងផ្លូវសួគ៌ ទាំងផ្លូវនិញ្វន តែអាបត្តិទាំងនោះធ្វើឱ្យអន្តរាយ តែត្រឹមរវាងដែលភិក្ខុទៅប្ដេជ្ញាខ្លួនជាភិក្ខុភាវៈ ឬមិនទាន់បានចូលបរិវាស, មិនទាន់បានសំដែងប៉ុណ្ណោះ បើភិក្ខុបានប្ដេជ្ញាខ្លួនថាមិនមែនជាភិក្ខុភាវៈហើយ ឬបានចូលបរិវាស, បានសំដែងរួចហើយ តពីនោះទៅក៏មិនមានធ្វើឱ្យអន្តរាយដែរ ។

មែនពិត អាបត្តិទាំង ៧ កងគឺៈ បារាជិក, សង្ឃាទិសេស, ថុល្លច្ច័យ, បាចិត្តិយៈ, បាដិទេសនីយៈ, ទុក្កដ, ទុញ្ភាសិត បើភិក្ខុក្លែងធ្វើបំពានឱ្យត្រូវក្នុងកងបារាជិក ហើយនៅប្ដេជ្ញាខ្លួនជាភិក្ខុភាវៈ មិនសឹកចេញ, ឱ្យត្រូវក្នុងកងសង្ឃាទិសេសបិទបាំងទុកមិនចូលបរិវាស, ឱ្យត្រូវក្នុងកងថុល្លបច្ច័យ, បាចិត្តិយៈ, បាដិទេសនីយៈ, ទុក្កដ, ទុញ្ភាសិត តំអក់មិនសំដែងចេញៈ បែបនេះកុំថាឡើយដល់កងអាបត្តិ

---

១-ពាក្យនេះរួមកិរិយាសព្ទនិងនាមសព្ទចូលគ្នាជាបទសមាសដូចពាក្យថា "ឯហិភិក្ខុ" និងពាក្យថា "អហោសិកម្ម" ជាដើម ។ របៀបសូមខមថទោសនេះ សូមចំពោះព្រះភក្ត្រលោកក៏បាន បើរកលោកមិនជួបសូមក្នុងសំណាក់ភិក្ខុសង្ឃឯទៀតក៏បាន ឬបើលោកនិញ្វនហើយសូមចំពោះសព ចំពោះព្រះធាតុ ចំពោះទីបូជាសពរបស់លោកក៏បាន ។

ធំៗ ដោយហោចទៅសូម្បីតែកងអាបត្តិតូចៗ ដូចទុក្កដ ឬ ទុព្ភាសិត ក៏គង់ធ្វើឱ្យអន្តរាយទាំងផ្លូវសួគ៌ទាំងផ្លូវនិព្វានបាន តែបើភិក្ខុក្លែងធ្វើឱ្យត្រូវអាបត្តិក្នុងកងបារាជិកហើយបានប្ដេជ្ញាខ្លួនថាមិនមែនជាភិក្ខុ-ភាវៈ ហើយសឹកចេញស្រឡះទៅក្ដី, ប្ដេជ្ញាខ្លួនជាសាមណេរឡើងវិញក្ដី, ត្រូវអាបត្តិក្នុងកងសង្ឃាទិសេសបានចូលបរិវាស, ត្រូវអាបត្តិក្នុងកងថុល្លច្ច័យ, **បាចិត្តិយៈ,បាដិទេសនីយៈ, ទុក្កដ,ទុព្ភាសិត** បានសំដែងចេញ; បែបនេះកុំថាឡើយតែកងអាបត្តិតូចៗ សូម្បីដល់កងអាបត្តិធំៗ បារាជិក ឬសង្ឃាទិសេស ក៏មិនអាចធ្វើឱ្យអន្តរាយដល់ផ្លូវសួគ៌ និងផ្លូវនិព្វានបានឡើយ ។ អម្បាលអរិយុបវាទកកម្មសូម្បីជាអកុសលពេញទី កាលបើបុគ្គលបានសូមខមថទោសរួចហើយ ក៏ជាអហោសិកម្ម[១] មិនមានឱ្យផល យ៉ាងណាមិញ អាបត្តិដែលភិក្ខុត្រូវហើយ កាលបើភិក្ខុបានប្ដេជ្ញា, បានចូលបរិវាស, បានសំដែង តាមសមគួរដល់ទោសរួចហើយ ក៏ជាអហោសិកម្ម មិនបានឱ្យផល, មិនមានធ្វើឱ្យអន្តរាយ យ៉ាងនោះដែរ តែបើភិក្ខុត្រូវហើយមិនព្រមប្ដេជ្ញា, មិនព្រមចូលបរិវាស, មិនព្រមសំដែងចេញទេ អាបត្តិទាំងនោះមុខជានឹងប្រានភិក្ខុនោះឱ្យជ្រមុជចុះទៅកាន់អបាយ

---

១-កម្មដែលបុគ្គលធ្វើទៅហើយ គ្រាន់ឱ្យផលមិនរួច ហៅថា អហោសិកម្ម ។

ជាប្រាកដ ព្រោះហេតុនោះ ទើបព្រះមានព្រះភាគទ្រង់ទំនាយទុកថា: **សាបត្តិកស្ស ភិក្ខវេ និរយំ វទាមិ តិរច្ឆានយោនឹវា**=ម្នាល ភិក្ខុទាំងឡាយ តថាគតពោលកំណត់ទុក ស្ថាននរក ឬតិរច្ឆានកំណើត សម្រាប់ភិក្ខុដែលប្រកបដោយអាបត្តិ ។

## រឿងឯរកាបត្ត

ក្នុងអធិការនោះ ត្រូវដឹងតាមរឿងនេះជាតួយ៉ាង ក្នុងសាសន កាលនៃព្រះពុទ្ធកស្សប មានភិក្ខុកំឡោះ ១ រូប ធ្វើសមណធម៌នៅ ក្នុងព្រៃអស់ ២ ហ្មឺនឆ្នាំ ថ្ងៃ ១ ឡើងជិះទូកទៅតាមទន្លេគង្គា ដល់ ក្បែរគុម្ពរៃទឹក ១ ក៏លូកដៃទៅចាប់តោងស្លឹក ដល់ទូកលឿនជ្រុល ទៅ ក៏មិនព្រមលែងទាល់តែដាច់ ស្លឹករៃទឹកនោះទៅ ។ ភិក្ខុនោះ តាំងអក់មិនសំដែងអាបត្តិ[(១)] ដោយសំគាល់ថាអំពើនោះបន្តិចបន្តួចទេ លុះដល់ជិតធ្វើកាលកិរិយា ស្រាប់តែឃើញហាក់ដូចជាស្លឹករៃទឹក មករុំព័ទ្ធ គិតចង់នឹងសំដែងអាបត្តិនោះចេញដែរ តែទទួលមិន ឃើញមានភិក្ខុរូបឯទៀតគ្រាន់នឹងសំដែង ក៏កើតវិប្បដិសារៈក្តៅក្រ ហាយចិត្ត ដោយគិតឃើញថា "សីលរបស់ខ្លួនមិនបរិសុទ្ធ" លុះដល់ ស្លាប់ហើយក៏ទៅកើតជាពស់នាគរាជ ទំហឹប៉ុនទូកកម្រោល មាន

---

១-អាបត្តិត្រង់នេះមុខជាសំដៅយកអាបត្តិបាចិត្តិយៈ ត្រង់ភូតគាមសិក្ខាបទ ។

ឈ្មោះថាឯរកបត្ត ។ នាគរាជនោះ គិតនឹងស៊ើបដំណឹងពុទ្ធុប្បាទកាល ដោយឧបាយ ទើបបង្ហាត់ធីតារបស់ខ្លួនឱ្យរៀនច្រៀង ហើយបើក ពពារយ៉ាងធំដាក់ធីតាលើនោះ ឱ្យច្រៀងលើខ្នងទឹកទន្លេគង្គាក្នុងថ្ងៃ ឧបោសថរាល់កន្លះខែ ។ នាងនាគមាណវិកានោះច្រៀងបណ្តើររាំ បណ្តើរតែលើពពារបិតានោះ ។ បណ្តាជនក្នុងជម្ពូទ្វីបចង់បាននាង នាគមាណវិកានោះ ក៏នាំគ្នាទៅច្រៀងតតាមកំឡាំងប្រាជ្ញារៀងខ្លួន នាគរាជជាបិតាក៏ចេះតែប្រកែក (១) ។ ធ្វើបែបនេះដរាបដល់កន្លង ទៅមួយរវាងព្រះពុទ្ធ ។ គ្រានោះព្រះបរមសាស្តារបស់យើងបាន ត្រាស់ដឹងឡើងក្នុងលោក ទ្រង់ទតមើលសត្វលោកក្នុងបច្ចូសកាល ទ្រង់ជ្រាបរឿងនោះ ក៏ស្តេចយាងទៅគង់ក្បែរគល់ច្រេស ១ ទៀប ក្រុងពារាណសី ទ្រង់ទតឃើញមាណពម្នាក់ឈ្មោះឧត្តរៈ កំពុងដើរ សំដៅទៅរកច្រៀងតនឹងនាងនាគមាណវិកានោះ ទ្រង់ត្រាស់ហៅឱ្យ ចូលមកជិតហើយត្រាស់សួរដំណើរសព្វគ្រប់ ទើបទ្រង់បង្រៀនទំនុក ច្រៀងផ្ទាល់ព្រះអង្គ កំពុងតែបង្រៀន ឧត្តរមាណពនោះ ក៏បានលុះ ដល់ថ្នាក់ជាសោតាប័ន្ន ហើយក៏ក្រាបបង្គំលាព្រះបរមសាស្តាដើរ ហួសទៅ ។

---

១-តាមទំនងនេះប្រហែលជាបើកអំណាចថា: បើជនណាច្រៀងតឆ្លើយប្រស្នាត្រូវនឹងឱ្យនាងនាគ មាណវិកានោះទៅជននោះ ។

គ្រានោះ នាងនាគមាណវិកា ច្រៀងសួរជាប្រស្នា ៧ ខ ដោយគាថា ២ បទថា:

**កឹសុ អធិបតី រាជា    កឹសុ រាជា រជស្សិរោ**

**កថំ សុ វិរជោ ហោតិ កថំ ពាលោតិ វុច្ចតិ ។**

**កេនស្សុ វុយ្ហតី ពាលោ កថំ នុទតិ បណ្ឌិតោ**

**យោគក្ខេមី កថំ ហោតិ តម្មេ អក្ខាហិ បុច្ឆិតោ ៈ**

១- បុគ្គលជាអធិបតីលើអ្វី ទើបហៅថាស្តេច ?

២- ស្តេចបែបណា ហៅថាស្តេចមានធូលីជាប់ព្រះសិរ ?

៣- ស្តេចបែបណា ហៅថាស្តេចមានធូលីប្រាសចេញ ?

៤- បុគ្គលដែលលោកហៅថាពាល ដោយហេតុអ្វី ?

៥- បុគ្គលពាល រសាត់ទៅដោយធម៌អ្វី ?

៦- បណ្ឌិត បន្ទោរបង់នូវធម៌អ្វី ដោយធម៌អ្វី ?

៧- បុគ្គលបែបណា ទើបឈ្មោះថាក្សេមចាកយោគៈ[១] ?

នាងខ្ញុំសួរអ្នក ចូរឱ្យអ្នកប្រាប់នាងខ្ញុំ ។

លំដាប់នោះឧត្តរមាណពក៏ច្រៀងតគ្រប់ប្រស្នាទាំង ៧ ខ ដោយគាថា ២ បទថា:

---

១-ធម៌ដែលសំរាប់ក្រុងសត្វទុកក្នុងសង្សារវដ្ដ ហៅថា យោគៈ មាន ៤គឺ កាម ១. ភព ១. ទិដ្ឋិ ១.អវិជ្ជា ១ ។

**ឆទ្វារាធិបតី រាជា រជមានោ រជស្សិរោ**

**អរជំ វិរជោ ហោតិ រជំ ពាលោតិ វុច្ចតិ ។**

**ឱឃេន វុយ្ហតី ពាលោ យោគា នុទតិ បណ្ឌិតោ**

**សព្វយោគវិសំយុត្តោ យោគក្ខេមីតិ វុច្ចតិ=**

១-បុគ្គលជាអធិបតីលើទ្វារទាំង ៦ ការពារមិនឱ្យរូបារម្មណ៍ជាដើមជិះជាន់បាន ទើបហៅថា ស្តេច ។

២-ស្តេចដែលត្រេកត្រអាលក្នុងរូបារម្មណ៍ ជាដើមលើសប្រមាណ ហៅថា ស្តេចមានធូលីជាប់ព្រះសិរ ។

៣-ស្តេចដែលមិនត្រេកត្រអាលក្នុងរូបារម្មណ៍ ជាដើមឱ្យលើសប្រមាណ ហៅថា ស្តេចមានធូលីប្រាសចេញ ។

៤-បុគ្គលដែលហៅថា ពាល ដោយហេតុតែត្រេកអាលលើសប្រមាណក្នុងរូបារម្មណ៍ជាដើមនោះ ។

៥-បុគ្គលពាលរសាត់ទៅដោយឱឃៈ ៤[១] មានកាមោឃៈជាដើម ។

៦- បណ្ឌិតបន្ទោរបង់ឱឃៈ ៤ដោយសេចក្តីព្យាយាមគឺ

---

១-ធម៌សម្រាប់នាំសត្វឱ្យលង់ជ្រមុជទៅក្នុងសង្សារវដ្តដូចជាជំនន់ទឹកយ៉ាងធំ ហៅថា ឱឃៈ មាន ៤ គឺៈ កាម ១, ភព ១, ទិដ្ឋិ ១, អវិជ្ជា ១ ។

សម្មប្បធាន ៤[១] ។

៧- បុគ្គលដែលប្រាសចាកយោគៈទាំងពួង មានកាមយោគៈ ជាដើម លោកហៅថា បុគ្គលក្សេមចាកយោគៈ ។

នាគរាជ បានស្តាប់ទំនុកច្រៀងតរបស់ឧត្តរមាណពនោះ ក៏មានចិត្តត្រេកអរបន្លឺវាចាឡើងថា "ទំនុកច្រៀងបែបនេះខ្ញុំខានបានឮអស់កាលមួយរវាងព្រះពុទ្ធមកហើយ ម្នាលអ្នកដ៏ចំរើន ព្រះពុទ្ធទ្រង់កើតឡើងក្នុងលោកហើយតើ !" រួចហើយក៏ឡើងអំពីទឹកទៅកាន់ សំណាក់ព្រះបរមសាស្តាជាមួយ នឹងឧត្តរមាណព ដល់ហើយក៏ក្រាបថ្វាយបង្គំ រួចទូលយំរៀបរាប់អំពីដំណើរដែលខ្លួនទៅកើតក្នុងកំណើតសត្វតិរច្ឆាន ព្រោះអាស្រ័យទោសដែលខ្លួនធ្វើឱ្យដាច់ស្លឹករំទើកបន្តិចប៉ុណ្ណោះ ហើយក្រាបបង្គំទូលព្រះបរមសាស្តាថាៈ បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គខានបានកើតជាមនុស្ស, ខានបានស្តាប់ខ្ញុំសម្មទ្ធ ខានឃើញព្រះពុទ្ធបែបដូចជាព្រះអង្គ អស់កាលមួយរវាងព្រះពុទ្ធមកហើយ ។

ព្រះបរមសាស្តាត្រាស់តបថា "ម្នាលមហារាជ ពិតមែនហើយ កំណើតរបស់មនុស្សជាដើម សត្វក្ររកបានពេកណាស់" រួចហើយទ្រង់

១-ព្យាយាមត្រូវល្អ ហៅថា សម្មប្បធាន មាន ៤ គឺៈ ព្យាយាមលះបាបចាស់ ១. បង្ការបាបថ្មី១. បណ្តុះបុណ្យថ្មី ១. បំប៉នបុណ្យចាស់ ១. ។

ត្រាស់គាថាក្នុងពុទ្ធវគ្គនៃគម្ពីរធម្មបទថាៈ

**កិច្ឆោ មនុស្សបដិលាភោ កិច្ឆំ មច្ចានជីវិតំ**

**កិច្ឆំ សទ្ធម្មស្សវនំ កិច្ឆោ ពុទ្ធានមុប្បាទោ=**

ការបានកើតមកជាមនុស្សក្រ, ការចិញ្ចឹមជីវិតរបស់សត្វទាំងឡាយក្រ, ការស្តាប់ព្រះសទ្ធម្មក្រ, កាលជាទីកើតឡើងនៃព្រះពុទ្ធទាំងឡាយក្រ ។

អធិប្បាយៈ កាលដែលបានកើតមកជាកំណើតមនុស្សចាត់ជារបស់ក្រ ១ ព្រោះកំណើតជាមនុស្សសត្វគប្បីបានដោយអំណាចនៃកុសលយ៉ាងធំ មិនមែនបានដោយងាយៗ ដោយអំណាចនៃកុសលបន្តិចបន្តួចឡើយ ។ ការចិញ្ចឹមជីវិតរបស់សត្វទាំងឡាយចាត់ជារបស់ក្រ ១ ព្រោះសត្វនឹងអាចញុំាងជីវិតនោះឱ្យប្រព្រឹត្តទៅបានលុះណាតែប្រឹងប្រែងប្រកបការងារមានកសិកម្មជាដើមកុំបីមានសម្រាក ហើយបើទុកជាដូច្នោះក៏ជីវិតនោះមិនបានតាំងនៅយូរប៉ុន្មាន តាំងនៅបានតែត្រឹមអស់កាលបន្តិចបន្តួចប៉ុណ្ណោះ ។ ការស្តាប់ព្រះសទ្ធម្មចាត់ជារបស់ក្រ ១ ព្រោះកម្រមានបុគ្គលអ្នកសំដែងទំរាំនឹងមានម្តងៗ ច្រើនកប្បអនេក លុះណាតែមានព្រះពុទ្ធបានត្រាស់ដឹងឡើងក្នុងលោកទើបមាន ។ កាលជាទីកើតឡើងនៃព្រះ

ពុទ្ធទាំងឡាយចាត់ជារបស់ក្រ១ ព្រោះការកសាងជាព្រះពុទ្ធនីមួយៗ លុះណាតែតាំងឧស្សាហ៍យ៉ាងមាំមួនណាស់ទើបបានសម្រេច មិនមែនបាន សម្រេចដោយការតាំងឧស្សាហ៍យ៉ាងស្ទាក់ស្ទើរឡើយ ហើយតួអង្គព្រះបរមពោធិសត្វ ដែលមានអភិនីហារសម្រេចបរិបូណ៌គួរនឹងបានត្រាស់ដឹងជាព្រះពុទ្ធនោះកម្រមាន ជាទីបំផុតទំរាំមានមួយព្រះអង្គ ៗ រាប់សែនកោដិនៃកប្បជាអនេក ។

នាគរាជ លុះបានស្តាប់គាថានោះហើយ បើតាមទំនងគួរបានសម្រេចដល់ថ្នាក់ជាសោតបន្នក្នុងថ្ងៃនោះ តែបែរជាមិនបានវិញព្រោះខ្លួនមានកំណើតជាសត្វតិរច្ឆាន គ្រាន់តែបានមិនលំបាកក្នុងទី ៥ ស្ថាន ខុសពីពួកនាគឯទៀតៗ គឺមិនលំបាកក្នុងស្ថាន បដិសន្ធិ ១, សកសំណក ១, ចុះកាន់និទ្រាលក់ស្និទ្ធ ១, សេពមេថុននឹងនាងនាគីរានជាតិស្មើរគ្នា ១, ចុតិ ១, ហើយនឹងត្រេចទៅដោយរូបជាពោណពបានប៉ុណ្ណោះ ។

## រឿងភិក្ខុ ៣ ពួកស្លាប់អគ្គិភ្លនៃ្ខាបមស្ទ្រ

ព្រោះហេតុនោះ បើភិក្ខុបានជាថ្វោះធ្វោយធ្វើឱ្យត្រូវអាបត្តិណាមួយហើយគប្បីប្រតិបត្តិឱ្យសមគួរដល់កិច្ចក្នុងអាបត្តិនោះ ៗ ចុះដ្បិតថាកាលបើភិក្ខុប្រតិបត្តិយ៉ាងនេះទៅហើយ សូម្បីមគ្គ និងផល

ក៏គង់ភិក្ខុនោះសម្រេចបាន ទំនងដូចកាលគ្រាព្រះបរមសាស្តាទ្រង់យាងទៅកាន់ចារិកក្នុងដែនកោសល ទ្រង់ទតឃើញភ្លើងឆេះដើមឈើប្រហោងមួយយ៉ាងធំនៅក្បែរផ្លូវ ទ្រង់ព្រះបំណងនឹងសំដែងធម៌ប្រៀបដោយគំនរភ្លើង ទើបទ្រង់គង់ប្រថាប់ទៀបគល់ឈើមួយ ហើយទ្រង់ត្រាស់សំដែងនូវអគ្គិក្ខន្ធោបមសូត្រក្នុងសត្តកនិបាតង្គុត្តរ ដោយន័យថា "ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយចូរមើលគំនរភ្លើងឯណោះហ្ន៎"ដូច្នេះជាដើម ។ និមិត្តតែបានស្តាប់ នូវអគ្គិក្ខន្ធោបមសូត្រនោះ នាមកាយ[1] របស់ភិក្ខុ ៦០ រូបក៏ក្តៅអន្ទះអន្ទែង[2] កាលបើនាមកាយក្តៅអន្ទះអន្ទែងហើយ ក៏ក្តៅអន្ទះអន្ទែងដល់ករជកាយ[3] ផង កាលបើករជកាយក្តៅអន្ទះអន្ទែងហើយ ឈាមដែលកកនៅខាងក្នុង[4] ក៏ខ្ពុរចេញមកពីមាត់ទាំងក្តៅ ៗ បានឮថាភិក្ខុទាំងនោះ សុទ្ធតែត្រូវអាបត្តិបារាជិក ។ មានភិក្ខុ ៦០ រូបទៀត គិតគ្នាថា: "ការប្រព្រឹត្តព្រហ្មចារ្យក្នុងព្រះពុទ្ធសាសនាឱ្យបានបរិសុទ្ធពេញលេញដរាបដល់អស់ជីវិតវៀងខ្លួនក្រក្រៃពេក" ហើយក៏នាំគ្នាសឹកចេញអស់ទៅ បានឮថាភិក្ខុទាំងនោះ សុទ្ធតែប្រព្រឹត្តញ៉ាំញីសិក្ខាបទតូចៗ រាយរង ។

---

១-ចិត្តនិងចេតសិក ហៅថានាមកាយ ។ ២-សំដៅវិប្បដិសារៈ សេចក្តីក្តៅក្រហាយចិត្ត ។ ៣-កាយដែលកើតអំពីសុក្កសម្ភវៈ ហៅថា ករជកាយ សំដៅយកប្រជុំអាការៈទាំង ៣២ ។ ៤ ឈាមនេះឈ្មោះ សន្និចយលោហិត ។

ក៏គង់ភិក្ខុនោះសម្រេចបាន ទំនងដូចកាលគ្រាព្រះបរមសាស្តាទ្រង់យាងទៅកាន់ចារិកក្នុងដែនកោសល ទ្រង់ទតឃើញភ្លើងឆេះដើមឈើប្រហោងមួយយ៉ាងធំនៅក្បែរផ្លូវ ទ្រង់ព្រះបំណងនឹងសំដែងធម៌ប្រៀបដោយគំនរភ្លើង ទើបទ្រង់គង់ប្រថាប់ទៀបគល់ឈើមួយ ហើយទ្រង់ត្រាស់សំដែងនូវអគ្គិក្ខន្ធោបមសូត្រក្នុងសត្តកនិបាតង្គុត្តរ ដោយន័យថា "ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយចូរមើលគំនរភ្លើងឯណោះហ្ន៎"ដូច្នេះជាដើម ។ និមិត្តតែបានស្តាប់ នូវអគ្គិក្ខន្ធោបមសូត្រនោះ នាមកាយ[១] របស់ភិក្ខុ ៦០ រូបក៏ក្តៅអន្ទះអន្ទែង[២] កាលបើនាមកាយក្តៅអន្ទះអន្ទែងហើយ ក៏ក្តៅអន្ទះអន្ទែងដល់ករជកាយ[៣] ផង កាលបើករជកាយក្តៅអន្ទះអន្ទែងហើយ ឈាមដែលកកនៅខាងក្នុង[៤] ក៏ខ្ពុរចេញមកពីមាត់ទាំងក្តៅ ៗ បានឮថាភិក្ខុទាំងនោះ សុទ្ធតែត្រូវអាបត្តិបារាជិក ។ មានភិក្ខុ ៦០ រូបទៀត គិតគ្នាថាៈ "ការប្រព្រឹត្តព្រហ្មចារ្យក្នុងព្រះពុទ្ធសាសនាឱ្យបានបរិសុទ្ធពេញលេញដរាបដល់អស់ជីវិតរឿងខ្ជួនក្រក្រៃពេក" ហើយក៏នាំគ្នាសឹកចេញអស់ទៅ បានឮថាភិក្ខុទាំងនោះ សុទ្ធតែប្រព្រឹត្តល្មាំញីសិក្ខាបទតូចៗ រាយរង ។

---

១-ចិត្តនិងចេតសិក ហៅថានាមកាយ ។ ២-សំដៅវិប្បដិសារៈ សេចក្តីក្តៅក្រហាយចិត្ត ។ ៣-កាយដែលកើតអំពីសុក្កសម្ភវៈ ហៅថា ករជកាយ សំដៅយកប្រជុំអាការៈទាំង ៣២ ។ ៤ ឈាមនេះឈ្មោះ សន្និចយលោហិត ។

ក្នុងទេវលោក. ឯពួកភិក្ខុក្រៅពីនេះ ដែលប្រព្រឹត្តញាំញីសិក្ខាបទតូចៗ រាយរង បើកុំតែបានស្តាប់ធម្មទេសនានុ៎ះ យូរទៅមុខជានឹងហ៊ានធ្វើឱ្យត្រូវរហូតដល់អាបត្តិសង្ឃាទិសេស. អាបត្តិបារាជិកទៀតនេះមិនដូច្នោះ លុះបានស្តាប់ធម្មទេសនានុ៎ះហើយ ក៏កើតសេចក្តីសង្វេគថា "ឱព្រះពុទ្ធសាសនា ថ្លៃថ្លាណាស់តើ! ពួកយើងមិនអាចប្រតិបត្តិឱ្យពេញលេញ ដរាបដល់អស់ជីវិតបានឡើយ ណ្ហើយយើងគិតសឹកចេញទៅបំពេញធម៌របស់ឧបាសកវិញ មិនលែងរួចចាកទុក្ខទេ"រួចហើយក៏នាំគ្នាសឹកចេញទៅតាំងនៅក្នុងសរណត្រ័យនិងបញ្ច-សីល ខំបំពេញធម៌របស់ឧបាសកទាំងអស់គ្នា ខ្លះក៏បានសម្រេចដល់ថ្នាក់សោតាប័ន្ន ខ្លះជាសកទាគាមី, ខ្លះជាអនាគាមី ខ្លះក៏បានត្រឹមតែឡើងទៅកើតក្នុងទេវលោក ធម្មទេសនានុ៎ះ ប្រកបដោយផលដល់ភិក្ខុទាំង ២ ពួកនោះបែបនេះឯង ។

សូម្បីអាបត្តិដែលភិក្ខុត្រូវហើយ តែបានប្តេជ្ញាខ្លួនសឹកចេញទៅ ឬបានចូលបរិវាស, បានសំដែងឱ្យជ្រះស្រឡះទៅវិញ ក៏មិនអាចធ្វើឱ្យអន្តរាយបានទៅហើយ ចាំនិយាយថ្វីដល់ទៅអាបត្តិដែលភិក្ខុគ្មានត្រូវ !

<u>អន្តរាយិកធម៌ ចប់</u>

## ចតុប្បារិសុទ្ធិសីល

ន័យមួយទៀត អនាគារិយវិន័យលោកសំដៅយកចតុប្បារិ-សុទ្ធិសីលគឺ បាតិមោក្ខសំវរសីល ១, ឥន្ទ្រិយសំវរសីល ១, អាជីវ-ប្បារិសុទ្ធិសីល ១, បច្ចយសន្និស្សិតសីល ១ ។ សីលដែលសម្រេចដោយការសង្រួមតាមសិក្ខាបទក្នុងបដិមោក្ខ ឈ្មោះថាបដិមោក្ខសំវរសីល, ដែលសម្រេចដោយការសង្រួមឥន្ទ្រិយទាំង ៦ ឈ្មោះថាឥន្ទ្រិយសំវរសីល, ដែលសម្រេចដោយការចិញ្ចឹមជីវិតស្អាតបរិសុទ្ធឈ្មោះថាអាជីវប្បារិសុទ្ធិសីល, ដែលសម្រេចដោយការអាស្រ័យប្រើប្រាស់បច្ច័យ បានពិចារណាឈ្មោះថា បច្ចយសន្និស្សិតសីល ។

## បាតិមោក្ខសំវរសីល

ក៏បាតិមោក្ខសំវរសីល លុះណាតែភិក្ខុមិនធ្វើឱ្យត្រូវអាបត្តិសោះទើបឈ្មោះថាបរិសុទ្ធ មែនពិត បាតិមោក្ខសំវរសីលដែលបរិសុទ្ធបែបនោះ រមែងនាំមកនូវសេចក្ដីសុខ ទាំងលោកិយៈ ទាំងជាលោកុត្តរៈ តួយ៉ាងដូចសីលរបស់ព្រះបធានិយត្ថេរ ។

## រឿងព្រះបធានិយត្ថេរ

សេចក្ដីដំណាលថា : ព្រះថេរៈអង្គនោះ កំពុងតែគង់ស្ដាប់

អរិយវំស[១] ទេសនា ក្នុងខណ្ឌបេលវិហារ មានពស់មានពិសដ៏ពន្លឹក ទៅចឹកលោក បើទុកជាលោកដឹងហើយ ក៏នៅតែមានចិត្តជ្រះថ្លាគង់ស្តាប់ធម៌ដដែល លុះកម្លាំងពិសកាន់តែក្លាឡើង លោកក៏ពិចារណាសីលរបស់ខ្លួន តាំងពីឧបសម្បទមណ្ឌលមក លុះបានឃើញថាសីលរបស់ខ្លួនបរិសុទ្ធស្អាតឥតសៅហ្មង ក៏ញ៉ាំងបិតីឱ្យកើតឡើង គ្រាន់តែចិត្តដែលសម្បយុត្តដោយបីតិកើតឡើងប៉ុណ្ណោះ ពិសពស់ក៏ស្រាកត្រឡប់ចូលទៅកាន់ផែនដីអស់ទៅ លោកក៏បានឯគ្គតាចិត្ត ខំចម្រើនវិបស្សនាបានលុះព្រះអរហត្តក្នុងទីនោះឯង ។

រឿងនេះលោកពោលដោយឧក្រិដ្ឋ បើពោលដោយបន្ទាប់បន្សំចុះមក បាតិមោក្ខសំវរសីល លោកឱ្យឈ្មោះថាទេសនាសុទ្ធិ ព្រោះសីលនោះបរិសុទ្ធដោយការសំដែង ឬ មានការសំដែងជាគ្រឿងធ្វើឱ្យបរិសុទ្ធ ហើយទាំងការប្តេជ្ញាខ្លួនថាមិនមែនជាភិក្ខុភាវៈដោយត្រូវអាបត្តិបារាជិក និងការចូលបរិវាស ដោយត្រូវអាបត្តិសង្ឃាទិសេស ក៏លោកសង្គ្រោះចូលក្នុងការសំដែងទាំងអស់ ព្រោះហេតុនោះ បើភិក្ខុប្រព្រឹត្តកន្លងធ្វើឱ្យត្រូវអាបត្តិណាមួយហើយ បាន

---

១-ធម៌ដែលជាវង្សរបស់ព្រះអរិយៈ ហៅថា អរិយវំស មាន ៤ គឺ សន្តោសក្នុងចីវរ ១, សន្តោសក្នុងបិណ្ឌបាត ១, សន្តោសក្នុងសេនាសនៈ ១, សន្តោសក្នុងគិលានភេសជ្ជៈ ១ ។

សំដែងដោយការបេ្តជ្ញាខ្លួន, ដោយការចូលបរិវាស, ដោយការប្រកាសប្រាប់សង្ឃ ឬគណៈ ឬបុគ្គល តាមសមគួរដល់អាបត្តិនោះ ៗ សីលរបស់ភិក្ខុនោះ ឈ្មោះថានៅបរិសុទ្ធ សូម្បីមគ្គនិងផលក៏គង់សម្រេចដល់ភិក្ខុនោះបាន ។

តាមទំនងនេះ សូម្បីសីលរបស់ភិក្ខុដែលមានធ្វើឱ្យត្រូវអាបត្តិដែរ តែបានចេញចាកអាបត្តិទាំងនោះវិញ ដោយទេសនាវិធីជាដើម ក៏គង់នាំមកនូវសេចក្ដីសុខបានដែរ តួយ៉ាងដូចសីលរបស់ព្រះសុធម្ម-ត្ថេរ ។

## រឿងព្រះសុធម្មត្ថេរ

សេចក្ដីដំណាលថាៈ ព្រះថេរៈអង្គនោះបានជេរចិត្តគហបតីដោយពាក្យមិនគប្បីហើយទៅកាន់សំណាក់ព្រះសាស្ដា ទទួលយកឱវាទអំពីសំណាក់ព្រះអង្គ ត្រឡប់មកសំដែងអាបត្តិចំពោះមុខចិត្តគហបតីសូមខមាទោសនឹកគាត់ រួចហើយក៏ទៅនៅក្នុងអម្ពាដការាមដដែលវិញ កន្លងទៅបានពីរបីថ្ងៃ ក៏បានសម្រេចព្រះអរហត្តព្រមទាំងបដិសម្ភិទាទៅ ។

តែបើទុកជាដូច្នោះ ក៏មិនត្រូវឱ្យភិក្ខុអ្នកបំពេញនូវបាតិមោក្ខ-សំវរសីលបណ្ដែតបណ្ដោយឡើយ ត្រូវតែយកតម្រាប់តាមព្រះថេរៈ

អង្គមួយ ដែលពួកចោរចងលោកទុកចោលក្នុងដងព្រៃ ។

## រឿងព្រះថេរៈចោរចង

សេចក្ដីដំណាលថាៈ មានព្រះថេរៈអង្គ ១ និមន្តទៅជួបនឹងពួកចោរក្នុងដងព្រៃ ក្បែរហិមវន្តប្បទេស ។ ពួកចោរទាំងនោះចាប់លោកចងភ្ជាប់នឹងវល្លិ៍ ចោលក្នុងទីនោះ ដោយខ្លាចក្រែងលោកត្រឡប់ទៅវិញនិយាយប្រាប់គេ ។ ព្រះថេរៈក៏គង់នៅតែមួយកន្លែងមិនហ៊ានបម្រះឱ្យដាច់វល្លិ៍ ខំតែចម្រើនវិបស្សនាអស់ ៧ ថ្ងៃ ក៏បានសម្រេចដល់ថ្នាក់អនាគាមី ច្យុតក្នុងទីនោះ បានឡើងទៅកាន់ព្រហ្ម-លោក ។

## រឿងព្រះថេរៈចោរចងដទៃទៀត

មានព្រះថេរៈមួយអង្គទៀត នៅក្នុងតម្ពបណ្ណិទ្វីប.[១] ពួកចោរចាប់លោកចងនឹងវល្លិ៍ ផ្ដេកចោលក្នុងដងព្រៃ ទទួលភ្លើងព្រៃឆេះរាលមកដល់ លោកក៏មិនហ៊ានផ្ដាច់វល្លិ៍ ចេញ ខំតែចម្រើនវិបស្សនាដរាបបានសម្រេចព្រះអរហត្តឈ្មោះជីវិតសមសីសី[២] បរិនិព្វានក្នុងទីនេះទៅ ។

---

១ លង្កាទ្វីប ឬសីហឡទ្វីប ។ ២- បានសម្រេចព្រះអរហត្តដំណាលគ្នានឹងអស់ជីវិត ។

**អវសានគាថា**

**បាតិមោក្ខំ វិសោធេន្តោ អប្បេវជីវិតំ ជហេ**
**បញ្ញត្តំ លោកនាថេន ន ភិន្ទេ សីលសំវរំ=**

ព្រោះហេតុនោះ កុលបុត្តអ្នកមានសទ្ធា កាលបើជម្រះនូវបាតិមោក្ខ-សំវរសីល សូវឱ្យប្រថុយ លះបង់ជីវិត មិនត្រូវឱ្យទម្លាយការសង្រួមសីល ដែលព្រះលោកនាថ ទ្រង់បញ្ញត្តឡើយ ។

បាតិមោក្ខសំវរសីល ចប់

# ឥន្ទ្រិយសំវរសីល

ឯឥន្ទ្រិយសំវរសីល រមែងបរិសុទ្ធដល់ភិក្ខុអ្នកឃើញទោស និងអានិសង្សក្នុងការសង្រួម និងការមិនសង្រួម មិនមែនបរិសុទ្ធដល់ភិក្ខុក្រៅអំពីនេះឡើយ ។ មែនពិត ឥន្ទ្រិយសំវរសីលនោះ លុះតែភិក្ខុឃើញអានិសង្សដោយការគ្រៀម, ឃើញទោសដោយការភ័យ ទើបអាចនឹងរក្សាឱ្យបរិសុទ្ធឱ្យពេញលេញបាន បើមិនដូច្នោះទេ មិនអាចនឹងរក្សាឱ្យបរិសុទ្ធឱ្យពេញលេញបានឡើយ ។

# ទោសនិងអានិសង្សក្នុងការសង្រួម និងការមិនសង្រួម

ទោសនិងអានិសង្សក្នុងការសង្រួម និងការមិនសង្រួមនោះ ក្នុងបឋមសង្គេយ្យសូត្រ ព្រះមានព្រះភាគទ្រង់ត្រាស់ថាៈ កន្លែងកើតនៃផស្សៈ ៦ គឺ : ភ្នែក ១, ត្រចៀក ១, ច្រមុះ ១, អណ្តាត ១, កាយ ១, ចិត្ត ១ បើភិក្ខុមិនបានទូន្មានឃុំគ្រងរក្សាដោយល្អទេ រមែងនាំមកនូវទុក្ខលើសប្រមាណ មានទុក្ខក្នុងនរកជាដើម បើភិក្ខុបានទូន្មានឃុំគ្រង់រក្សាដោយល្អហើយ រមែងនាំមកនូវសេចក្តីសុខលើសប្រមាណ មានសុខក្នុងឈាន និងសុខក្នុងមគ្គផលជាដើម ។ ក្នុងអាទិត្តបរិយាយសូត្រ ព្រះមានព្រះភាគទ្រង់ត្រាស់ថាៈ បើភិក្ខុអាលភ្នែកដោយបន្ទះដែក, ក្វារត្រចៀកដោយកង្វារដែកយ៉ាងមុត, ឆ្កៀលច្រមុះដោយកាំបិតកាត់ក្រចកយ៉ាងមុត, កាត់អណ្តាតដោយកាំបិតកោរយ៉ាងមុត, ពន្លះកាយដោយលំពែងយ៉ាងមុត ដែលគេដុតភ្លើងឆេះយ៉ាងរន្ទាលផុតចុងផុតដើម ប្រសើរជាង ឯការកាន់យកនូវនិមិត្តដោយអនុព្យញ្ជនៈថាល្អស្អាតជាដើម ក្នុងរូបដែលឃើញដោយភ្នែកថាពីរោះជាដើម ក្នុងសំឡេងដែលឮដោយត្រចៀក, ថាក្រអូបជាដើម ក្នុងក្លិនដែលធុំដោយច្រមុះ, ថាឆ្ងាញ់ជាដើមក្នុងរសដែល

ស្រស់ស្រួបដោយអណ្តាត. ថាត្រជាក់ ទន់ ជាដើម ក្នុងផ្សព្វដែលប៉ះពាល់ដោយកាយ មិនប្រសើរសោះទេ ព្រោះថាបើចិត្តកំពុងតែជាប់ដោយសេចក្តីត្រេកអរក្នុងនិមិត្តនោះៗ ហើយទទួលភិក្ខុនោះធ្វើកាលកិរិយាក្នុងសម័យនោះទៅ ក៏មុខជានឹងទៅកាន់គតិពីរគឺ នរក ឬកំណើតសត្វតិរច្ឆានជាប្រាកដ បើមិន ១ ក៏ ១ ន័យមួយទៀតថា ការដេកលក់ប្រសើរជាង ព្រោះការដេកលក់គ្រាន់ជាទោស នាំឱ្យខាតផលដល់អ្នករកស៊ីចិញ្ចឹមជីវិតប៉ុណ្ណោះ ឯគំនិតខុស ដែលភិក្ខុត្រិះរិះដោយចិត្ត មិនប្រសើរសោះឡើយ ព្រោះថាបើភិក្ខុលុះក្នុងអំណាចគំនិតនោះហើយ គំនិតនោះមុខជានាំភិក្ខុនោះឱ្យធ្វើអំពើបាបដរាបដល់បំបែកសង្ឃជាទីបំផុត ។ មិនត្រឹមតែប៉ុណ្ណោះ សូម្បីសេចក្តីវិនាសទាន់ហន់បច្ចុប្បន្នក៏ លោកចាត់ថាជាទោសដែរ តួយ៉ាងដូចរឿងរ៉ាវតទៅនេះ ។

# រឿងហារិតតាបស

សេចក្តីដំណាលថា: ក្នុងអតីតកាល ព្រះបរមពោធិសត្វសោយព្រះជាតិជាព្រាហ្មណ៍នាម "ហារិត" មានព្រះឆវិវណ្ណល្អដូចមាសកាញ្ចនា មាសម្បត្តិ ៨០ កោដិ ដល់អំណើះអំពីមាតាបិតាទៅទ្រង់ចេញទៅសាងផ្នួសជាតាបសឫសីនៅក្នុងព្រៃហិមវន្ត បាន ៧ ថ្ងៃ

ទ្រង់ចម្រើនបានឈាននិងអភិញ្ញា ហើយគង់នៅក្នុងទីនោះអស់កាលដ៏យូរ ដោយមានព្រះហឫទ័យភ្ញាក់ចង់សេពវត្ថុប្រៃនិងជូ ក៏ចេញទៅគង់នៅក្នុងឧទ្យានព្រះបាទពារាណសី តែងតែទៅឆាន់ចង្ហាន់ក្នុងព្រះរាជដំណាក់ជាប់ជានិច្ចអស់ ១២ ឆ្នាំ ។ សម័យ ១ ព្រះរាជាទ្រង់យាងចេញទៅបង្ក្រាបសត្រូវក្នុងបច្ចន្តគ្រាម ទ្រង់ផ្តាំទុកនឹងនាងទេវីថា កុំឱ្យព្រះនាងធ្វេសប្រហែសនឹងបុញ្ញក្ខេត្តរបស់ទ្រង់ ។ តាំងពីត្រឹមនោះមកព្រះនាងទេវី ក៏តែងតែអង្គាសចង្ហាន់ព្រះមហាសត្វផ្ទាល់ដៃខ្លួនរាល់៧ ថ្ងៃ គាប់ជួនថ្ងៃមួយព្រះមហាសត្វយឺតយូរក្រនិមន្តមកដល់ ព្រះនាងក៏ស្រង់ទឹក ហើយទ្រង់ព្រះពស្ត្រសាច់រអិលបើកបង្អួចសីហបញ្ជរ ផ្ទំសំដីលយកខ្យល់ ដល់ឮសន្ធឹកចីវរសម្បកផ្ចៃព្រះមហាសត្វហោះមកតាមអាកាស ព្រះនាងស្ទុះក្រោកឡើងប្រញាប់ប្រញាល់ក៏របូតព្រះពស្ត្រព្រះអង្គទទេ ព្រះមហាសត្វទតឃើញវិសភាគារម្មណ៍បែបនោះ មានកិលេសកើតឡើង ក៏សាបសូន្យឈានក្នុងខណៈនោះ មិនអាចនឹងទប់ទល់ស្មារតីបានក៏សេពសន្ថវនឹងនាងទេវីនោះទៅ ដល់ឆាន់ចង្ហាន់រួច ក៏និមន្តទៅកាន់ឧទ្យានវិញដោយព្រះបាទ ។ តាំងពីត្រឹមនោះមកព្រះមហាសត្វធ្វើអំពើបែបនោះតែរាល់៧ ថ្ងៃ ។ ព្រះមហាសត្វទ្រង់បានដល់នូវសេចក្តីវិនាស

ទាន់ហាន់ក្នុងបច្ចុប្បន្នដូច្នេះ ក៏ព្រោះតែមិនសង្រួមឥន្ទ្រិយ ។ តមក អំពើនោះក៏ល្បីសុះសាយពេញទាំងនគរ ពួករាជអាមាត្យផ្ញើចុត ហ្មាយទៅថ្វាយដំណឹងដល់ព្រះរាជា ៗ ក៏ស្តេចមិនទ្រង់ជឿ លុះ បង្ក្រាបសត្រូវបានស្ងាប់រម្ងាប់ហើយទ្រង់យាងត្រឡប់មកដល់វិញ ទើបទ្រង់ស្តេចយាងទៅសាកសួរព្រះបរមពោធិសត្វឯឧទ្យានផ្ទាល់ ព្រះអង្គ ។ ព្រះបរមពោធិសត្វ ហេតុតែទ្រង់ជាអ្នកពោលពាក្យសច្ចៈ ក៏ថ្វាយព្រះពរព្រះរាជតាមការពិតឥតលាក់លាម ហើយសូមឱ្យព្រះ រាជាទុកឱកាសឱ្យបន្តិចទើបចូលទៅកាន់បណ្ណសាលា សំឡឹងមើល មណ្ឌលកសិណ ក៏ញ៉ាំងឈានឱ្យកើតឡើងវិញ ហោះចេញអំពីបណ្ណ សាលា ទៅគង់នៅឰដ៏អាកាសសំដែងធម៌ថ្វាយព្រះរាជា ហើយហោះ ត្រឡប់ទៅកាន់ហិមវន្តប្បទេសវិញទៅតមកទ្រង់មិនបានសាបសូន្យ ចាកឈាន ក៏បានឡើងទៅកើតក្នុងព្រហ្មលោក ។

## រឿងរាជបុត្រព្រះចៅក្រុងពារាណសី

រឿងមួយទៀត ក្នុងអតីតកាលព្រះបរមពោធិសត្វ សោយ ព្រះជាតិជាព្រះរាជឱរសពៅទី ១០០ របស់ព្រះបាទព្រហ្មទត្តក្នុង ក្រុងពារាណសី ។ ព្រះអង្គទ្រង់នាំបុរសជាបរិវារ ៥ នាក់ចេញចាក ដែនទៅកាន់ក្រុងតក្កសិលាកន្លងផ្លូវកន្តារចម្ងាយ ៥០ យោជន៍ ជួប

ប្រទះនឹងយក្ខិនីនិម្មិតជារូបទិព្វ, សំឡេងទិព្វ, ក្លិនទិព្វ, រសទិព្វ, សម្ផស្សទិព្វ ល្បួងលួងលោមនៅក្នុងដងព្រៃពាក់កណ្តាលផ្លូវ ឯបុរសទាំង ៥ នាក់ជាបរិវាររបស់ពោធិសត្វ ម្នាក់មិនសង្រួមភ្នែក លុះក្នុងការលួងលោមរបស់ពួកយក្ខិនីដោយរូប, ម្នាក់មិនសង្រួមត្រចៀក លុះដោយសំឡេង, ម្នាក់មិនសង្រួមច្រមុះ លុះដោយក្លិន, ម្នាក់មិនសង្រួមអណ្តាត លុះដោយរស, ម្នាក់មិនសង្រួមកាយ លុះដោយសម្ផស្ស ពួកយក្ខិនីទំពាស៊ី ជាអាហារអស់ទាំង ៥ នាក់ នៅសល់តែព្រះពោធិសត្វ ១ ព្រះអង្គ ទ្រង់ប្រុងប្រយ័ត្នឥន្ទ្រិយ មិនលុះដោយការលួងលោមរបស់ពួកយក្ខិនី ទ្រង់បានយាងទៅដល់ទីក្រុងតក្កសិលា បានទទួលគ្រោងរាជក្នុងថ្ងៃទី ៧ ។

មែនពិត បុរសទាំង ៥ នាក់ បានដល់នូវសេចក្តីវិនាសដូច្នេះ ព្រោះតែមិនសង្រួមឥន្ទ្រិយ ព្រះបរមពោធិសត្វបានដល់នូវសេចក្តីចំរើនដូច្នេះ ព្រោះតែសង្រួមឥន្ទ្រិយ ។

ន័យមួយទៀត សេចក្តីសាបសូន្យចាកចំណី (គោចរ) របស់ខ្លួន ក៏ចាត់ថាជាទោសដែរ ព្រោះហេតុនោះទើបព្រះមានព្រះភាគទ្រង់ត្រាស់ប្រទានឱវាទថា: ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនគួរកាន់យកនិមិត្តថាល្អ ក្នុងរូបជាដើមទេ ព្រោះបើធ្វើកាលកិរិយាក្នុង

សម័យនោះទៅ មុខជាទៅកើតក្នុងអបាយមាននរកជាដើម ព្រោះហេតុនោះ អ្នកទាំងឡាយកុំកាន់យកនិមិត្តថាល្អ ក្នុងរូបជាដើមឡើយ កាលវេលាដែលអ្នកទាំងឡាយគួរសំឡឹងមើលរូបក៏មាន ដែលមិនគួរសម្លឹងមើរូបក៏មាន ក្នុងកាលដែលក្រឡេកឃើញរូប មិនគួរអ្នកទាំងឡាយសម្លឹងមើលដោយសម្គាល់ថាល្អទេ គួរសម្លឹងមើលដោយសំគាល់ថាមិនល្អវិញ យ៉ាងនេះទើបមិនសាបសូន្យចាកចំណីរបស់ខ្លួន អ្វីជាចំណីរបស់អ្នកទាំងឡាយ ? បតិបដ្ឋាន ៤, សម្មប្បធាន ៤ , អរិយមគ្គ មានអង្គ ៨, លោកុត្តរធម៌ ៩, មែនពិត កាលបើអ្នកទាំងឡាយប្រព្រឹត្តក្នុងចំណីទាំងនុ៎ះ មារនឹងរកចន្លោះទោលមិនបានឡើយ ប្រសិនបើអ្នកទាំងឡាយលុះក្នុងអំណាចកិលេស សំឡឹងមើលរូបដែលសំគាល់ថាល្អហើយ មុខជានឹងសាបសូន្យចាកចំណីរបស់ខ្លួនមិនខាន ដូចជាចចកឈ្មោះបូតិមំសៈ[១] ។

## រឿងចចកឈ្មោះបូតិមំសៈ

សេចក្ដីដំណាលថា: ក្នុងអតីតកាលមានពួកចៀមជាច្រើនរយនៅអាស្រ័យក្នុងគុហារភ្នំ ១ ក្បែរហិមវន្តប្បទេស ។ ក្នុងចន្លោះចៀមទាំងនោះ មានមេចៀមមួយ ឈ្លាសវៃក្នុងឧបាយផ្សេងៗ

---

១-ចចកសាច់ស្អុយ ។

ឈ្មោះមេណ្ឌមាតា ។ នៅជិតទីលំនៅពួកចៀមទាំងនោះ មាន គុហា១ មានចចកឈ្មោលមួយឈ្មោះបូតិមំសៈ និងភរិយាឈ្មោះវេណី នៅអាស្រ័យក្នុងនោះ ។ ចចកឈ្មោលញីបានចាប់ពួកចៀមទាំងនោះ ស៊ីអស់ជាច្រើន ហើយគិតរកឧបាយនឹងចាប់មេចៀមឈ្មោះមេណ្ឌ មាតាស៊ីទៀត ទើបចចកឈ្មោលនិយាយនឹងភរិយារបស់ខ្លួនថាៈ ចូរ នាងឯងទៅសុំធ្វើជាសំឡាញ់នឹងមេចៀមឈ្មោះមេណ្ឌមាតានោះ ដល់បានស្និទ្ធស្នាលហើយ អញនឹងដេកពុតជាស្លាប់ រួចចូរនាងឯងទៅ បបួលវាមកថា (...ស្វាមីខ្ញុំស្លាប់ ខ្ញុំគ្មានទីពឹងសោះទេ វាលែងតែ នាងចេញខ្ញុំគ្មានញាតិដទៃទេ អញ្ជើញនាងទៅជួយធ្វើសរីរកិច្ចស្វាមី ខ្ញុំ) លុះវាមកដល់អញនឹងស្ទុះលោតទៅខាំកវាសម្លាប់ ។ ចចកញីក៏ ធ្វើតាម លុះទៅបបួលធ្វើជាសំឡាញ់នឹងមេចៀមនោះបានស្និទ្ធស្នាល ហើយ ក៏និយាយបបួលដូច្នេះ ។ មេចៀមនិយាយថាៈ ប្ដីនាងស៊ីញាតិ របស់ខ្ញុំអស់ច្រើនណាស់ហើយ ខ្ញុំខ្លាចគាត់មិនហ៊ានទៅទេ ។ មេ ចចកនិយាយទៅវិញថាៈ "នាងកុំខ្លាចគាត់ស្លាប់ហើយនឹងធ្វើអ្វីកើត" រួចក៏បបួលមេចៀមនោះទាល់តែបានទៅ ។ ចចកឈ្មោះពួស្ទូរជើង សត្វទាំងពីរដើរទៅអំពីចម្ងាយក៏ងើបក្បាលអើតមើលនឹងក្នុងចិត្តថាៈ មេចៀមមកដែរឬទេ ។ ចៀមឃើញចចកធ្វើដូច្នេះក៏គិតថាៈ

"ចចកនេះមានធមិដ៏លាមក ដេកពុតធ្វើជាស្លាប់ ប្រុងនឹងបញ្ឆោតអញយកមកសម្លាប់ទេតើ" ហើយក៏រត់ទៅវិញបាត់ទៅ ។ មេចចកមិនអាចនឹងឃាត់មេចៀមនោះថាកុំឱ្យត្រឡប់ទៅវិញបាន ក៏ចូរទៅតិះដៀលចចកជាប្ដីរបស់ខ្លួន ពោលជាគាថាដូច្នេះថា:

**ត្វំ ខោសិ សម្ម ឧម្មត្តោ ទុម្មេធោ អវិចក្ខណោ**
**យោ ត្វំ មតាលយំ គន្ត្វា អកាលេន វិបេក្ខតិ=**

ម្នាលសំឡាញ់មានធុរៈស្មើ អ្នកឯងឆ្កួតសោះទេ អ្នកឯងមានគំនិតអាក្រក់ គ្មានប្រាជ្ញាពិចារណាអ្វីសោះ អ្នកឯងធ្វើពុតជាស្លាប់ ហើយក្រឡេកមើលឥតរបប មិនត្រូវតាមកាល ។

ព្រះមានព្រះភាគទ្រង់នាំអតីតនិទានមកដំណាលយ៉ាងនេះរួចហើយ ទើបទ្រង់ត្រាស់ព្រះគាថាក្នុងបូតិមំសជាតក ក្នុងនវកនិបាតថា:

**ន អកាលេ វិបេក្ខេយ្យ កាលេ បេក្ខេយ្យ បណ្ឌិតោ**
**បូតិមំសោវ ឈាយតិ យោ អកាលេ វិបេក្ខតិ=**

បណ្ឌិតមិនត្រូវក្រឡេកមើលក្នុងកាលមិនគួរទេ ត្រូវតែក្រឡេកមើលការគួរ បុគ្គលណាក្រឡេកមើលរូបក្នុងការមិនគួរ បុគ្គលនោះរមែងក្រៀមក្រំដូចជាចចកឈ្មោលឈ្មោះបូតិមំសៈ ។

**អធិប្បាយៈ** ពាក្យថា "កាលមិនគួរ" សំដៅយកកាលដែលចិត្តកំពុងកើតឡើង ប្រារព្ធកាមគុណ ដោយសុភនិមិត្តមែនពិត កាលនេះ ឈ្មោះថាកាលមិនគួរឱ្យសម្លឹងមើលរូប ។ ពាក្យថា "កាលគួរ" សំដៅយកកាលជាទី កាន់យករូបមកសំគាល់ជាអសុភ[១] មកពិចារណាជាអនុស្សតិ[២] ឬកាន់យកមកសម្លឹងជាកសិណ[៣] មែនពិត កាលនេះឈ្មោះថាកាលគួរឱ្យសម្លឹងមើលរូប ។ ពាក្យថា "ក្រៀមក្រំដូចជាចចកឈ្មោះបូតិមំសៈ" សេចក្តីថា ចចកឈ្មោះបូតិមំសៈក្រឡេកមើលមេចៀមក្នុងកាលមិនគួរ ឱ្យសូន្យចាកចំណីរបស់ខ្លួនហើយក្រៀមក្រមនៅយ៉ាងណា បើភិក្ខុក្រឡេកមើលរូបក្នុងកាលមិនគួរដោយសុភនិមិត្តឱ្យសូន្យចាកចំណីរបស់ខ្លួនមានសតិបដ្ឋានជាដើម រមែងក្រៀមក្រំទាំងក្នុងបច្ចុប្បន្ន ទាំងក្នុងបរលោកនាយយ៉ាងនោះ ។

ព្រោះហេតុនោះ ភិក្ខុមិនត្រូវប្រកាន់រូបារម្មណ៍ជាដើម ដោយការកាន់យកនូវអនុព្យញ្ជនៈ[៤] និងការកាន់យកនូវនិមិត្ត[៥] ឡើយ

១-សំដៅយកវិធីចំរើនអសុភកម្មដ្ឋានទាំង ១០ ។ ២-សំដៅយកវិធីចំរើនកាយគតាសតិកម្មដ្ឋាន ។ ៣-សំដៅយកវិធីចំរើនកសិណទាំង ១០ ដោយសម្លឹងយករូបរបស់កសិណមកជាអារម្មណ៍ ។ ៤-ការកាន់យកបំបែកដោយឡែកៗ តាមអវយវៈនោះ ៗ ដូចជាប្រកាន់ថា "ដៃល្អ ជើងល្អ" ជាដើម ហៅថា កាន់យកនូវអនុព្យញ្ជនៈ ។ ៥-ការកាន់យកម៉ៅទាំងស្រុងដូសត្វក្រពើលេបចំណី ហៅថា កាន់យកនូវនិមិត្ត ។

គឺបើឃើញរូបយ៉ាងណា, ឮសំឡេងយ៉ាងណា, ធុំក្លិនលិតភ្លក់រស, ប៉ះពាល់សម្ផស្សយ៉ាងណា ត្រូវឱ្យប្រកាន់តែត្រឹមប៉ុណ្ណោះ កុំឱ្យជ្រួលហួសដល់ទៅកើតសោមនស្សនិងទោមនស្សឡើយ ឱ្យបានដូចជាព្រះអសុភកម្មិកមហាតិស្សត្ថេរ នៅក្នុងចេតិយបព្វតវិហារ ។

## រឿងព្រះអសុភកម្មិកមហាតិស្សត្ថេរ

សេចក្ដីដំណាលថា: ព្រះថេរៈអង្គនោះ ធ្វើទុកក្នុងចិត្តនូវអដ្ឋិកកម្មដ្ឋានជាប្រក្រតី ថ្ងៃមួយលោកចេញទៅស្វែងរកបិណ្ឌបាតក្នុងក្រុងអនុរាធបុរី គ្រានោះមានស្ត្រីម្នាក់ ឈ្លោះនឹងស្វាមីដើរចេញអំពីក្រុងអនុរាធបុរី ពីព្រលឹមទៅកាន់ផ្ទះញាតិ ដល់ប្រទះឃើញលោកពាក់កណ្ដាលផ្លូវ ក៏មានចិត្តប្រែប្រួល ម្រ៉េចម្រ៉ូច សើចក្អាកក្អាយឡើង ទទួលលោកកំពុងតែនិមន្តទៅទាំងធ្វើទុកក្នុងចិត្តនូវអដ្ឋិកកម្មដ្ឋានបណ្ដើរ លោកក៏គិតថាអ្វីហ្នឹង? ហើយផ្ទៀងមើលតាមលំអោនសំឡេងសើចនោះទៅ ព្រោះបុព្វភាគមនសិការៈមាន សំឡេងជាបន្ទា(១) លោកក៏បាននូវអដ្ឋិកសញ្ញាក្នុងឆ្អឹងធ្មេញរបស់ស្ត្រីនោះ បានលុះដល់បឋមជ្ឈាន ហើយធ្វើបឋមជ្ឈាននោះឱ្យជាទីតាំង ខំចំរើន

---

១-ការធ្វើទុកក្នុងចិត្តនូវកម្មដ្ឋានដើមដំបូងជាសត្រូវនឹងសំឡេង កា[illegible]បើមានសំឡេងមកប៉ះភ្ជាក់បាក់ដូចជាបន្លាចុច ។

វិបស្សនាបន្តទៅបានសម្រេចអរហត្តផលព្រះអរហត្ត តែក្នុងមួយជំហរនោះ ។

រឿងនេះលោកពោលដោយឧក្រិដ្ឋ បើពោលដោយបន្ទាប់បន្សំចុះមក ធម្មតាចិត្តនេះប្រព្រឹត្តទៅរហ័ស ព្រោះហេតុនោះ បើរាគៈកើតឡើង ភិក្ខុត្រូវបន្ទោរបង់ដោយអសុភមនសិការៈ[១] ហើយញ៉ាំងឥន្ទ្រិយសំវរសីលឱ្យសម្រេចបរិបូណ៌ ដូចជាព្រះវង្គីសត្ថេរ ដែលទើបនឹងបួសថ្មីចុះ ។

## រឿងព្រះវង្គីសត្ថេរ

សេចក្តីដំណាលថា: ព្រះថេរៈអង្គនោះ និមន្តទៅបិណ្ឌបាតជាមួយនឹងព្រះអានន្ទត្ថេរ ក្រឡេកឃើញស្ត្រីម្នាក់ក៏មានរាគៈកើតឡើង ហើយពិតទូលដំណើរនោះដល់ព្រះអានន្ទត្ថេរថា: សូមឱ្យលោកប្រាប់ឧបាយសម្រាប់រំលត់រាគៈដល់ខ្ញុំ ។ ព្រះអានន្ទត្ថេរបង្គាប់ថា: បើដូច្នេះចូរអ្នកកុំធ្វើទុកក្នុងចិត្តនូវអសុភនិមិត្តដែលជាហេតុនាំកើតរាគៈ ហើយចូរចំរើនចិត្តដោយអសុភភាវនាចុះ ។

ព្រះថេរៈអង្គនោះធ្វើតាមដូច្នោះ ក៏បន្ទោរបង់រាគៈបានមែន ហើយត្រាច់ទៅស្វែងរកបិណ្ឌបាតតាមស្រួល ដល់ខាងក្រោយមក

---

១-ការធ្វើទុកក្នុងចិត្តថាមិនល្អ, មិនស្អាត ។

លោកក៏បានសម្រេចដល់ព្រះអរហត្ត ។

មែនពិត ឥន្ទ្រិយសំវរសីល លោកឱ្យឈ្មោះថាសំវរសុទ្ធិ ព្រោះសីលនេះ បើភិក្ខុធ្វើឱ្យបែកធ្លាយហើយ គ្រាន់តែតាំងចិត្តថា លែងធ្វើយ៉ាងនេះទៀតប៉ុណ្ណោះ ក៏អាចបរិសុទ្ធឡើងវិញបាន ។

ព្រោះហេតុនោះ ឥន្ទ្រិយសំវរសីលនេះ សូម្បីភិក្ខុឯទៀត កាលបើបានជាធ្វើឱ្យបែកធ្លាយហើយ គប្បីធ្វើឱ្យសម្រេចបរិបូណ៌ ឡើងវិញ ដោយការតាំងចិត្តលែងធ្វើដូច្នោះទៀត ដូចពោលមក ហើយនោះចុះ។ មួយទៀត ភិក្ខុអ្នកបំពេញឥន្ទ្រិយសំវរសីលគប្បីយក តម្រាប់តាមព្រះចិត្តគុត្តត្ថេរនៅក្នុងករណ្ឌកលេណចុះ ។

## រឿងព្រះចិត្តគុត្តត្ថេរ

សេចក្តីដំណាលថាៈ ក្នុងលេណ(១) ឈ្មោះករណ្ឌកៈមានគំនូរ ជាទីតម្រេកចិត្ត ថ្លែងរឿងព្រះពុទ្ធ ៧ ព្រះអង្គទ្រង់ចេញសាងព្រះ ផ្នួស ។ ព្រះថេរៈគង់នៅក្នុងទីនោះអស់ជាង ៦០ វស្សា មិនដែល បើកព្រះនេត្រក្រឡេកមើលលេណដល់ម្តង ព្រោះលោកសំឡឹងមើល តែត្រឹមមួយជួរនឹមជាប្រក្រតី ព្រោះហេតុនោះទើបលោកមិនទាំង ជ្រាបថាមានគំនូរនៅក្នុងទីនោះផង ។

---

១-ពាក្យនេះជាមួយគ្នានឹងពាក្យថាគុហា យើងសព្វថ្ងៃហៅថាគុះ ។

**សួរថា:** ក្នុងសេនាសនវត្ត ព្រះមានព្រះភាគទ្រង់ត្រាស់ថា ត្រូវឱ្យភិក្ខុបោសចាប់អំពីពិដានមុនដំបូងចុះមក មែនទេ ? ឬព្រះថេរៈលោកមិនជម្រះសេនាសនៈទេ ?

**ឆ្លើយថា:** អើលោកមិនជម្រះទេ តែអន្តេវាសិកជាដើមរបស់លោកជម្រះប្រគេនលោក ។

ថ្ងៃមួយខាងក្រោយមក មានភិក្ខុច្រើនរូបដើរទៅកាន់សេនាសនចារិក លុះបានឃើញគំនួរក៏ទូលថា: បពិត្រលោកដ៏ចំរើន គំនួរនេះជាទីតម្រេកចិត្តពេក ។ ព្រះថេរៈតបថា: ម្នាលអាវុសោទាំងឡាយ ខ្ញុំនៅទីនេះអស់កាលយូរប៉ុណ្ណេះមក មិនទាន់បានដឹងថាមានគំនួរ ទើបតែថ្ងៃនេះខ្ញុំបានដឹងអាស្រ័យដោយសារលោករាល់អង្គដែលជាអ្នកមានភ្នែក ។ មួយទៀតនៅក្បែរទ្វារលេណរបស់លោកនោះមានដើមខ្នឹង ១ ដើមយ៉ាងធំ សូម្បីតែដើមខ្នឹនោះ ក៏លោកមិនដែលងើយមើលទៅខាងលើដល់ម្តងឡើយ បានឮថារាល់ឆ្នាំលោកបានជ្រាបថា ដើមខ្នឹងនោះមានផ្កាដោយសារឃើញកេសរជ្រុះមកលើផែនដីប៉ុណ្ណោះ ។ ព្រះរាជាទ្រង់ព្រះសណ្តាប់អំពីគុណសម្បត្តិរបស់ព្រះថេរៈ ក៏មានព្រះរាជហឫទ័យប្រាថ្នាចង់ថ្វាយបង្គំ ហើយទ្រង់ចាត់រាជបំរើទៅនិមន្ត ៣ ដង ព្រះថេរៈចេះតែមិនព្រមទទួលនិមន្ត

ព្រះរាជាទ្រង់ត្រាស់ឱ្យរាជបុរសចងដោះពួកស្រី១ មានកូនខ្ចីនៅក្នុង មហាគ្រាមទាំងប៉ុន្មាន ដោយផែនសំពត់សំរាប់ចងដោះ ហើយឱ្យប្រថាប់ព្រះសង្ហារភ្ជាប់ ដោយព្រះរាជបំណង និងកុំឱ្យទារកទាំងឡាយបានបៅដោះ ដរាបដល់ព្រះថេរៈលោកនិមន្តទៅ ។ ព្រះថេរៈមានសេចក្តីអនុគ្រោះដល់ពួកទារក ក៏និមន្តទៅត្រឹមមហាគ្រាម(១) ព្រះរាជទ្រង់ជ្រាបដំណឹង ក៏ទ្រង់ត្រាស់ឱ្យនិមន្តលោកចូលទៅក្នុងរាជបុរី ហើយថ្វាយបង្គំ ប្រគេនចង្ហាន់រួចសព្វគ្រប់ ទើបពិតទូលព្រះថេរៈថា: "បពិត្រលោកដ៏ចំរើន ថ្ងៃនេះខ្ញុំករុណាគ្មានឱកាស ដល់ថ្ងៃស្អែកខ្ញុំករុណាទទួលសីល" ហើយក៏ទ្រង់កាន់បាតយាងជូនដំណើរព្រះថេរៈទៅបន្តិច ជាមួយនឹងព្រះរាជទេពី រួចថ្វាយបង្គលាត្រឡប់ទៅវិញ ដល់មួយថ្ងៃទៀតទ្រង់ថ្វាយទានរួចពិតទូលព្រះថេរៈថា "ថ្ងៃស្អែកសីមខ្ញុំករុណាទទួលសីល" ដូចជាថ្ងៃមុន ហើយកាន់បាតយាងជូនព្រះថេរៈទៅ ទ្រង់ធ្វើតែតាមទំនងនេះ ដរាបដល់គ្រប់ ៧ ថ្ងៃ ។ ចំណែកព្រះថេរៈ ក្នុងកាលដែលព្រះរាជាស្តេចទ្រង់ថ្វាយបង្គំក្តី ព្រះនាងទេវីទ្រង់ថ្វាយបង្គំក្តី ក៏កាន់យកត្រឹមតែអាការថាសត្វ១ ប៉ុណ្ណោះ មិនមានសំគាល់ដោយឡែកពីគ្នាថាស្រីប្រុសឡើយ ព្រោះហេតុនោះទើប

---

១-មហាគ្រាមនេះ គឺជាឈ្មោះស្រុកធំ ១ នៅក្នុងលង្កាទ្វីប ក្បែរក្រុងអនុរាធបុរី ។

លោកចេះតែមានវាចាស្របគ្នាថា "សូមឱ្យមហារាជបានសេចក្ដីសុខៗ" ដូច្នេះ។ ព្រះថេរៈគង់នៅក្នុងមហាគ្រាមបាន ៧ ថ្ងៃ ព្រះរាជទ្រង់ឆ្ងល់យល់ថា "ព្រះថេរៈគង់នៅក្នុងទីនេះរមែងតែទុក្ខ" ទើបបើកឱកាសឱ្យលោកនិមន្តទៅ ព្រះថេរៈក៏និមន្តទៅកាន់លេណរបស់ខ្លួនវិញ ដល់ក្នុងចំណែករាត្រីលោកក៏ឡើងទៅកាន់ទីចង្ក្រម មានទេវតាមួយរូបនៅអាស្រ័យលើដើមខ្ទឹងគិតថា "លោកម្ចាស់អង្គនេះពិតជាមានសីលបរិសុទ្ធិល្អមែន" ទើបឈរកាន់ប្រទីបទ្រោពបំភ្លឺប្រគេន។ ព្រះថេរៈនិមន្តចង្ក្រមដោយធ្វើទុកក្នុងចិត្តនូវកម្មដ្ឋានបណ្ដើរ ដល់រវាងមជ្ឈិមយាមលោកក៏ញ៉ាំងភ្នំទាំងអស់ឱ្យលាន់ឮកងរំពងឡើង ហើយលុះបានដល់ព្រះអរហត្ត ក្នុងខណៈនោះឯង ។

ឥន្ទ្រិយសំវរសីល ចប់

# អាជីវបារិសុទ្ធិសីល

ឯអាជីវបារិសុទ្ធិសីលរមែងបរិសុទ្ធដល់ភិក្ខុដែលមានសេចក្ដីព្យាយាមជាគ្រឿងចិញ្ចឹមជីវិតត្រូវ ព្រោះហេតុនោះទើបព្រះមានព្រះភាគ ទ្រង់ត្រាស់ទុកក្នុងមហាសតិបដ្ឋានសូត្រថាៈ ម្នាលភិក្ខុទាំងឡាយ ដូចម្ដេចសោត សេចក្ដីព្យាយាមជាគ្រឿងចិញ្ចឹមជីវិតត្រូវ? ម្នាលភិក្ខុទាំងឡាយ អរិយសាវ័កក្នុងសាសនានេះ រមែងលះ

បង់សេចក្តីព្យាយាមជាគ្រឿងចិញ្ចឹមជីវិតខុស ហើយចិញ្ចឹមជីវិតដោយសេចក្តីព្យាយាមជាគ្រឿងចិញ្ចឹមជីវិតត្រូវ ម្នាលភិក្ខុទាំងឡាយ បែបនេះ តថាគត ហៅថា សេចក្តីព្យាយាមជាគ្រឿងចិញ្ចឹមជីវិតត្រូវ ។

អធិប្បាយៈ ពាក្យថាៈ "សេចក្តីព្យាយាមជាគ្រឿងចិញ្ចឹមជីវិតខុស" សំដៅយក កាយទុច្ចរិតនិងវចីទុច្ចរិត ដែលភិក្ខុឱ្យប្រព្រឹត្តទៅដើម្បីប្រយោជន៍ដល់បង្អែមនិងចំអាប ។ ពាក្យថា "សេចក្តីព្យាយាមជាគ្រឿងចិញ្ចឹមជីវិតត្រូវ" សំដៅយកសេចក្តីព្យាយាមជាគ្រឿងចិញ្ចឹមជីវិត ដែលព្រះសម្ពុទ្ធទ្រង់សរសើរ។ សេចក្តីព្យាយាមជាគ្រឿងចិញ្ចឹមជីវិតខុសចែកចេញជា ២ ប្រភេទគឺៈ កាយិកៈ=ប្រព្រឹត្តទៅក្នុងកាយទ្វារ ១, វាចសិកៈ=ប្រព្រឹត្តទៅក្នុង វចីទ្វារ ១។ អំពើទុច្ចរិតមានស្លប្រេងនិងស្លថ្នាំអរិដ្ឋ(១) ជាដើមដោយបំណងនឹងធ្វើវេជ្ជកម្មដែលព្រះពុទ្ធទ្រង់ហាម លោកហៅថា កាយិកមិច្ឆាអាជីវ=សេចក្តីព្យាយាមជាគ្រឿងចិញ្ចឹមជីវិតខុស ប្រព្រឹត្តទៅ ក្នុងកាយទ្វារ ។ អំពើទុច្ចរិតមានទទួលបណ្តាំគ្រហស្ថនិងប្រាប់ដំណឹង

---

១-ថ្នាំអរិដ្ឋនេះជាភេសជ្ជៈវិសេស ១ គេស្លផ្សំដោយរសរបស់ផ្លែកន្ទួតព្រៃជាដើម មានពណ៌ ក្លិន និងរសដូចជាគ្រឿងស្រវឹង តែមិនមែនជាគ្រឿងស្រវឹងទេ ។

គ្រហស្ថជាដើម ហៅថា វាចសិកមិច្ឆាអាជីវៈ=សេចក្ដីព្យាយាមជាគ្រឿងចិញ្ចឹមជីវិតខុសប្រព្រឹត្តទៅក្នុងវចីទ្វារ ។

## វេជ្ជកម្មវិធី

ភិក្ខុធ្វើថ្នាំឱ្យជនដទៃដែលព្រះពុទ្ធទ្រង់ហាម មិនបានទ្រង់អនុញ្ញាត ហៅថាវេជ្ជកម្មដែលព្រះពុទ្ធទ្រង់ហាម ។ មែនពិត កាលបើជនដទៃមករកសូមថ្នាំមិនត្រូវភិក្ខុធ្វើឱ្យឡើយ កាលបើធ្វើឱ្យនឹងត្រូវអាបត្តិទុក្កដ ។ តែជន ២៥ ពួកព្រះសម្ពុទ្ធទ្រង់អនុញ្ញាតឱ្យភិក្ខុធ្វើថ្នាំឱ្យបាន ។ ជន ២៥ ពួកនោះគឺសហធម្មិក ៥ គឺភិក្ខុ ១, ភិក្ខុនី ១ សិក្ខមានា ១, សាមណេរ ១, សាមណេរី ១ ( ត្រូវជា ៥) បណ្ឌុបលាសៈ=បុគ្គលដែលបំរុងនឹងបួសកំពុងតែចាត់ចែងដុតបាត្រជ្រលក់ចីវរជាដើមនៅក្នុងវត្ត ១, វេយ្យាវច្ចកររបស់ខ្លួន១, មាតា ១,បិតា ១, ឧបដ្ឋាកររបស់មាតាបិតា ១( ត្រូវជា ១០) ជេដ្ឋកាតា=បងប្រុស ១, កនិដ្ឋកាតា=ប្អូនប្រុស ១, ជេដ្ឋភគិនី=បងស្រី ១, កនិដ្ឋភគិនី=ប្អូនស្រី ១, ចុល្លមាតា=មាមីងខាងមាតា ១, មហាមាតា=តា-ដូនខាងមាតា ១, ចុល្លបិតា-មា-មីងខាងបិតា ១, មហាបិតា=តា-ដូនខាងបិតា ១, បិតុច្ឆា=ម្ដាយធំ-ឪពុកធំខាងបិតា ១, មាតុលា=ម្ដាយធំ-ឪពុកធំខាងមាតាធំ ១ ( ត្រូវជា ១០ ចាត់ទុកជាញាតិ) មនុស្ស

អាគន្តុកៈ ១. ចោរ ១. បុគ្គលដែលច្បាំងចាញ់គេ ១. ឥស្សរជន ១. បុគ្គលដែលពួកញាតិកាត់កាលចោល ១( ត្រូវជា ៥) រួបរួមទាំងអស់ត្រូវជាជន ២៥ ពួកដែលព្រះពុទ្ធទ្រង់អនុញ្ញាតឱ្យភិក្ខុធ្វើថ្នាំឱ្យបានតាមការគួរ ។

ត្រង់ជន ១០ ពួកដែលចាត់ទុកជាញាតិនុ៎ះសូម្បីកូននិងចៅជាដើមរបស់ជនទាំងអម្បាលនោះ ដរាបដល់ ៧ សន្តានត្រកូល(១) ក៏លោកសង្គ្រោះចូលថាជាញាតិរបស់ភិក្ខុដែរ ព្រោះជាប់សៃស្រឡាយមកអំពីជនទាំង ១០ ពួកនោះ ទោះបីភិក្ខុធ្វើថ្នាំឱ្យដល់ជនទាំងនោះផងក៏គួរ តែភាតុជាយា=បងថ្លៃ ប្អូនថ្លៃស្រី.ភគិនិសាមិកោ=បងថ្លៃ-ប្អូនថ្លៃប្រុស.ចុល្លមាតុសាមិកោ=មាថ្លៃ.ចុល្លបិតុជាយា=ម្តាយមីងថ្លៃជាដើមដែលមានជម្ងឺ បើជាប់ជាញាតិគួរភិក្ខុធ្វើថ្នាំឱ្យបាន បើមិនជាប់ជាញាតិទេ ត្រូវភិក្ខុធ្វើឱ្យទៅបងប្រុស ឬប្អូនប្រុសរបស់ខ្លួនជាដើមដែលជាប់ញាតិហើយប្រាប់ថា "អ្នកចូរយកទៅឱ្យត្រង់កន្លែងដែលជា

---

១-ពាក្យនេះច្រើននិយាយថាញាតិ ៧ សន្តានគឺរាប់យកខាងលើខ្លួន ៣ ជួរ. ស្រករខ្លួន ១ ជួរ. ខាងក្រោមខ្លួន ៣ ជួរ ត្រូវជា ៧ ជួរ. ខាងលើខ្លួន ៣ ជួរគឺ ស្រករមាតាបិតាខ្លួន ១ ជួរ. ស្រករជីដូនជីតាខ្លួន ១ ជួរ. ស្រករជីដូនតួតជីតាតួតខ្លួន ១ ជួរ. ជា ៣ ជួរ. ស្រករខ្លួនគឺពួកបងប្អូនបង្កើត. ជីដូនមួយ. ជីតួតមួយខ្លួន ១ ជួរ.ខាងក្រោមខ្លួន ៣ ជួរគឺ ស្រករនឹងកូនខ្លួន( ពួកក្មួយ) ១ ជួរ. ស្រករនឹងចៅខ្លួន( ពួកចៅ) ១ ជួរ.ស្រករនឹងចៅតួតខ្លួន( ពួកចៅតួត) ១ជួរត្រូវជា ៧ជួរ។

ទីថៃទាំរបស់អ្នកចុះ" ពុំនោះឱ្យដល់ពួកកូនរបស់ជនទាំងនោះថា "អ្នកចូរយកទៅឱ្យដល់មាតាបិតារបស់អ្នកចុះ" ធ្វើដូច្នេះទើបបាន ។ បុគ្គលឯទៀតក្រៅអំពីបុគ្គលទាំងប៉ុន្មានពួកដូចបានពោលមកនុ៎ះ ហៅថា ជនដទៃ ថ្នាំដែលភិក្ខុធ្វើឱ្យដល់ជនដទៃនោះ ហៅថាវេជ្ជកម្ម ដែលព្រះពុទ្ធទ្រង់ហាម ។ ក្នុងពួកជនទាំងប៉ុន្មាន ពួកដែលព្រះសម្ពុទ្ធទ្រង់អនុញ្ញាតឱ្យភិក្ខុធ្វើថ្នាំឱ្យបាននោះ ជន ១០ ពួកខាងដើមមានសហធម្មិក ៥ ជាដើម បើភិក្ខុនឹងធ្វើថ្នាំឱ្យត្រូវធ្វើដោយថ្នាំរបស់ជនទាំងនោះ ខ្លួនគ្រាន់តែផ្សំឱ្យ បើថ្នាំរបស់ជនទាំងនោះមិនមាន ត្រូវធ្វើដោយថ្នាំរបស់ខ្លួនចុះ បើថ្នាំរបស់ខ្លួនក៏មិនមានដែរ ត្រូវស្វែងរកដោយភិក្ខាចារវត្ត បើស្វែងរកយ៉ាងនេះមិនបាន ត្រូវរកអំពីសំណាក់ញាតិរបស់ខ្លួនក៏បាន ញាតិរបស់ជនទាំងនោះក៏បាន ឬរកអំពីទីដែលគេបវារណាចំពោះខ្លួនក៏បាន ចំពោះជនទាំងនោះក៏បាន បើធ្វើយ៉ាងនេះក៏នៅតែមិនបានទៀត គប្បីស្វែងរកដោយអកតវិញ្ញត្តិ គឺការសូមក្នុងទីដែលគេមិនបានបវារណាចុះ ។ ឯពួកជនដែលរាប់ថាជាញាតិទាំងប៉ុន្មានត្រូវភិក្ខុធ្វើឱ្យបានតែដោយថ្នាំរបស់គេ បើថ្នាំរបស់គេមិនមាន ត្រូវឱ្យគេខ្ចីរបស់ខ្លួនចុះ តែបើគេសងវិញក៏គប្បីទទួលយកទៅ បើគេមិនសងវិញទេមិនត្រូវភិក្ខុទៅតឿនទារគេឡើយ ។ មួយទៀត

ពួកញាតិទាំងប៉ុន្មានសុទ្ធតែគួរឱ្យភិក្ខុសូមបច្ច័យបាន ព្រោះហេតុនោះ កាលបើភិក្ខុឱ្យគេនាំយកចតុប្បច្ច័យរបស់ញាតិទាំងនោះមក ក៏មិនចាត់ជាអកតវិញ្ញត្តិ គឺការសូមក្នុងទីដែលគេមិនបានបវារណា កាលបើភិក្ខុធ្វើថ្នាំឱ្យក៏មិនចាត់ជាវេជ្ជកម្ម ពុំនោះបើភិក្ខុឱ្យរបស់ដើម្បីជាការសង្គ្រោះត្រកូល ក៏មិនមានកុលទូសនបត្តិ[១] ។ ចំណែកជន ៥ ពួកខាងចុងមានមនុស្សអាគន្តុកៈជាដើម បើមានជម្ងឺហើយដើរចូលទៅកាន់វត្ត គួរភិក្ខុធ្វើថ្នាំឱ្យចុះ សូម្បីធ្វើដោយថ្នាំរបស់ខ្លួនក៏បាន តែមិនត្រូវធ្វើដោយសង្ឃឹមលាភអំពីគេទេ កាលបើភិក្ខុធ្វើថ្នាំដោយសង្ឃឹមលាភអំពីគេថា "ធម្មតាមនុស្ស លែងអ្វីនឹងដឹងឧបការៈ"ដូច្នេះ នឹងមានទោសក្នុងវេជ្ជកម្ម និងកុលទូសនៈជាដើម តែបើភិក្ខុធ្វើដោយសង្ឃឹមថា "កាលបើអញធ្វើឧបការៈយ៉ាងនេះទៅ គេនឹងជ្រះថ្លាដឹងគុណសាសនា ឬគេនឹងធ្វើឧបការៈដល់សង្ឃ" ដូច្នេះវិញ មិនមានទោសឡើយ ។

មែនពិត វត្ថុដែលកើតឡើងដោយភិក្ខុធ្វើវេជ្ជកម្មដែលព្រះពុទ្ធទ្រង់ហាមជាដើម សុទ្ធតែអកប្បិយៈទាំងអស់ ព្រោះហេតុនោះ ទើបព្រះអដ្ឋកថាចារ្យពោលទុកថាៈ ភោជនដែលកើតអំពី

---

១-អាបត្តិទុក្កដ ព្រោះទ្រុស្តត្រកូលគឺប្រចុបប្រជែងឱ្យរបស់នេះរបស់នោះទៅត្រកូល ។

**កុលទូសនៈ=**ការទ្រុស្តត្រកូល, កើតអំពីវេជ្ជកម្ម, អំពីអូតឧត្តរិមនុស្សធម្ម, អំពីរូបិយៈដែលភិក្ខុទទួល ឬត្រេកអរជាដើម ព្រះពុទ្ធទ្រង់តិះដៀលថា សុទ្ធតែជាអកប្បិយភោជនកើតអំពីការស្វែងរកមិនត្រូវទំនងទាំងអស់ ។

## ទូតកម្មវិធី

**ឯទូតកម្ម=**ការធ្វើជាអ្នកបម្រើរបស់គ្រហស្ថនោះ គប្បីដឹងដោយសង្ខេបដូច្នេះ : ភិក្ខុ ១, ភិក្ខុនី ១, សិក្ខមានា ១, សាមណេរ ១, សាមណេរី ១ ដែលហៅថាសហធម្មិក ៥, បណ្ឌុបលាសៈ ១, វេយ្យាវច្ចកររបស់ខ្លួន ១, មាតា ១, បិតា ១ ត្រូវជា ៩ បុគ្គលទាំង ៩ ពួកនេះ គួរភិក្ខុទទួលពាក្យបណ្ដាំបាន ប្រាប់ពាក្យបណ្ដាំក៏បាន[១] ឯបុគ្គលដទៃអំពីនេះ គួរភិក្ខុទទួល ឬប្រាប់បានតែពាក្យបណ្ដាំដែលអកប្បិយៈ ព្រោះហេតុនោះ ភិក្ខុមិនត្រូវរង្កៀសសង្ស័យក្នុងពាក្យបណ្ដាំដែលគេផ្ដាំថា "សូមលោកថ្វាយបង្គំព្រះបាទាព្រះមានព្រះភាគតាមពាក្យខ្ញុំ សូមលោកថ្វាយបង្គំព្រះចេតិយ, ព្រះបដិមា, ព្រះពោធិព្រឹក្ស, ព្រះសង្ឃត្ថេរ សូមលោកធ្វើគន្ធបូជា-បុប្ផបូជាក្នុងព្រះចេតិយ

---

១-បើទុកជាដូច្នេះ ក៏គួរសន្និដ្ឋានថា គង់មានពាក្យបណ្ដាំដែលភិក្ខុមិនគួរទទួលបាន ដូចពាក្យបណ្ដាំក្នុងការដឹកនាំផ្សំផ្គុំស្ត្រីនិងបុរសជាដើម ។

សូមលោកចាត់ប្រជុំភិក្ខុ យើងខ្ញុំនឹងថ្វាយទាននិងស្តាប់ធម៌ដូច្នេះទេ ព្រោះពាក្យបណ្តាំទាំងនេះ ជាអកប្បិយៈមិនមានទាក់ទងដោយកិច្ចការរបស់គ្រហស្ថឡើយ ។ ជនដទៃក្រៅអំពីជនទាំង ៩ ពួកនុ៎ះ បើភិក្ខុណាមួយ ទទួលពាក្យបណ្តាំដទៃ ខុសចាកពាក្យបណ្តាំដែលជាកប្បិយៈមានទំនងដូចពោលមកហើយ ៗ ដើរទៅ ភិក្ខុនោះត្រូវអាបត្តិទុក្កដរាល់ៗជំហាន កាលបើភិក្ខុនោះឆាន់ភោជនដែលបានមកដោយសារអំពើបែបនោះ ត្រូវអាបត្តិទុក្កដរាល់ៗ ម៉ាត់ ព្រោះបច្ច័យដែលកើតឡើងដោយសារកុលទូសកកម្មមិនគួរដល់សហធម្មិកទាំង ៥ ដូចជាបច្ច័យដែលកើតឡើងដោយសារអ្នកឧត្តរិមនុស្សធម៌ និងទិញដូរដោយរូបិយៈដែរ ។

## ត្រូវសេពបច្ច័យដែលកើតឡើងបរិសុទ្ធ

ន័យមួយទៀត ភិក្ខុណាបរិភោគបច្ច័យដែលកើតឡើងដោយសារធ្វើទូតកម្ម និងវេជ្ជកម្មជាដើម អាជីវៈរបស់ភិក្ខុនោះមិនបរិសុទ្ធឡើយ ព្រោះហេតុនោះ ភិក្ខុត្រូវសេពតែបច្ច័យដែលកើតឡើងបរិ-សុទ្ធត្រូវចៀសវាងបច្ច័យ ដែលកើតឡើងមិនបរិសុទ្ធឱ្យដូចជាគេចៀសវាងសត្វអាសិរពិសចុះ។ បើភិក្ខុអ្នកមិនរក្សាធុតង្គ បច្ច័យកើតអំពីសំណាក់សង្ឃ, សំណាក់គណៈ ឬអំពីសំណាក់គ្រហស្ថ ដែលគេ

ជ្រះថ្លាដោយគុណរបស់ខ្លួនមានការសំដែងធម៌,ការចេះចាំពុទ្ធវចនៈ, ការបំពេញវត្តនិងសម្បត្តិនៃឥរិយាបថជាដើម ឈ្មោះថាកើតឡើងបរិសុទ្ធ តែបច្ច័យដែលកើតឡើងដោយត្រេចដើរបិណ្ឌបាតជាដើម ចាត់ថាកើតឡើងបរិសុទ្ធយ៉ាងក្រៃលែង ។ បើភិក្ខុអ្នករក្សាធុតង្គ បច្ច័យដែលកើតឡើងដោយត្រេចដើរបិណ្ឌបាត, កើតឡើងអំពីសំណាក់មិត្តសំឡាញ់, កើតឡើងដោយត្រេចដើរបង្សុកូលជាដើម ឬកើតឡើងអំពីសំណាក់គ្រហស្ថ ដែលគេជ្រះថ្លាក្នុងធុតង្គរបស់ខ្លួនតាមសមគួរដល់ធុតង្គនិយម ឈ្មោះថាកើតឡើងបរិសុទ្ធ ។

មែនពិត អាជីវបារិសុទ្ធិសីលលោកឱ្យឈ្មោះថាបរិយេដ្ឋិសុទ្ធិ ព្រោះសីលនេះរមែងបរិសុទ្ធដល់ភិក្ខុអ្នកលះបង់អនេសនៈចេញហើយ ញុំាងបច្ច័យឱ្យកើតឡើងដោយសារការស្វែងរកស្មោះស្មើតាមធម៌ ។ ការស្វែងរកបច្ច័យដោយវេជ្ជកម្មជាដើមដូចពោលមកហើយផង, ដោយបាបធម៌មានកុហនាជាដើមផង ដែលជាអំពើមិនសមគួរ ហៅថាអនេសនៈ ។ ធម្មតាភិក្ខុដែលជាអ្នកជំរះនូវអាជីវបារិសុទ្ធិសីល ទុកណាជាដាច់ភត្តក៏មិនត្រូវញុំាងចិត្តឱ្យកើតឡើងក្នុងអនេសនៈដែរ កុំថាដល់ទៅខ្វើកកាយ និងវាចា តួយ៉ាងដូចព្រះចិរគុម្ពវាសីមហាតិស្សត្ថេរ ។

# រឿងព្រះចិរគុម្ពវាសីមហាតិស្សត្ថេរ

សេចក្តីដំណាលថា: ព្រះថេរៈអង្គនោះនិមន្តទៅកាន់ផ្លូវឆ្ងាយ ក្នុងគ្រាអំណត់ មានកាយលំបាក ទ្រមទ្រម ដោយដាច់ភត្តផង, ដោយការនឿយហត់តាមផ្លូវផង ទៅដល់ដើមស្វាយផ្លែ ១ ដើម ក៏ប្រះសឹងក្បែរគល់ ទទួលមានផ្លែស្វាយជ្រុះចុះមកជាច្រើនក្នុងទីនោះៗ គ្រានោះមានឧបាសកចាស់ម្នាក់ ឃើញព្រះថេរសឹងរហិតរហៃដូច្នោះ ក៏ធ្វើទឹកផ្លែស្វាយ[១] ប្រគេនឆាន់ ហើយបញ្ជិះព្រះថេរៈលើខ្នងខ្លួននាំទៅកាន់លំនៅ ។ ចំណែកព្រះថេរៈក៏ទូន្មានព្រះអង្គលោកថា:

"ន បិតា នបិ តេ មាតា ន ញាតិ នបិ ពន្ធវា
ករោតេតាទិសំ កិច្ចំ សីលវន្តស្ស ការណា=
គេមិនមែនជាបិតា មិនមែនជាមាតា មិនមែនជាញាតិ
មិនមែនជាផៅពង្សរបស់អ្នកសោះ គេធ្វើកិច្ចបែបនេះ
ដល់អ្នក ព្រោះហេតុតែអ្នក ជាបុគ្គលមានសីល"

---

១-ទឹកផ្លែស្វាយនេះហៅថា អម្ពបាន នៅក្នុងពូក អដ្ឋបាន ចាត់ចូលក្នុងពូក យាមកាលិក ភិក្ខុទទួលមកហើយត្រូវទុកឆាន់បាន ១ ថ្ងៃ ១ យប់, របៀបធ្វើត្រូវយកផ្លែស្វាយខ្ចីក៏បានទុំក៏បាន មកចិតសម្បកចេញហើយច្របាច់លាយទឹកត្រជាក់ត្រងឱ្យស្អាត បង់ស្ករក្រាមនិងកប្បូរជាដើម ឱ្យមានរសជាតិល្អ រួចហាលថ្ងៃអិនទឹងកំដៅថ្ងៃឱ្យក្តៅអ៊ុនៗ ទើបយកមកប្រគេនឆាន់បាន ។

ដូច្នេះហើយ ខំចំរើនវិបស្សនាបានលុះព្រះអរហត្តទាំងនៅលើខ្នង ឧបាសកនោះឯង ។

អាជីវបារិសុទ្ធិសីល ចប់

# បច្ចយសន្និស្សិតសីល

ឯបច្ចយសន្និស្សិតសីល លោកឱ្យឈ្មោះថា បច្ចវេក្ខណសុទ្ធិ ព្រោះបរិសុទ្ធដោយការពិចារណា ។ ព្រោះហេតុនោះបច្ច័យទាំង ៤ គឺ: ចីវរប្បច្ច័យ ១ , បិណ្ឌបាតប្បច្ច័យ ១ , សេនាសនប្បច្ច័យ ១ , គិលានភេសជ្ជប្បច្ច័យ ១ កាលបើភិក្ខុឃើញទោសក្នុងការបរិភោគប្រើប្រាស់មិនបានពិចារណា គប្បីពិចារណាឱ្យបានហ្មត់ចត់ចុះ ។

# ទោសក្នុងការបរិភោគបច្ច័យមិនបានពិចារណា

សេចក្តីដំណាលថា: ក្នុងកាលមុនភិក្ខុទាំងឡាយច្រើនបរិ-ភោគប្រើប្រាស់បច្ច័យមិនបានពិចារណា ហើយច្រើនតែមិនបានរួចអំពីនរកនិងកំណើតសត្វតិរច្ឆាន ព្រះបរមសាស្តាទ្រង់ជ្រាបដំណើរនោះទើបទ្រង់ត្រាស់ថា: "ម្នាលភិក្ខុទាំងឡាយ បច្ច័យទាំង ៤ គួរតែភិក្ខុពិចារណាទើបបរិភោគប្រើប្រាស់បាន ព្រោះហេតុនោះ ពីត្រឹមនេះតទៅ ភិក្ខុត្រូវតែពិចារណារួចសិន សឹមបរិភោគប្រើប្រាស់បច្ច័យ"

ទើបទ្រង់តាំងបែបផែនបច្ច័វេក្ខណវិធីទុកសម្រាប់ពិចារណាដោយន័យថា "ភិក្ខុក្នុងសាសនានេះ ពិចារណាដោយឧបាយសិនសឹមសេពចីវរ" ជាដើម រួចហើយទ្រង់ប្រកាសទោសក្នុងការបរិភោគប្រើប្រាស់បច្ច័យមិនពិចារណា ថា "ធម្មតាការបរិភោគប្រើប្រាស់បច្ច័យមិនពិចារណា ប្រាកដស្មើដោយការបរិភោគថ្នាំពិសយ៉ាងពុតឆាប់ មានគេពីជាន់មុនមិនបានពិចារណាឱ្យដឹងទោសសិនក៏បរិភោគដោយថ្នាំពិស បានសោយទុក្ខវេទនាដ៏ធ្ងន់" ទើបទ្រង់នាំអតីតនិទានមកដំណាល ។

## រឿងបរិភោគមិនពិចារណា

ក្នុងអតីតកាល ព្រះពោធិសត្វសោយព្រះជាតិជាអ្នកលេងខ្នាច់ មានភោគសម្បត្តិច្រើន នៅក្នុងក្រុងពារាណសី ។ មានបុរសមួយរូបដទៃជាអ្នកលេងខ្នាច់កោង(១) ថ្ងៃមួយបុរសនោះចូលទៅលេងនឹងព្រះពោធិសត្វ កាលបើក្តារខ្លួនឈ្នះក៏មិនទម្លាយមណ្ឌលដែលលេង(២) ដល់ក្តារខ្លួនចាញ់វិញក៏ដាក់ខ្នាត់ក្នុងមាត់ថា "បាត់ខ្នាច់" ហើយទំលាយមណ្ឌលដែលលេងនោះចោលក្រោកដើរចេញទៅ ។

---

១-ល្បែងខ្នាច់នេះជាល្បែងស៊ីសង ១ ប្រហែលដូចជាបៀរក្នុងយើងសព្វថ្ងៃ. ដែលហៅថាលេងកោងគឺលេងបំបាត់ ។ ២-ពាក្យថា ទំលាយមណ្ឌលដែលលេង គឺឆានៅលើកលែង ។

ព្រះពោធិសត្វជ្រាបដំណើរនោះក៏យកខ្លាច់ទាំងអស់ទៅកាន់ផ្ទះ ជ្រលក់ដោយថ្នាំពិសយ៉ាងក្លាឆុតឆាប់ ហាលថ្ងៃស្ងួត ក៏យកទៅកាន់បុរសនោះបបួលគ្នាលេងទៀត ។ បុរសនោះលេងកោងបំបាត់បែបមុនទៀត ដល់ក្តារចាញ់ ក៏ដាក់ខ្លាច់ ១ ក្នុងមាត់បន្លំថាបាត់ខ្លាច់ ស្រាប់តែពុលសន្លប់ដោយកំឡាំងថ្នាំពិស ត្រឡប់ភ្នែករមូលកសំយុងចុះ។ ព្រះពោធិសត្វប្រាថ្នាឱ្យជីវិតដល់បុរសនោះទើបឱ្យថ្នាំក្អួត ដែលស្ងួលាយដោយថ្នាំឱសថឱ្យក្អួតចេញមកធ្វើបុរសនោះឱ្យជារោគឡើង ហើយឱ្យឱវាទកុំឱ្យធ្វើយ៉ាងនុ៎ះតទៅទៀត ។

# រឿងបរិភោគបច្ច័យដោយស្និទ្ធស្នាល

មានភិក្ខុច្រើនរូបទៀតស្និទ្ធស្នាលបរិភោគប្រើប្រាស់បច្ច័យ ៤ ដែលមាតាបិតានិងបងប្អូនប្រុសស្រីជាដើមប្រគេនមក មិនបានពិចារណា ដោយគិតឃើញថា : ជនអម្បាល្មេះគួរតែឱ្យបច្ច័យដល់យើងបរិភោគប្រើប្រាស់ ទោះបីក្នុងកាលដែលយើងនៅជាគ្រហស្ថក្តី ក្នុងកាលដែលយើងបួសហើយក្តី។ ព្រះសាស្តាទ្រង់ជ្រាបដំណើរនោះ ទើបទ្រង់ត្រាស់ថា "ម្នាលភិក្ខុទាំងឡាយ បច្ច័យដែលពួកញាតិប្រគេនក្តី ក៏ត្រូវតែភិក្ខុពិចារណាសិនសឹមបរិភោគប្រើប្រាស់ ព្រោះថា កាលបើភិក្ខុបរិភោគប្រើប្រាស់មិនពិចារណាដល់ធ្វើកាលកិរិយា

ទៅនឹងមិនរួចចាកអត្តភាព ជាយក្សនិងជាប្រេតឡើយ មួយសោត ការបរិភោគប្រើប្រាស់បច្ច័យមិនពិចារណាប្រាកដស្មើរដោយការបរិ-ភោគថ្នាំពិស ព្រោះថា ធម្មតាថ្នាំពិសទោះបុគ្គលអ្នកស្និទ្ធស្នាលឱ្យក្តី បុគ្គលអ្នកមិនស្និទ្ធស្នាលឱ្យក្តី ក៏គង់ធ្វើឱ្យស្លាប់បានដូចគ្នា ដូចក្នុងកាលមុនសត្វសីហៈ ១ បរិភោគថ្នាំពិសដែលមេម្រឹគជាទីស្និទ្ធស្នាលឱ្យក៏ដល់នូវសេចក្តីស្លាប់ទៅ" រួចហើយទ្រង់នាំអតីតនិទានមកដំណាលដូចតទៅនេះ ។

## រឿងបរិភោគថ្នាំពិសដោយស្និទ្ធស្នាល

ក្នុងអតីតកាលព្រះពោធិសត្វសោយព្រះជាតិជាសេដ្ឋី មានភោគសម្បត្តិច្រើននៅក្នុងក្រុងពារាណសី ។ មានគង្វាលគោរបស់សេដ្ឋីនោះម្នាក់ នាំយកហ្វូងគោទៅសង់រោងនៅចាំឃ្វាលឯព្រៃ ក្នុងសម័យដែលចង្កៀតដោយសន្ទូង ។ គ្រានោះមានសត្វសីហៈ ១ មានចិត្តប្រតិព័ទ្ធក្នុងមេម្រឹគ ១ នៅអាស្រ័យជិតរោងគោនោះ ។ មេគោទាំងឡាយស្ទុះស្រពោនដោយសេចក្តីតក់ស្លុតនឹងសត្វសីហៈ ទាំងទឹកដោះក៏ខះស្ងួតអស់។ គ្រាក្រោយសេដ្ឋីបានដឹងហេតុនោះ ក៏បង្គាប់គង្វាលគោថា : បើដូច្នោះ អ្នកឯង ចូរធ្វើឧបាយកលចាប់មេម្រឹគនោះឱ្យបានហើយជ្រលក់រោមខ្លួនវាដោយថ្នាំពិស ហាលថ្ងៃឱ្យ

ស្ងួតកន្លងទៅពីរបីថ្ងៃ សឹមលែងវាទៅ ។ គង្វាលគោក៏ធ្វើតាមបង្គាប់ ។ សត្វសីហៈក្រឡេកឃើញមេម្រឹគស្ពុះទៅលិតសព្វសរីរៈក៏ធ្វើកាលកិរិយាស្លាប់ទៅ ។

## បច្ចវេក្ខណកាលនិងបច្ចវេក្ខណវិធី

ន័យមួយទៀត កាលបរិភោគប្រើប្រាស់បច្ច័យមិនបានពិចារណារបស់ភិក្ខុអ្នកមានសីល ហៅថា ឥណបរិភោគ=បរិភោគដោយការជំពាក់បំណុល[(១)] ។ សេចក្តីថា: បុគ្គលដែលជំពាក់បំណុលគេ រមែងមិនបានទៅកាន់ប្រទេសដែលខ្លួនប្រាថ្នាតាមគាប់ចិត្តបាន យ៉ាងណា ភិក្ខុដែលប្រកបដោយឥណបរិភោគក៏រមែងមិនបានរលាស់ខ្លួន ឱ្យផុតអំពីសំសារលោកបានយ៉ាងនោះ ។ ព្រោះហេតុនោះបច្ច័យទាំង ៤ កាលបើភិក្ខុឃើញទោសជាក់ដូចពោលមកនេះក៏ត្រូវតែពិចារណាដោយពិត ។ ក៏កាលដែលភិក្ខុពិចារណាសោតត្រូវពិចារណាក្នុងកាល ៣គឺ: **បដិលាភកាល**=កាលដែលបានមក

---

១-បរិភោគមាន ៤ គឺ ថេយ្យបរិភោគ=បរិភោគដោយការលួច ជាបរិភោគរបស់ភិក្ខុទ្រុស្ត-សីល ១. ឥណបរិភោគ=បរិភោគដោយការជំពាក់បំណុល ជាបរិភោគរបស់ភិក្ខុអ្នកមានសីល តែមិនបានពិចារណា ១. ទាយជ្ជបរិភោគ=បរិភោគអំណោយដែលត្រូវបាន ជាបរិភោគរបស់សេខបុគ្គល ៧ ពួកនិងភិក្ខុអ្នកមានសីលហើយបានពិចារណា ១. សាមិបរិភោគ=បរិភោគរបស់បុគ្គលជាម្ចាស់ ជាបរិភោគរបស់ព្រះខីណាស្រព ១ (មើលសេចក្តីពិស្តារក្នុងសីលនិទ្ទេស) ។

ឬកាលដែលទទួលមក ១, **បរិភោគកាល**=កាលកំពុងបរិភោគប្រើប្រាស់ ១, **បច្ឆាកាល**=កាលជាខាងក្រោយអំពីកាលបរិភោគប្រើប្រាស់ ១ ។

អធិប្បាយៈ ក្នុងបដិលាភកាល គឺកាលដែលភិក្ខុបាន ឬទទួលបច្ច័យមក ត្រូវពិចារណាដោយធាតុប្បច្ចវេក្ខណៈថា "**យថាបច្ចយំ បវត្តមានំ ធាតុមត្តមេវេតំ យទិទំចីវរំ**=ចីវរឯណានេះចីវរនុំះឯង គ្រាន់តែជាធាតុប្រព្រឹត្តទៅតាមសមគួរដល់បច្ច័យ"ដូច្នេះជាដើមក៏បាន ឬក៏ពិចារណាដោយ បដិកូលប្បច្ចវេក្ខណៈថា "**សព្វានិ បន ឥមានិ ចីវរានិ អជិគុច្ឆនីយានិ**=ចីវរទាំងឡាយទាំងពួងនេះជារបស់មិនគួរខ្ពើមរអើមឡើយ" ដូច្នេះជាដើមក៏បានពិចារណាបែបនេះសូម្បី ១ ចប់ក៏បានដែរ ។ កាលភិក្ខុទទួលបច្ច័យមកបានពិចារណាយ៉ាងនេះ ដល់បរិភោគប្រើប្រាស់តទៅ មិនពិចារណាក៏មិនមានទោសឡើយ ដូចប្រើប្រាស់បាត្រនិងចីវរដែលភិក្ខុបានអធិដ្ឋានទុកដូច្នោះដែរ[(១)] ។ពាក្យដែលពោលមកនេះគ្រាន់តែជាប្រធានក្នុងការសំដែងឱ្យឃើញ សេចក្ដីបរិសុទ្ធក្នុងខាង

---

១- បាត្រនិងចីវរ បើភិក្ខុបានអធិដ្ឋានតែ ១ លើកដំបូងហើយ បើមិនមានហេតុដែលគួរឱ្យដាច់អធិដ្ឋានទេ ភិក្ខុប្រើប្រាស់បានរហូតតទៅមិនបាច់អធិដ្ឋានទៀតឡើយ ។

ដើមដោយការពិចារណាប៉ុណ្ណោះ មិនមែនជាប្រធានក្នុងការហាមមិន ភិក្ខុពិចារណាក្នុងការបរិភោគកាលនោះទេ ព្រោះហេតុនោះក្នុងបរិភោគ កាលដ៏គួរភិក្ខុពិចារណាទៀតចុះ ។ ក៏ក្នុងបរិភោគកាលនោះ ត្រូវឱ្យ ភិក្ខុពិចារណាដំណាលគ្នានឹងការបរិភោគប្រើប្រាស់ដោយតំខណិកប្ប ច្ចវេក្ខណៈថា "**បដិសង្ខា យោ និសោ ចីវរំ បដិសេវាមិ**=អញ ពិចារណាដោយឧបាយហើយ សឹមសេពនូវចីវរ"ដូច្នេះជាដើម ។ ក្នុង តំខណិកបច្ចវេក្ខណៈនេះត្រូវឱ្យភិក្ខុពិចារណាក្នុងចីវរប្បច្ច័យឱ្យរាល់ ៗ ប្រយោគដែលប្រើប្រាស់, បិណ្ឌបាតប្បច្ច័យរាល់ៗ ពំនូត,សេនាសន-ប្បច្ច័យរាល់ៗ ប្រយោគដែលប្រើប្រាស់ រាល់ ៗ វារៈដែលចូលទៅ គឺ ត្រូវពិចារណាក្នុងកាលជាទីចូលទៅខាងក្នុង តាំងពីត្រឹមរងទឹកទៅនឹង ក្នុងកាលជាទីអង្គុយ, កាលជាទីដេក ។ បើក្នុងបរិភោគកាល ភិក្ខុមិន អាចពិចារណាបានដល់បរិភោគប្រើប្រាស់រួចហើយទៅ ត្រូវភិក្ខុពិចារណា ក្នុងបច្ឆាកាលដោយអតីតប្បច្ចវេក្ខណៈថា "**អជ្ជ មយា អបច្ច-វេក្ខិត្វា យំ ចីវរំ បរិភុត្តំ**=ចីវរឯណា ដែលអញមិនបានពិចារណា ហើយប្រើប្រាស់ហើយក្នុងថ្ងៃនេះ"ដូច្នេះជាដើម សូម្បីពិចារណា ១ ចប់ក៏បាន ។

ន័យមួយទៀត លោកសំដែងថាៈ បើភិក្ខុមិនអាចនឹង

ពិចារណាក្នុងបរិភោគកាលដោយ តំខណិកប្បច្ចវេក្ខណៈបានទេ គប្បីពិចារណាដោយអតីតប្បច្ចវេក្ខណៈ តាមកាលវិសេសចាកកាលដែលពោលមកហើយ គឺតាំងពីត្រឹមបរិភោគកាលទៅខាងនាយ ទោះកាលមុនភត្តក្តី, ក្រោយភត្តក្តី, យាម ៣ នៃរាត្រីក្តី ឱ្យតែនៅត្រឹមរវាងថ្ងៃ ១ នោះ ហើយពិចារណា ៤ ចប់ក៏បាន ៣ ចប់ ២ ចប់ ឬ ១ ចប់ក៏បាន តែធ្វើបែបនេះគួរតែក្នុងបច្ច័យ ៣ ចប់ ដ៏សេស ឯភេសជ្ជ-ប្បច្ច័យ ក្នុងបដិលាភកាលទោះបីភិក្ខុបានពិចារណាក្តី មិនបានពិចារណាក្តី ដល់ទៅក្នុងបរិភោគកាល ត្រូវតែភិក្ខុពិចារណាខានមិនបាន ព្រោះព្រះអដ្ឋកថាចារ្យពោលទុកថាៈ ក្នុងភេសជ្ជប្បច្ច័យត្រូវតែភិក្ខុពិចារណាក្នុងកាលដែលទទួលផង រួចហើយផ្ចង់ស្មារតីពិចារណាក្នុងកាលដែលបរិភោគផងទៀតទើបគួរ កាលបើភិក្ខុបានពិចារណាតែក្នុងកាលដែលទទួល ដល់ក្នុងកាលដែលបរិភោគមិនបានពិចារណានឹងត្រូវអាបត្តិទុក្កដ បើបែរជាមិនបានពិចារណាក្នុងកាលដែលទទួលហើយបានពិចារណាក្នុងការដែលបរិភោគវិញ មិនត្រូវអាបត្តិឡើយតែថ្វីបើដូច្នោះក៏គួរតែភិក្ខុប្រុងស្មារតីពិចារណាក្នុងកាលទាំងពីរចុះ។ មែនពិត បច្ចយសន្និស្សិតសីល រមែងបរិសុទ្ធដោយការពិចារណា មិនមែនបរិសុទ្ធដោយសភាពរបស់បច្ច័យឡើយ ឱ្យតែបានពិចារណាក្នុង

បច្ច័យណាមួយ ដោយបច្ចវេក្ខណៈណាមួយក៏គង់បរិសុទ្ធបាន ព្រោះហេតុនោះពាក្យថា: "ភិក្ខុមិនបានពិចារណាក្នុងកាលដែលបរិភោគនឹងត្រូវអាបត្តិទុក្កដ"ដូច្នេះនោះ លោកសំដែងឱ្យឃើញការបែកធ្លាយបាតិមោក្ខសំវរសីលទេ មិនមែនបែកធ្លាយបច្ចយសន្និស្សិតសីលឡើយ ព្រោះបច្ចយសន្និស្សិតសីលនោះ អាចធ្វើឱ្យបរិសុទ្ធដោយអតីតប្បច្ចវេក្ខណៈទៀតបាន ឯការបែកធ្លាយបច្ចយសន្និស្សិតសីលទោះក្នុងភេសជ្ជប្បច្ច័យក្តី ក្នុងបច្ច័យដ៏សេសក្តី ត្រូវដឹងតាមពាក្យថា "ឥណបរិភោគ"ជាដើមចុះ ។ ក៏តំខណិកប្បច្ចវេក្ខណៈ ក្នុងភេសជ្ជប្បច្ច័យរក្សាមិនឱ្យបែកធ្លាយបានសីល ២ គឺ:បាតិមោក្ខសំវរសីល ១, បច្ចយសន្និស្សិតសីល ១ ឯអតីតប្បច្ចវេក្ខណៈរក្សាបានតែ បច្ចយសន្និស្សិតសីល ១ប៉ុណ្ណោះ បច្ចវេក្ខណៈទាំង ២ គឺទាំងតំខណិកប្បច្ចវេក្ខណៈ ទាំងអតីតប្បច្ចវេក្ខណ ក្នុងបច្ច័យដ៏សេស ក៏រក្សាបានតែបច្ចយសន្និស្សិតសីល ១ ដូចគ្នា ព្រោះហេតុនោះក្នុងបច្ច័យទាំង ៤ បើភិក្ខុបានធ្វើតំខណិកប្បច្ចវេក្ខណៈរួចហើយ មិនបាច់ធ្វើអតីតប្បច្ចវេក្ខណៈទៀតក៏បាន តែបើមិនទាន់បានធ្វើទេ ត្រូវតែធ្វើឡើង ដើម្បីញ៉ាំងបច្ចយសន្និស្សិតសីលឱ្យបរិសុទ្ធ ឯបាតិមោក្ខសំវរសីលដែលបែកធ្លាយទៅព្រោះហេតុតែមិនបានធ្វើតំខណិកប្បច្ចវេក្ខណៈក្នុងភេសជ្ជ-

ប្បច្ច័យនោះត្រូវឱ្យធ្វើបរិសុទ្ធដោយការសំដែងចុះ បើភិក្ខុមិនបានធ្វើបច្ចវេក្ខណៈណាមួយសោះគ្រប់បច្ច័យទាំង ៤ ឱ្យអរុណរះឡើងទាន់សីលទាំង ២ ក៏បែកធ្លាយតាមន័យដូចពោលមកហើយ ឯភិក្ខុនោះសោតក៏តាំងនៅក្នុងទីនៃឥណបរិភោគ ។

## រឿងព្រះភាគិនេយ្យសង្ឃរក្ខិតសាមណេរ

ក៏ភិក្ខុអ្នកបំពេញនូវបច្ចយសន្និស្សិតសីលគួរយកតម្រាប់តាមព្រះភាគិនេយ្យសង្ឃរក្ខិតសាមណេរ ព្រោះសាមណេរអង្គនោះ តែងតែពិចារណារួចដោយប្រពៃ ទើបបរិភោគប្រើប្រាស់បច្ច័យ ព្រោះហេតុនោះទើបលោកសំដែងប្រកាសអង្គលោកថា:

ឧបជ្ឈាយោ មំ ភុញ្ជមានំ សាលិកុរំ សុនិព្វុតំ
មាហេវ ត្វំ សាមណេរ ជិវ្ហំ ឈាបេសិ អសញ្ញតោ ។
ឧបជ្ឈាយស្ស វចោ សុត្វា សំវេគមលភិន្តទា
ឯកាសនេ និសីទិត្វា អរហត្តមបាបុណឹ ។
សោហំ បរិបុណ្ណសង្កប្បោ ចន្ទោ បណ្ណរសោ យថា
សព្វាសវបរិក្ខិណា នត្ថិ ទានិ បុនព្ភវោ=

ខ្ញុំកំពុងតែឆាន់បាយសាលីត្រជាក់រហើម ព្រះឧបជ្ឈាយ៍

ប្រាប់ថា: ម្នាលសាមណេរ អ្នកកុំដុតអណ្តាតរបស់ខ្លួនឱ្យឆេះ ព្រោះតែមិនពិចារណាឡើយ ។ ខ្ញុំបានស្តាប់វាចារបស់ព្រះឧបជ្ឈាយ៍ក្នុងកាលណោះក៏បាននូវសេចក្តីសង្វេគ ខ្ញុំអង្គុយនៅតែលើអាសនៈ ១ បានដល់នូវព្រះអរហត្ត ។ ខ្ញុំមានតម្រិះពេញបរិបូណ៌ដូចព្រះច័ន្ទក្នុងថ្ងៃ ១៥ កើត ខ្ញុំមានអាសវៈក្សិណក្ស័យអស់ហើយ ឥឡូវនេះខ្ញុំលែងកើតទៀតហើយ ។

## **អវសានគាថា**

**តស្មា អញ្ញោបិ ទុក្ខស្ស បត្ថយន្តោ បរិក្ខយំ**
**យោនិសោ បច្ចវេក្ខិត្វា បដិសេវេថ បច្ចយេ=**

ព្រោះហេតុនោះ សូម្បីកុលបុត្រឯទៀត កាលបើប្រាថ្នាចង់ឱ្យក្ស័យទុក្ខ ក៏គួរតែពិចារណាដោយឧបាយសិនសឹមសេពនូវបច្ច័យ ។

<u>បច្ចយសន្និស្សិតសីល ចប់</u>

## **សេចក្តីសរុបក្នុងចតុប្បរិសុទ្ធិសីល**

មែនពិតអនាគារិយវិន័យ ពោលគឺចតុប្បារិសុទ្ធិសីលមានបាតិមោក្ខសំវរសីលជាដើម កាលបើភិក្ខុបានធ្វើឱ្យបរិសុទ្ធប្រពៃតាម

តាមន័យដូចបានពណ៌នាមកនេះ ឈ្មោះថាភិក្ខុបានសិក្សាដោយល្អ. អនាគារិយវិន័យ ដែលភិក្ខុបានសិក្សាដោយល្អយ៉ាងនេះសូម្បីដល់ទៅអរហត្តផល ក៏អាចនាំយកមកប្រគល់ឱ្យដល់ភិក្ខុនោះបានដែរ កុំថាតែត្រឹមមគ្គផលជាន់ទាបឡើយ ព្រោះហេតុនោះ កុលបុត្រអ្នកមានសទ្ធាដែលបានចូលមកបួសក្នុងព្រះពុទ្ធសាសនា ដោយសេចក្ដីស្មោះត្រង់ គួរតែខំផ្ចិតផ្ចង់សិក្សាឱ្យបានស្អាតហ្មត់ចត់ចុះ ។

ចតុប្បារិសុទ្ធិសីលចប់

ពណ៌នាមកដោយសង្ខេប ក្នុងអនាគារិយវិន័យ ជាសេចក្ដីទេសនា ដើម្បីជាគ្រឿងប្រដាប់ប្រាជ្ញាស្មារតីនៃសិក្ខាកាមកុលបុត្រទាំងឡាយក៏សមគួរតែត្រឹមប៉ុណ្ណេះ ។

អនាគារិយវិន័យ ចប់

**វិនយោ សាសនស្ស មូលំ**

ព្រះវិន័យ ជាឫសកែវ របស់សាសនា

**អ៊ុច-រស់**